សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច
Université Royale de Droit et des Science Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ប្រតិបត្តិការធានារ៉ាប់រង

ស្រាវជ្រាវពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧

រៀបរៀងដោយ
និស្សិតឈ្មោះ ៖ លោក **ហ៊ាន ស័ក្កដា**
កញ្ញា **ប៉ាន ឡាលីន**

សាស្រ្តាចារ្យណែនាំ ៖
លោក **ជិន វណ្ណារ៉ា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្រ្ត**
ជំនាន់ទី១៧

ឆ្នាំចូលសិក្សា ២០១៣
ឆ្នាំសរសេរសារណា២០១៧

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ហ៊ន ស័ក្កដា** និង នាងខ្ញុំឈ្មោះ **ប៊ាន ឡាលីន** ជានិស្សិតបរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ជំនាន់ទី១៧ ឆ្នាំសិក្សា ២០១៣-២០១៧ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមសម្តែងនូវសេចក្តីថ្លែងអំណរគុណ និង ដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ ៖

លោក**ឪពុក** អ្នក**ម្តាយ** ដែលលោកទាំងពីរជាអ្នកមានគុណដ៏ធំធេង សម្រាប់យើងខ្ញុំជាកូនៗ មិនអាចបំភ្លេចបាននូវគុណូបការៈដ៏ថ្លៃថ្លា និង មិនអាចកាត់ថ្លៃបានឡើយ ដោយលោកទាំងពីរបាន ចិញ្ចឹមបីបាច់ថែរក្សាតាំងពីតូចរហូតដល់ធំ ស្តីប្រដៅទូន្មានអប់រំកូនៗឱ្យដើរផ្លូវល្អក្នុងគន្លងធម៌ ផ្តល់ប្រាក់កាស ផ្តល់សំលៀកបំពាក់...។ ជាពិសេសលោកទាំងពីរបានខិតខំប្រឹងប្រែងធ្វើការរកប្រាក់ ទោះបីហត់នឿយលំបាកយ៉ាងណាក៏ដោយឱ្យតែកូនៗទទួលបានការអប់រំរៀនសូត្រ និងទទួលបានចំណេះដឹង ។

ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក លោកស្រី ជាសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំអស់ពីកម្លាំងកាយចិត្តក្នុងការបង្ហាត់បង្រៀនផ្តល់ចំណេះដឹងជាច្រើនទាក់ទងនឹងវិស័យច្បាប់ ។

លោកសាស្ត្រាចារ្យ **ជិន វណ្ណារ៉ា** ដែលបានចំណាយពេលដ៏មានតម្លៃក្នុងការណែនាំ ផ្តល់យោបល់ល្អៗដល់យើងខ្ញុំក្នុងការស្រាវជ្រាវទៅលើប្រធានបទនេះប្រកបដោយភាពរីករាយ និង យកចិត្តទុកដាក់ជាទីបំផុត ។

យើងខ្ញុំសូមជូនពរដល់ លោកឪពុក អ្នកម្តាយ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិ-ការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក លោកស្រីជាសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច បងប្អូន សាច់ញាតិ មិត្តភក្តិទាំងអស់ ឱ្យជួបប្រទះនូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

ជាចុងក្រោយ ខ្ញុំសូមលើកហត្ថាទាំងទ្វេបួងសួងដល់សក្កទេវរាជ និង វត្ថុស័ក្តិសិទ្ធិក្នុងលោក សូមជួយតាមថែរក្សា ការពារប្រជាពលរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា និងប្រជាជននៅលើពិភពលោក ឱ្យជួបតែសេចក្តីសុខ សេចក្តីចម្រើន សុខដុមរមនា ជាពិសេសសូមឱ្យប្រទេសកម្ពុជា ជួបតែសុខសុវត្ថិភាព សន្តិភាព និងមានការអភិវឌ្ឍប្រកបដោយចីរភាព...។

# អារម្ភកថា

ឆ្លងកាត់ការសិក្សាអស់រយៈពេលបួនឆ្នាំក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច យើងខ្ញុំបានទទួលនូវចំណេះដឹងពាក់ព័ន្ធនឹងវិស័យច្បាប់ និងចំណេះដឹងទូទៅជាច្រើន ។ ការសិក្សាផ្នែកច្បាប់ពិតជាមានសារៈសំខាន់ខ្លាំងណាស់ ព្រោះថាប្រទេសនីមួយៗតែងតែមានច្បាប់គ្រប់គ្រងប្រទេសរៀងៗខ្លួន លើសពីនេះក្នុងសកម្មភាពជីវភាពប្រចាំថ្ងៃរបស់បុគ្គលម្នាក់ៗតែងតែផ្សារភ្ជាប់ទៅទំនាក់ទំនងគតិយុត្តដែលខានមិនបាន ។ ចំពោះការបកស្រាយប្រធានបទនេះ ផ្អែកលើលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងវិស័យធានារ៉ាប់រង ជាពិសេសលើកយកការអនុវត្តជាក់ស្តែងដែលកំពុងកើតមាននៅពេលបច្ចុប្បន្នផងដែរ ។ ដោយហេតុថា ការធានារ៉ាប់រងកំពុងតែមានការរីកចម្រើននៅក្នុងប្រទេសកម្ពុជា ហើយត្រូវបានប្រជាពលរដ្ឋចង់ស្វែងយល់ឱ្យកាន់តែច្បាស់ទៅលើវិស័យនេះថាតើអ្វីទៅជាការធានារ៉ាប់រង ? ហើយពួកគាត់នឹងទទួលបានផលប្រយោជន៍អ្វីខ្លះ នៅពេលដែលពួកគាត់ទិញធានារ៉ាប់រងពីក្រុមហ៊ុនធានារ៉ាប់រង ? ម្យ៉ាងទៀត ឯកសារពន្យល់អំពីការធានារ៉ាប់រងនៅមានកម្រិតតិចតួច នៅក្នុងបណ្ណាល័យមិនអាចផ្តល់ជូននូវចំណេះដឹងគ្រប់គ្រាន់ដល់និស្សិត និងអ្នកស្រាវជ្រាវបាន ដោយមើលឃើញពីមូលហេតុដ៏មានសារៈសំខាន់ទាំងនេះហើយទើបយើងខ្ញុំសម្រេចចិត្តជ្រើសរើសយកប្រធានបទដែលមានចំណងជើងថា ប្រតិបត្តិការធានារ៉ាប់រងមកធ្វើការស្រាវជ្រាវ ។ ជាការពិត ប្រធានបទដែលទាក់ទងនឹងការធានារ៉ាប់រងនេះ ក៏មាននិស្សិតមួយចំនួនបានសរសេរខ្លះដែរ ប៉ុន្តែអ្វីដែលពួកគាត់បានសសរសេរគឺយោងតាមបទបញ្ញត្តិចាស់ៗដែលបាននិរាករណ៍ទៅហើយ ដូច្នេះយើងខ្ញុំនឹងសរសេរដោយផ្អែកទៅបទបញ្ញត្តិច្បាប់ដែលនៅជាធរមាន ដែលបទបញ្ញត្តិទាំងនោះត្រូវបានកំពុងអនុវត្តក្នុងពេលបច្ចុប្បន្ន ។ យើងខ្ញុំសង្ឃឹមថាសារណាមួយនេះនឹងផ្តល់អត្ថប្រយោជន៍មួយចំនួនតាមរយៈការផ្តល់ជាគំនិត យោបល់ផ្សេងៗដល់និស្សិតអ្នកសិក្សាស្រាវជ្រាវដែលចង់ដឹងអំពីការធានារ៉ាប់រងនេះ ។ សារណានេះត្រូវបានយើងខ្ញុំសរសេរឡើងដោយការផ្ចិតផ្ចង់ និងយកចិត្តទុកដាក់បំផុតដើម្បីឱ្យអត្ថន័យកាន់តែល្អ ងាយស្រួលយល់ តែទោះបីជាយ៉ាងណាក៏ដោយ ក៏នៅតែមានចំណុចខ្វះខាតខ្លះៗផងដែរ ។ យើងខ្ញុំនឹងរង់ចាំស្វាគមន៍នូវការរិះគន់កែលម្អក្នុងន័យស្ថាបនាពីសំណាក់មិត្តអ្នកអានទាំងអស់គ្នាដែលចូលរួមជាគំនិតយោបល់ដើម្បីធ្វើឱ្យអត្ថន័យប្រធានបទនេះកាន់តែល្អប្រសើរឡើងថែមទៀត ។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម**......................................................................................................១

**ជំពូក១ ៖ ចំណាត់ថ្នាក់នៃការធានារ៉ាប់រង**.........................................................................៣

**១.១. ការធានារ៉ាប់រងទូទៅ**...........................................................................................៣

១.១.១. ការធានារ៉ាប់រងទ្រព្យសម្បត្តិ ....................................................................៣

១.១.២. ការធានារ៉ាប់រងភារៈទទួលខុសត្រូវ .............................................................៥

១.១.២.១. ការធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្ត...........................................៥

១.១.២.២. ការធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន...........................................៧

១.១.២.៣. ការធានារ៉ាប់រងភារៈទទួលខុសត្រូវការដឹកជញ្ជូនអ្នកដំណើរ.....................៩

១.១.៣. ការធានារ៉ាប់រងសុខភាព.........................................................................១១

**១.២. ការធានារ៉ាប់រងអាយុជីវិត**.......................................................................................១១

១.២.១. ការធានារ៉ាប់រងមានកាលកំណត់...............................................................១២

១.២.២. ការធានារ៉ាប់រងមួយជីវិតកាល.................................................................១២

១.២.៣. ការធានារ៉ាប់រងទាយជ្ជទាន.....................................................................១៣

១.២.៤.ការធានារ៉ាប់រងធនលាភ...........................................................................១៣

**ជំពូក២ ៖ កិច្ចសន្យាធានារ៉ាប់រង**...................................................................................១៤

**២.១. លក្ខខណ្ឌនៃការបង្កើតកិច្ចសន្យាធានារ៉ាប់រង**.......................................................១៥

២.១.១. លក្ខខណ្ឌគ្រឹះ.........................................................................................១៥

២.១.១.១. ការព្រមព្រៀង.....................................................................................១៥

ក. ជំនួបនៃឆន្ទៈ...............................................................................................១៥

ក.១. សំណើ......................................................................................................១៥

ក.២. ស្វីការ............................................................................................១៦
ខ. ការព្រមព្រៀងដោយគ្មានវិការៈ...........................................................................១៦
ខ.១. ការភាន់ច្រឡំ.........................................................................................១៧
ខ.២. ការឆបោក..............................................................................................១៧
ខ.៣. ការគម្រាមកំហែង.......................................................................................១៧
ខ.៤. ព័ត៌មានមិនពិត.........................................................................................១៧
ខ.៥. ការរំលោភបំពានលើស្ថានភាព.............................................................................១៧
ខ.៦. អំពើកេងចំណេញហួសហេតុ.................................................................................១៨
២.១.១.២. សមត្ថភាព..........................................................................................១៨
ក. សមត្ថភាពរបស់អ្នកទិញធានារ៉ាប់រង...........................................................................១៨
ខ. សមត្ថភាពរបស់ក្រុមហ៊ុនធានារ៉ាប់រង.........................................................................១៩
២.១.១.៣. កម្មវត្ថុ..........................................................................................១៩
២.១.២. លក្ខខណ្ឌទម្រង់......................................................................................២១
២.១.២.១. បណ្ណសន្យារ៉ាប់រង..................................................................................២១
២.១.២.២. វិញ្ញាបនបត្រធានារ៉ាប់រង.............................................................................២២
២.១.២.៣. កំណត់សំអាង........................................................................................២៣
**២.២. អានុភាពនៃកិច្ចសន្យាធានារ៉ាប់រង**.....................................................................២៣
២.២.១. សិទ្ធិ និង កាតព្វកិច្ចរបស់ក្រុមហ៊ុនធានារ៉ាប់រង.............................................................២៣
២.២.១.១. សិទ្ធិទទួលបានបុព្វលាភ...............................................................................២៣
២.២.១.២. កាតព្វកិច្ចពន្យល់......................................................................................២៣
២.២.១.៣. កាតព្វកិច្ចធ្វើសំណាង..................................................................................២៤
២.២.២. សិទ្ធិ និង កាតព្វកិច្ចរបស់អ្នកទិញធានារ៉ាប់រង.............................................................២៤

២.២.២.១. សិទ្ធិទទួលបានប្រាក់សំណងធានារ៉ាប់រង..........................................២៤

២.២.២.២. សិទ្ធិធ្វើអនុប្បទានការធានារ៉ាប់រង..........................................២៥

២.២.២.៣. សិទ្ធិសុំដកមកវិញនូវបុព្វលាភនៅពេលធ្វើអនុប្បទាន..........................២៥

២.២.២.៤. កាតព្វកិច្ចបង់បុព្វលាភរ៉ាប់រង..........................................២៥

២.២.២.៥. កាតព្វកិច្ចជូនដំណឹង..........................................២៥

២.២.២.៦. កាតព្វកិច្ចសហការ..........................................២៦

**២.៣. ការបញ្ចប់កិច្ចសន្យាធានារ៉ាប់រង**..........................................២៦

២.៣.១. តាមការកំណត់របស់ច្បាប់..........................................២៦

២.៣.១.១. ការជួសជុសធំ..........................................២៧

២.៣.១.២. ធនក្ស័យ..........................................២៧

២.៣.១.៣. មរណភាព..........................................២៧

២.៣.១.៤. ការបាត់បង់ទាំងស្រុងនូវកម្មវត្ថុ..........................................២៨

២.៣.២. ការលុបចោលកិច្ចសន្យា..........................................២៨

២.៣.២.១. ការមិនអនុវត្តកាតព្វកិច្ចរបស់អ្នកត្រូវបានធានារ៉ាប់រង..........................២៨

២.៣.២.២. ការលាក់លៀម ឬធ្វើប្រតិវេទន៍ខុស..........................................២៨

២.៣.២.៣. វិការៈក្នុងការបង្ហាញឆន្ទៈ..........................................២៩

២.៣.៣. ការព្រមព្រៀង..........................................២៩

២.៣.៣.១. ការបញ្ចប់មុនកាលកំណត់..........................................២៩

២.៣.៣.២. កាលបរិច្ឆេទដល់កាលកំណត់..........................................២៩

សេចក្តីសន្និដ្ឋាន..........................................៣១

ឯកសារយោង

ឧបសម្ព័ន្ធ

# សេចក្តីផ្តើម

ឧស្សាហកម្មជាវិស័យមួយដ៏សំខាន់នៃសេដ្ឋកិច្ច ។ ពាក្យឧស្សាហកម្មត្រូវបានអ្នកហិរញ្ញវត្ថុយកមកប្រើផងដែរ ។ យ៉ាងណាមិញ យើងឃើញមានពាក្យឧស្សាហកម្មហិរញ្ញវត្ថុ ដែលសំដៅលើទីផ្សារមូលបត្រ ប្រាតិភោគទាក់ទងនឹងការបញ្ចាំ ប្រាតិភោគដោយអនុប្បទាន ព្រមទាំងវិស័យធានារ៉ាប់រងផងដែរ ។ នៅក្នុងប្រទេសកម្ពុជា វិស័យធានារ៉ាប់រងនេះ មានការវិវត្តន៍ជាបីដំណាក់កាលសំខាន់ៗគឺ ចាប់ពីឆ្នាំ ១៩៥៦ ដល់ ឆ្នាំ ១៩៧៥ អាជីវកម្មធានារ៉ាប់រងគ្រប់ប្រភេទ ត្រូវផ្តាច់មុខដោយរដ្ឋ ។ ចាប់ពីពេលនោះមក ក្រុមហ៊ុនធានារ៉ាប់រងជាតិមួយមានឈ្មោះថា ក្រុមហ៊ុនធានារ៉ាប់រង (SNA) ត្រូវបានបង្កើតឡើងដើម្បីបម្រើសេវាធានារ៉ាប់រងក្នុងទីផ្សារកម្ពុជា ។ នៅក្នុងសម័យប៉ុលពតហេដ្ឋារចនាសម្ព័ន្ធទាំងអស់ត្រូវបំផ្លាញ សកម្មភាពដោះដូរទំនិញត្រូវបានលុបបំបាត់ទាំងស្រុង ហើយសកម្មភាពនៃវិស័យធានារ៉ាប់រងត្រូវបានលុបបំបាត់ផងដែរ ។ ចាប់ពីឆ្នាំ ១៩៩០ ដល់ ឆ្នាំ ១៩៩៩ រដ្ឋសភាបានអនុម័តច្បាប់ស្តីពីការបង្កើតអាជីវកម្មធានារ៉ាប់រង ហើយវិស័យធានារ៉ាប់រងត្រូវស្ថិតក្រោមការគ្រប់គ្រងនិងចាត់ចែងដោយរដ្ឋ ។ បន្ទាប់មកទៀត រដ្ឋាភិបាលក៏បានបង្កើតនូវលិខិតបទដ្ឋានគតិយុត្តមួយចំនួនដែលទាក់ទងនឹងវិស័យធានារ៉ាប់រងមានដូចជា ប្រកាស សេចក្តីណែនាំ ជាដើម ។ ចាប់ពីឆ្នាំ ២០០០ ដល់បច្ចុប្បន្ន រដ្ឋសភាបានអនុម័តច្បាប់ស្តីពីការធានារ៉ាប់រង ឆ្នាំ ២០០០ ហើយអនុក្រឹត្យស្តីពីការធានារ៉ាប់រងក៏ត្រូវបានអនុម័តផងដែរ ។ ក្រោយមករាជរដ្ឋាភិបាលបានបង្កើតឱ្យមានសហគ្រាសសាធារណៈដែលមានលក្ខណៈជាក្រុមហ៊ុនរដ្ឋឈ្មោះ ក្រុមហ៊ុនជាតិធានារ៉ាប់រង ហៅកាត់ថា កាមិនកូ និង ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា ហៅកាត់ថា កម្ពុជា-រី ដោយស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស និង ហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ[1] ។ នៅឆ្នាំ ២០១៤ រដ្ឋសភាបានអនុម័តច្បាប់ស្តីពីការធានារ៉ាប់រងថ្មី ក្នុងគោលបំណងធានានូវការអភិវឌ្ឍប្រកបដោយចីរភាពនៃវិស័យធានារ៉ាប់រង ផលប្រយោជន៍សាធារណៈ និង ទំនុកចិត្តដល់សេវាធានារ៉ាប់រង សង្គតិភាពជាមួយនឹងគោលការណ៍គ្រឹះធានារ៉ាប់រងអន្តរជាតិ ផលប្រយោជន៍របស់រូបវន្តបុគ្គល និង នីតិបុគ្គលដែលជាអ្នកត្រូវបានធានារ៉ាប់រង ។

បច្ចុប្បន្នយើងឃើញថាមានក្រុមហ៊ុនធានារ៉ាប់រងជាច្រើន កំពុងតែធ្វើប្រតិបត្តិការធានារ៉ាប់រងនៅក្នុងទីផ្សារកម្ពុជា ។ ប្រភេទប្រតិបត្តិករធានារ៉ាប់រងទាំងនោះមានដូចជា ក្រុមហ៊ុនធានារ៉ាប់រងទូទៅ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច ប្រតិបត្តិករធានារ៉ាប់រងសុខភាពសហគមន៍ ក្រុមហ៊ុនជើងសារ និង ភ្នាក់ងារធានារ៉ាប់រង ។ ក្រុមហ៊ុនធានារ៉ាប់រងទូទៅមានដូចជា ក្រុមហ៊ុនធានារ៉ាប់រង អេស៊ីអា អ៊ិនស្វូរិន(ខេមបូឌា)ភីអិលស៊ី ក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា(កាមិនកូ)

[1] គេហទំព័ររបស់នាយកដ្ឋានធានារ៉ាប់រង និងសោធន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, អំពីប្រវត្តិនៃវិស័យធានារ៉ាប់រងនៅកម្ពុជា

ក្រុមហ៊ុនធានារ៉ាប់រង កម្ពុឡុនប៉ាក ភីអិលស៊ី ក្រុមហ៊ុនធានារ៉ាប់រង ហ្វតតេ អ៊ិនស្វរិនស៍ ( ខេមបូឌា ) ក្រុមហ៊ុនធានារ៉ាប់រង អ៊ិនហ្វីនីធី ជេនណេរលអិនស្វរិន ភីអិលស៊ី ក្រុមហ៊ុនធានារ៉ាប់រងកម្ពុជា-វៀតណាម ភីអិលស៊ី និង ក្រុមហ៊ុនធានារ៉ាប់រងបន្ទកម្ពុជា ។ ចំណែកឯក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត មាន ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត កម្ពុជា ‹កម្ពុជា ឡៃហ្វ› ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត មេនូឡាយហ្វ៍ ( ខេមបូឌា ) ភីអិលស៊ី ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ព្រូដិនសល ( ខេមបូឌា ) ឡាយហ្វ៍ អឹស្វរិន៍ ភីអិលស៊ី ។ ក្រុមហ៊ុនធានារ៉ាប់រងខ្នាចតូច និង ប្រតិបត្តិករធានារ៉ាប់រងសុខភាពសហគមន៍ មាន ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចប្រេវ៉រ ( កម្ពុជា ) ឡាយហ្វ៍ អ៊ិនស្វរិន ភីអិលស៊ី និង អង្គការគណៈកម្មាធិការ សុខភាពកម្ពុជា ‹គ.ស.ក› ។ ចំណែកក្រុមហ៊ុនជើងសា និង ភ្នាក់ងារធានារ៉ាប់រងមានដូចជា ភ្នាក់ងារ ធានារ៉ាប់រង AG Services Consulting Co, Ltd. ភ្នាក់ងារធានារ៉ាប់រង ធនាគារកម្ពុជាសាធារណៈ ភីអិលស៊ី ភ្នាក់ងារធានារ៉ាប់រងអេស៊ារ៉ែន អ៊ិនស្វរេន អេជេន (ខេមបូឌា) និង ភ្នាក់ងារធានារ៉ាប់រង ធនាគារ អេស៊ីលីដា ភីអិលស៊ី[2] ។

តើគោលការណ៍នៃការធានារ៉ាប់រងមានរបបគតិយុត្តយ៉ាងដូចម្តេច ?

ការស្រាវជ្រាវនេះបានធ្វើឡើងដោយពឹងផ្អែកលើលិខិតបទដ្ឋានគតិយុត្តិផ្សេងៗដែលពាក់ព័ន្ធ និង សៀវភៅរបាយការណ៍ប្រចាំឆ្នាំរបស់នាយកដ្ឋានធានារ៉ាប់រង និង សោធន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ យើងខ្ញុំបានដាក់លិខិតអនុញ្ញាតចុះកម្មសិក្សាទៅក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត មេនូឡាយហ្វ៍ ប៉ុន្តែក្រុមហ៊ុនធានារ៉ាប់រងនេះពុំបានធ្វើការឆ្លើយតបទៅនឹងសំណើរបស់យើងខ្ញុំនោះ ទេ ។ ដំណើរការនៃការប្រមូលឯកសារភាគច្រើន បណ្ណាល័យ តូបសៀវភៅ និង តាមបណ្តាគេហទំព័រ របស់នាយកដ្ឋានធានារ៉ាប់រងនិងសោធននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រុមហ៊ុនធានារ៉ាប់រង មួយចំនួន ។ លើសពីនេះ យើងខ្ញុំបានទៅជួបជាមួយអតិថិជនផ្ទាល់របស់ក្រុមហ៊ុនធានារ៉ាប់រង ព្រូដិនសល និង មេនូឡាយហ្វ៍ ដើម្បីសុំឯកសារខ្លះៗដែលពាក់ព័ន្ធនឹងការធានារ៉ាប់រង ។

សារណានេះបែងចែកជាពីរជំពូក ។ ជំពូកទី១ បកស្រាយអំពីចំណាត់ថ្នាក់នៃការធានា រ៉ាប់រង ដែលក្នុងនោះផ្តោតសំខាន់ទៅលើ ការធានារ៉ាប់រងទូទៅ និង ការធានារ៉ាប់រងអាយុជីវិត ។ ជំពូកទី២ បកស្រាយអំពី កិច្ចសន្យាធានារ៉ាប់រង ក្នុងនោះធ្វើការលើកឡើងអំពី ការបង្កើត អានុភាព និងការបញ្ចប់នៃកិច្ចសន្យាធានារ៉ាប់រង ។

[2] ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ , អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ , នាយកដ្ឋានធានារ៉ាប់រងនិងសោធន , របាយការណ៍ប្រចាំឆ្នាំ ២០១៣ , ទំព័រ ១៩ ២០ និង ២១

# ជំពូកទី១ ៖ ចំណាត់ថ្នាក់នៃការធានារ៉ាប់រង

អាជីវកម្មធានារ៉ាប់រងមានការបែងចែកជាពីរចំណាត់ថ្នាក់សំខាន់ៗ ។ មុននឹងឈានចូលទៅដល់ការធ្វើចំណាត់ថ្នាក់ធានារ៉ាប់រង យើងគួរយល់អំពីអត្ថន័យនៃការធានារ៉ាប់រងជាមុនសិន ។ ការធានារ៉ាប់រង សំដៅដល់ការធ្វើកិច្ចសន្យាធានារ៉ាប់រងដែលក្នុងនោះ អ្នកត្រូវបានធានារ៉ាប់រងត្រូវបង់បុព្វលាភធានារ៉ាប់រងទៅអោយក្រុមហ៊ុនធានារ៉ាប់រងត្រូវធ្វើសំណងដល់ការខូចខាត ឬ ការបាត់បង់ទ្រព្យសម្បត្តិដែលបង្កឡើងដោយហេតុការណ៍គ្រោះថ្នាក់ ឬ ក៏ធ្វើសំណងនៅពេលដែលអ្នកត្រូវបានធានារ៉ាប់រងស្លាប់ របួស ពិការ មានជម្ងឺ ឬ នៅពេលដែលបុគ្គលនោះ ឈានដល់កាលកំណត់ណាមួយដែលភាគីទាំងពីរបានព្រមព្រៀងគ្នា ដូចមានចែងក្នុងកិច្ចសន្យាធានារ៉ាប់រង[3] ។ លើសពីនេះ ការធានារ៉ាប់រងនេះ អ្នកត្រូវបានធានារ៉ាប់រងតែងតែជួបប្រទះនូវហានិភ័យជាច្រើន ដោយហានិភ័យខ្លះទៀតមិនអាចត្រូវទទួលបានធានារ៉ាប់រងទេតែទោះជាយ៉ាងណាក្តី អ្នកត្រូវធានារ៉ាប់រងក៏ទទួលបាននូវផលប្រយោជន៍មួយចំនួនផងដែរពីការធានារ៉ាប់រងនេះ ។

ការធានារ៉ាប់រងត្រូវបានបែងចែកចំណាត់ថ្នាក់ជាពីរធំៗ គឺការធានារ៉ាប់រងទូទៅ និង ការធានារ៉ាប់រងអាយុជីវិត ។ នៅក្នុងការធានារ៉ាប់រងទូទៅ មានដូចជា ការធានារ៉ាប់រងទ្រព្យសម្បត្តិ ការធានារ៉ាប់រងភារៈទទួលខុសត្រូវ និង ការធានារ៉ាប់រងសុខភាព ។ រីឯការធានារ៉ាប់រងអាយុជីវិតមានដូចជា ការធានារ៉ាប់រងអាយុជីវិតមានកាលកំណត់ ការធានារ៉ាប់រងមួយជីវិតកាល ការធានារ៉ាប់រងទាយជ្ជទាន និង ការធានារ៉ាប់រងធនលាភ ។

## ១.១. ការធានារ៉ាប់រងទូទៅ

មាត្រា ២៣ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការធានារ៉ាប់រង ឆ្នាំ២០១៤ បានកំណត់និយមន័យនៃការធានារ៉ាប់រងទូទៅថា ជាកិច្ចសន្យាធានារ៉ាប់រងដែលធ្វើឡើងរវាងអ្នកត្រូវបានធានារ៉ាប់រង និង ក្រុមហ៊ុនធានារ៉ាប់រង ដែលក្នុងនោះការបង់បុព្វលាភធានារ៉ាប់រងត្រូវធ្វើឡើងដើម្បីធានាហានិភ័យលើទ្រព្យសម្បត្តិ ភារៈទទួលខុសត្រូវ និង សុខភាព ។ ប្រភេទផលិតផលធានារ៉ាប់រងទូទៅរួមមាន ការធានារ៉ាប់រងទ្រព្យសម្បត្តិ ការធានារ៉ាប់រងភារៈទទួលខុសត្រូវ និង ការធានារ៉ាប់រងសុខភាព ។

### ១.១.១. ការធានារ៉ាប់រងទ្រព្យសម្បត្តិ

ការធានារ៉ាប់រងទ្រព្យសម្បត្តិ ជាកិច្ចសន្យាធានារ៉ាប់រងដែលធ្វើសំណងដល់អ្នកត្រូវបានធានារ៉ាប់រងនៅពេលដែលទ្រព្យសម្បត្តិរបស់បុគ្គលនោះបានខូចខាត បាត់បង់ ឬ អន្តរាយដោយសារ

[3] មាត្រា ៩ នៃច្បាប់ស្តីពីការធានារ៉ាប់រង, ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៤

ហានិភ័យដែលត្រូវបានធានា ។ សំណងដែលត្រូវផ្តល់ដោយក្រុមហ៊ុនធានារ៉ាប់រងទៅអោយអ្នកត្រូវបានធានារ៉ាប់រង មិនអាចមានតម្លៃលើសពីវត្ថុដែលបានធ្វើប្រតិវេទន៍ នៅពេលចុះកិច្ចសន្យាធានារ៉ាប់រងឡើយ លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះ ។ ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការធានារ៉ាប់រងទ្រព្យសម្បត្តិដូចជា អគារ នាវា ជាដើម[4] ។ លើសពីនេះ បើកម្មវត្ថុទ្រព្យសម្បត្តិនោះខូចខាតទាំងស្រុង ដែលបណ្តាលមកពីគ្រោះថ្នាក់ដែលបណ្តាលមកពីហេតុការណ៍ ឬ សម្មភាពណាមួយដែលពុំបានគ្រោងទុកជាមុនក្នុងបណ្ណសន្យារ៉ាប់រងទេ ការធានារ៉ាប់រងត្រូវបញ្ចប់ដោយស្របច្បាប់ ហើយក្រុមហ៊ុនធានារ៉ាប់រងត្រូវសងទៅឱ្យអ្នកត្រូវបានធានារ៉ាប់រងវិញចំនួន ៩០% នៃបុព្វលាភចំពោះរយៈពេលដែលនៅសល់[5] ។ នៅក្នុងករណីដែលតតិយជនបានបង្កការខូចខាតដល់ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការធានារ៉ាបរង ក្រុមហ៊ុនធានារ៉ាប់រងត្រូវធ្វើសំណងទៅឱ្យអ្នកត្រូវបានធានារ៉ាប់រងបន្ទាប់មក អ្នកត្រូវបានធានារ៉ាប់រងត្រូវផ្ទេរសិទ្ធិទៅឱ្យក្រុមហ៊ុនធានារ៉ាប់រង ក្នុងការប្តឹងតទល់ជាមួយនឹងតតិយជននោះដើម្បីទាមទារមកវិញនូវទឹកប្រាក់ស្មើនឹងចំនួនដែលបានធ្វើសំណងនោះ ប៉ុន្តែក្រុមហ៊ុនធានារ៉ាប់រងមិនអាចប្តឹងទាមទារសំណងពីបច្ឆាញាតិ បុព្វញាតិ ញាតិពន្ធ អ្នកគ្រប់គ្រង និងកម្មករនិយោជិតដែលរស់នៅធម្មតាក្នុងលំនៅឋានរបស់អ្នកត្រូវបានធានារ៉ាប់រងទេ លើកលែងតែករណីដែលមានភស្តុតាងបញ្ជាក់ថា មានការប្រព្រឹត្តកំហុសធ្ងន់ធ្ងរដោយចេតនាដោយជនណាម្នាក់ក្នុងចំណោមជនទាំងនោះ[6] ។

នៅក្នុងការប្រតិបត្តិសព្វថ្ងៃ ក្រុមហ៊ុនធានារ៉ាប់រង ហ្វតតេ (កម្ពុជា) ភីអិលស៊ី មានផលិតផលនៃការធានារ៉ាប់រងទ្រព្យសម្បត្តិមួយឈ្មោះថា សេវាធានារ៉ាប់រងគ្រោះអគ្គីភ័យ (Fire Insurance) ។ សេវាធានារ៉ាប់រងគ្រោះអគ្គីភ័យ គឺជាសេវាដែលជួយការពារទ្រព្យសម្បត្តិរបស់អ្នកត្រូវបានធានារ៉ាប់រង ដូចជា លំនៅដ្ឋាន ឬ កន្លែងប្រកបអាជីវកម្មពីការបាត់បង់ ឬ ខូចខាតក្នុងករណីអគ្គីភ័យឆាបឆេះ រន្ទះ និង គ្រោះទឹកជំនន់ជាដើម ។ មិនតែប៉ុណ្ណោះ សេវាធានារ៉ាប់រងនេះអាចការពារទ្រព្យសម្បត្តិ ដូចជា ការខូចខាតដោយសារអគ្គីភ័យ បាតុភូតរន្ទះ ឬ ឧបទ្ទវហេតុផ្សេងៗទៀតដូចជាការផ្ទុះ រញ្ជួយដី បាតុកម្ម កុបកម្ម និង ការខូចខាតដោយសារគំនុំ ទឹកជំនន់ការខូចខាតដោយការប៉ះពាល់ពីយានយន្ត ផលប៉ះពាល់ដោយយន្តហោះធ្លាក់ ការផ្ទុះបំពង់ទឹកជាដើម[7] ។

---

[4] មាត្រា ២៣ កថាខណ្ឌទី២ នៃច្បាប់ស្តីពីការធានារ៉ាប់រង, ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៤

[5] មាត្រា ២៤ នៃច្បាប់ដដែល

[6] មាត្រា ២៥ នៃច្បាប់ដដែល

[7] ខិត្តបណ្ណផលិតផលអំពីសេវាធានារ៉ាប់រងគ្រោះអគ្គិភ័យ របស់ក្រុមហ៊ុន ហ្វតតេ

### ១.១.២. ការធានារ៉ាប់រងភារៈទទួលខុសត្រូវ

ការធានារ៉ាប់រងភារៈទទួលខុសត្រូវ ជាកិច្ចសន្យាធានារ៉ាប់រងលើទឹកប្រាក់សំណងដែលអ្នកធានារ៉ាប់រងមានកាតព្វកិច្ចបង់ឱ្យតតិយជនដែលទទួលរងរបួសលើរូបរាងកាយ ឬ អាយុជីវិត ឬ ទទួលរងការខូចខាតលើទ្រព្យសម្បត្តិ ដោយសារទង្វើរបស់អ្នកត្រូវបានធានារ៉ាប់រង ឬ សកម្មភាពដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់អ្នកត្រូវបានធានារ៉ាប់រង ។ ប្រភេទផលិតផលធានារ៉ាប់រងភារៈទទួលខុសត្រូវរួមមាន ការធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្ត ការធានារ៉ាប់រងភារៈទទួលខុសត្រូវលើការដ្ឋាន និង ការធានារ៉ាប់រងភារៈទទួលខុសត្រូវដឹកជញ្ជូនអ្នកដំណើរ[8] ។

#### ១.១.២.១. ការធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្ត

បុគ្គលទាំងឡាយជាម្ចាស់យានយន្តដែលប្រកបអាជីវកម្មក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវមានការធានារ៉ាប់រងយានយន្តរបស់ខ្លួនពីក្រុមហ៊ុនធានារ៉ាប់រងណាមួយលើភារៈទទួលខុសត្រូវចំពោះរាល់ការខូចខាតបង្កឡើងដល់តតិយជន ដែលបណ្តាលមកពីសកម្មភាពនៃយានយន្តរបស់ខ្លួន រួមទាំងរ៉ឺម៉កសណ្តោងគ្រប់ប្រភេទ ។ ការធានារ៉ាប់រងនេះមិនត្រឹមតែមានប្រសិទ្ធិភាពចំពោះម្ចាស់យានយន្តប៉ុណ្ណោះទេ ប៉ុន្តែត្រូវមានប្រសិទ្ធិភាពផងដែរចំពោះអ្នកបើកបរ និង អ្នកកាន់កាប់ថែទាំយានយន្ត[9] ។ ករណីបុគ្គលជាម្ចាស់យានយន្តដែលច្បាប់តម្រូវឱ្យមានការធានារ៉ាប់រងជាកាតព្វកិច្ចមិនបានទិញការធានារ៉ាប់រងលើយានយន្ត ហើយដែលយានយន្តត្រូវបានធ្វើចរាចរណ៍នៅលើផ្លូវថ្នល់សាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១៥ ០០០ ( ដប់ប្រាំពាន់ ) រៀល ទៅ ១ ៥០០ ០០០ ( មួយលានប្រាំសែន ) រៀល និង តម្រូវឱ្យមានការធានារ៉ាប់រង[10] ។

ប្រភេទយានយន្តដែលត្រូវបំពេញកាតព្វកិច្ចធានារ៉ាប់រងតតិយជន សម្រាប់គ្រោះថ្នាក់ដែលកើតឡើងក្នុងព្រះរាជាណាចក្រកម្ពុជា រួមមាន ៖ យានយន្តគ្រប់ប្រភេទដែលធ្វើអាជីវកម្មដឹកជញ្ជូនទំនិញ ដឹកជញ្ជូនអ្នកដំណើរ ដឹកជញ្ជូនភ្ញៀវទេសចរនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ យានយន្តគ្រប់ប្រភេទដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុន សហគ្រាស រោងចក្រ ។ យានយន្តរបស់អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ និង សមាគមនានា ។ ឧបករណ៍លាយស៊ីម៉ង់ត៍ ដែលធ្វើចលនាផ្លាស់ប្តូរទីកន្លែងដោយម៉ាស៊ីនផ្ទាល់ ឬ ដោយអូសសណ្តោង ។ ត្រីចក្រយានយន្តដែលប្រើប្រាស់សម្រាប់

[8] មាត្រា ២៣ កថាខណ្ឌទី ៣ នៃច្បាប់ស្តីពីការធានារ៉ាប់រង, ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៤

[9] មាត្រា ៣៣ នៃច្បាប់ដដែល

[10] មាត្រា ៩៧ កថាខណ្ឌទី ១ នៃច្បាប់ដដែល

ធ្វើអាជីវកម្មដឹកជញ្ជូនទំនិញ ឬ ដឹកជញ្ជូនអ្នកដំណើរ[11] ។

នៅពេលដែលមានគ្រោះថ្នាក់កើតឡើង ភាគីទាំងអស់ដែលពាក់ព័ន្ធក្នុងគ្រោះថ្នាក់ ត្រូវធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរ ផ្ញើជូនក្រុមហ៊ុនធានារ៉ាប់រង ដែលបញ្ជាក់ពីមូលហេតុនៃគ្រោះថ្នាក់ចរាចរនេះ ។ បើគ្មានការព្រមព្រៀងគ្នាទេ ភាគីទាំងអស់ត្រូវទាក់ទងអោយមានអន្តរាគមន៍ពីនគរបាលចរាចររាជធានី-ខេត្ត ដើម្បីធ្វើកំណត់ហេតុអង្កេតគ្រោះថ្នាក់ចរាចរ ។ នគរបាលរាជធានី-ខេត្ត ត្រូវកសាងកំណត់ហេតុអង្កេតគ្រោះថ្នាក់ ត្រួតពិនិត្យ និង ធ្វើប្លង់កន្លែងកើតហេតុអោយបានត្រឹមត្រូវ ហើយផ្ញើមកក្រុមហ៊ុនធានារ៉ាប់រង ក្នុងអំឡុងពេល៤៨ម៉ោង គិតចាប់ពីពេលអង្កេតគ្រោះថ្នាក់ដើម្បីអោយក្រុមហ៊ុនធានារ៉ាប់រងមានមូលដ្ឋានសម្រាប់គិតគូរធ្វើសំណងដល់ការខូចខាតទាំងឡាយដែលពាក់ព័ន្ធនឹងបណ្ណសន្យារ៉ាប់រង ។ ក្នុងអំឡុងពេល៥ថ្ងៃគិតចាប់ពីថ្ងៃកើតមានគ្រោះថ្នាក់ចរាចរម្ចាស់យាន្តយន្ត ឬ អ្នកបើកបរត្រូវបញ្ជាក់ជាលាយលក្ខណ៍អក្សរអំពីការទាមទារសំណងមកក្រុមហ៊ុនធានារ៉ាប់រង[12] ។ នៅតំបន់ដាច់ស្រយាលដែលគ្មាននគរបាលចរាចរជើងគោកឈរជើងទេនោះម្ចាស់យានយន្ត ឬ អ្នកបើកបរត្រូវទាក់ទងជាមួយអាជ្ញាធរមានសមត្ថកិច្ចដែនដី ដើម្បីបញ្ជាក់លើរបាយការណ៍គ្រោះថ្នាក់ ។ ក្នុងករណីដែលយានយន្តមានគ្រោះថ្នាក់ត្រូវបានឃុំឃាំងទុកដោយនគរបាលចរាចរ យាន្តយន្តនោះត្រូវបានដោះលែងបន្ទាប់ពីបានទទួលនូវលិខិតជាផ្លូវការពីអ្នកធានារ៉ាប់រង ដែលមានការអនុញ្ញាតអោយធ្វើអាជីវកម្មធានារ៉ាប់រង នៅក្នុងព្រះរាជាណាចក្រកម្ពុជា ចំពោះយានយន្តដែលមានកាតព្វកិច្ចធានារ៉ាប់រង[13] ។ ក្រុមហ៊ុនធានារ៉ាប់រងត្រូវដោះស្រាយរាល់សំណងជូនជនរងគ្រោះជំនួសម្ចាស់យានយន្ត ឬ អ្នកបើកបរ ដែលមានការធានារ៉ាប់រងក្នុងរយៈពេល ១០ ថ្ងៃយ៉ាងយូរ ក្រោយពេលដែលទទួលសំណុំលិខិតគ្រោះថ្នាក់ចរាចរគ្រប់គ្រាន់រួចហើយរួមទាំងរបាយ-ការណ៍នគរបាលចរាចរដែរ លើកលែងតែក្រុមហ៊ុនធានារ៉ាប់រងយល់ឃើញថា សំណងនេះគ្មាននៅក្នុងលក្ខខណ្ឌនៃកិច្ចព្រមព្រៀងធានារ៉ាប់រង ឬ សំណងមានច្រើនហួសហេតុ[14] ។

ចំពោះតតិយជនទាំងឡាយដែលបានទទួលរងគ្រោះដល់រូបរាងកាយ និង/ឬ មរណភាពដោយសារយានយន្តដែលមានការធានារ៉ាប់រងបង្កឡើង ក្រុមហ៊ុនធានារ៉ាប់រង ត្រូវធ្វើសំណងចំពោះរាល់ការខូចខាតអន្តរាយនោះឱ្យបានទាន់ពេលវេលាដែល និង សមស្របតាមកម្រិតនៃការខូចខាត ។ ចំនួនទឹកប្រាក់កាតព្វកិច្ចធានារ៉ាប់រងអប្បបរមាដែលត្រូវបានកម្រិតចំពោះភារៈទទួលខុសត្រូវលើ

---

[11] ប្រការ ២ នៃប្រកាសអន្តរក្រសួងស្តីពីកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្ត ឬ ធានារ៉ាប់រងតតិយជន, ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០២

[12] ប្រការ ៩ កថាខណ្ឌទី២ វាក្យខណ្ឌទី ២ នៃប្រកាសដដែល

[13] ប្រការ ៨ នៃប្រកាសដដែល

[14] ប្រការ ៧ កថាខណ្ឌទី ២ នៃប្រកាសដដែល

យានយន្ត ឬ ធានារ៉ាប់រងតតិយជនត្រូវកំណត់មានយានយន្តដែលមានកង់បួន ឬ ច្រើនជាងបួន និងយានយន្តដែលមានកង់តិចជាងបួន ។ ចំពោះយានយន្តដែលមានកង់បួន ឬ ច្រើនជាងបួន ទឹកប្រាក់ ៥ ០០០ ដុល្លារអាមេរិក សម្រាប់របួសរាងកាយ ឬ ស្លាប់ក្នុងមនុស្សម្នាក់ ។ ២៥ ០០០ ដុល្លារអាមេរិក សម្រាប់របួសរាងកាយ ឬ ស្លាប់ក្នុងគ្រោះថ្នាក់មួយករណី ។ ១០ ០០០ ដុល្លារអាមេរិក សម្រាប់ខូចខាតទ្រព្យសម្បត្តិ ។ រីឯចំពោះយានយន្តដែលមានកង់តិចជាងបួន ទឹកប្រាក់ ៥ ០០០ ដុល្លារអាមេរិក សម្រាប់របួសរាងកាយ ឬ ស្លាប់ក្នុងមនុស្សម្នាក់ ។ ១២ ៥០០ ដុល្លារអាមេរិក សម្រាប់របួសរាងកាយ ឬ ស្លាប់ក្នុងគ្រោះថ្នាក់មួយករណី ។ ៥ ០០០ ដុល្លារអាមេរិក សម្រាប់ខូចខាតទ្រព្យសម្បត្តិ[15] ។

ជាក់ស្តែងក្នុងប្រតិបត្តិការធានារ៉ាប់រង ក្រុមហ៊ុនធានារ៉ាប់រង ហ្វតតេ (កម្ពុជា) ភីអិលស៊ី មានផលិតផលនៃការធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្តមួយឈ្មោះថា សេវាធានារ៉ាប់រងយានយន្ត ។ សេវាធានារ៉ាប់រងយានយន្ត គឺជាសេវាដែលធានារ៉ាប់រងទៅលើយានយន្តរបស់អ្នកត្រូវបានធានារ៉ាប់រង ក្នុងករណីជួបគ្រោះថ្នាក់ចរាចរណ៍ ចោរកម្ម ឬ អគ្គីភ័យឆាបឆេះជាដើម ។ ប្រភេទនៃការធានារ៉ាប់រងយានយន្តនេះមានពីរយ៉ាងគឺ ការធានារ៉ាប់រងជាមូលដ្ឋាន និង សេវាធានារ៉ាប់រងគ្រប់ហានិភ័យ ។ ការធានារ៉ាប់រងជាមូលដ្ឋាន គឺជាការធានាទទួលខុសត្រូវចំពោះតតិយជន ជួយការពារអ្នកត្រូវបានធានារ៉ាប់រងក្នុងករណីបង្កគ្រោះថ្នាក់បណ្តាលអោយរបួសរាងកាយអ្នកដទៃ ឬ ខូចខាតរថយន្តអ្នកដទៃ ឬ ទ្រព្យសម្បត្តិផ្សេងៗទៀតអំឡុងពេលបើកបរ ។ រីឯសេវាធានារ៉ាប់រងគ្រប់ហានិភ័យ គឺជាសេវាដែលផ្តល់ជូននូវការធានាកម្រិតអតិបរមា ក្នុងករណីយានយន្តរបស់អ្នកត្រូវបានធានារ៉ាប់រង ត្រូវចោរលួច ឬ ខូចខាតដោយចៃដន្យជាដើម ក៏ដូចជាការពារអ្នកត្រូវបានធានារ៉ាប់រងពីការទាមទារសំណងដោយភាគីដទៃផងដែរ ។ ជាងនេះទៅទៀត សេវានេះអាចធានាទៅលើការទទួលខុសត្រូវចំពោះអ្នករួមដំណើរ ករណីចោរលួច អគ្គីភ័យឆាបឆេះ បាតុកម្ម កុបកម្ម ចលាចលសង្គម និង ខូចខាតដោយទឹកជំនន់ផងដែរ[16] ។

### ១.១.២.២. ការធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន

រូបវន្តបុគ្គល ឬ នីតិបុគ្គលទាំងឡាយដែលជាម្ចាស់ការដ្ឋាន ត្រូវមានការធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន ។ នៅពេលបើកការដ្ឋាន បុគ្គលជាម្ចាស់ការដ្ឋានត្រូវមានភស្តុតាងបញ្ជាក់ថាខ្លួនបានចុះកិច្ចសន្យាធានារ៉ាប់រងជាមួយក្រុមហ៊ុនធានារ៉ាប់រងណាមួយរួចហើយ[17] ។ យោងតាម

[15] ប្រការ ៣ នៃប្រកាសអន្តរក្រសួងស្តីពីកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្ត ឬ ធានារ៉ាប់រងតតិយជន, ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០២

[16] ខិត្តបណ្ណផលិតផលអំពីសេវាធានារ៉ាប់រងយានយន្តរបស់ក្រុមហ៊ុន ហ្វតតេ

[17] មាត្រា ៣៧ នៃច្បាប់ស្តីពីការធានារ៉ាប់រង, ចុះថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០១៤

ប្រការ ៦ នៃប្រកាសអន្តរក្រសួងស្តីពីកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន ចែងថា នៅពេលសុំបើកការដ្ឋាន ម្ចាស់សំណង់ត្រូវបង្ហាញឯកសារធានារ៉ាប់រងថាបានចុះកិច្ចសន្យាធានារ៉ាប់រងជាមួយក្រុមហ៊ុនធានារ៉ាប់រងណាមួយដែលមានអាជ្ញាប័ណ្ណត្រឹមត្រូវនៅព្រះរាជាណាចក្រកម្ពុជារួចហើយ ។ បើសំណុំឯកសារពុំមានភ្ជាប់ជាមួយនូវកំណត់សំអាង ឬ វិញ្ញាបនបត្រធានារ៉ាប់រងទេ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ ឬ មន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និង សុរិយោដីរាជធានី-ខេត្ត មិនចេញលិខិតអនុញ្ញាតបើកការដ្ឋានឡើយ ។ ពេលការដ្ឋានកំពុងដំណើរការ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ ឬ មន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និង សុរិយោដីរាជធានី-ខេត្ត និង អាជ្ញាធរមានសមត្ថកិច្ចនៅមូលដ្ឋាន មានភារកិច្ចត្រួតពិនិត្យផ្ទាល់ដល់ការដ្ឋាន និង សួររកវិញ្ញាបនបត្រធានារ៉ាប់រង ។ ក្នុងករណីគ្មានវិញ្ញាបនបត្រធានារ៉ាប់រងដែលតម្រូវទេនោះ ក្រុមត្រួតពិនិត្យការដ្ឋាននៅមូលដ្ឋាននោះត្រូវបញ្ឈប់សកម្មភាពការដ្ឋានជាបណ្តោះអាសន្ន ហើយតម្រូវអោយទិញធានារ៉ាប់រង ។ ប្រសិនបើនៅតែមិនព្រមអនុវត្តតាមនឹងត្រូវទទួលរងនូវការពិន័យតាមមាត្រា ៩៧ កថាខណ្ឌទី ២ នៃច្បាប់ស្តីពីការធានារ៉ាប់រង ឆ្នាំ ២០១៤ ។ ក្នុងករណីដែលអ្នកធានារ៉ាប់រងបានលុបចោលការធានារ៉ាប់រង ដោយអ្នកត្រូវបានធានារ៉ាប់រងមិនបានបង់នូវបុព្វលាភរ៉ាប់រង ឬ ដោយការមិនគោរពលក្ខខណ្ឌធានារ៉ាប់រង នោះអ្នកធានារ៉ាប់រងត្រូវជូនដំណឹងពីការលុបចោលធានារ៉ាប់រងនេះ ដល់ក្រសួងរៀបចំដែនដីនគររូបនីយកម្ម និង សំណង់ និង មន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និង សុរិយោដីរាជធានី-ខេត្ត និង អាជ្ញាធរមានសមត្ថកិច្ចនៅមូលដ្ឋាន[18] ។

គ្រប់ការដ្ឋានសាងសង់ ជួសជុល តម្លើងទាំងអស់ ដែលទទួលខុសត្រូវដោយសហគ្រិន អ្នកម៉ៅការ ឬ អ្នកម៉ៅការបន្ត ដែលចាំបាច់ត្រូវមានការធានារ៉ាប់រងលើភារៈទទួលខុសត្រូវការដ្ឋាន ។ ប្រភេទការដ្ឋានដែលត្រូវបានលើកលែងមិនចាំបាច់មានការធានារ៉ាប់រងលើភារៈទទួលខុសត្រូវរួមមាន ៖ ការដ្ឋានសាងសង់ដែលដំណើរការដោយស្ថាប័នរដ្ឋាភិបាល ។ ការដ្ឋានសាងសង់ ជួសជុល តម្លើង ដែលទទួលបន្ទុកដោយនីតិបុគ្គលនៃនីតិសាធារណៈ ដើម្បីផលប្រយោជន៍សាធារណៈ ដែលក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ អះអាងថាមានលទ្ធភាពជួសជុលសាងសង់បានឆាប់រហ័ស និង គ្រប់គ្រាន់សម្រាប់ការខូចខាតទាំងឡាយ ។ ការដ្ឋានសាងសង់ ជួសជុល កែលម្អតូចតាច ដែលមិនតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់[19] ។

---

[18] ប្រការ ៨ នៃប្រកាសអន្តរក្រសួងស្តីពីកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន, ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០២

[19] ប្រការ ២ នៃប្រកាសដដែល

ការធានារ៉ាប់រងលើភារៈទទួលខុសត្រូវលើការដ្ឋាន មានសារៈសំខាន់ក្នុងកិច្ចការពារផលប្រយោជន៍របស់តតិយជនទាំងឡាយដែលរស់នៅក្នុង ឬ ជុំវិញការដ្ឋាន ឬ ធ្វើដំណើរឆ្លងកាត់ ឬក្បែរការដ្ឋាន ។ រាល់បុគ្គលដែលជាម្ចាស់ការដ្ឋាន អ្នកម៉ៅការ អ្នកម៉ៅការបន្ត មាន ភារៈទទួលខុសត្រូវចំពោះគ្រោះថ្នាក់ទាំងឡាយ ទោះបីលើរូបរាងកាយក្តី ឬ ស្លាប់ក្តី ឬ ទ្រព្យសម្បត្តិក្តី របស់តតិយជនដែលបង្កឡើងដោយសកម្មភាពរបស់ការដ្ឋាន[20] ។ ចំនួនទឹកប្រាក់កាតព្វកិច្ចអប្បបរមាដែលត្រូវបានកម្រិតសម្រាប់ភារៈទទួលខុសត្រូវការដ្ឋានត្រូវកំណត់មាន ៥ ០០០ ដុល្លារអាមេរិកសម្រាប់របួសរាងកាយ ឬ ស្លាប់ក្នុងមនុស្សម្នាក់ ។ ២៥ ០០០ ដុល្លារអាមេរិក សម្រាប់របួសរាងកាយ ឬ ស្លាប់ក្នុងគ្រោះថ្នាក់មួយករណី ។ ១០ ០០០ ដុល្លារអាមេរិច សំរាប់ការខូចខាតទ្រព្យសម្បត្តិ[21] ។

### ១.១.២.៣. ការធានារ៉ាប់រងភារៈទទួលខុសត្រូវការដឹកជញ្ជូនអ្នកដំណើរ

រាល់បុគ្គលទាំងឡាយដែលប្រកបអាជីវកម្មដឹកជញ្ជូនអ្នកដំណើរតាមមធ្យោបាយដឹកជញ្ជូននានា ត្រូវមានការធានារ៉ាប់រងភារៈទទួលខុសត្រូវចំពោះអ្នកដំណើរដែលជិះតាមមធ្យោបាយដឹកជញ្ជូនរបស់ខ្លួនទោះបីជាមធ្យាបាយដឹកជញ្ជូនទាំងនោះចរាចរតាមផ្លូវគោក ផ្លូវទឹក ផ្លូវអាកាស ឬ ផ្លូវដែកក៏ដោយ ។ ការធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើររួមទាំងភ្ញៀវទេសចរ មានសារៈសំខាន់ដើម្បីការពារសិទ្ធិ និង ផលប្រយោជន៍របស់អ្នកដំណើរ ចំពោះរាល់គ្រោះថ្នាក់ដែលកើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ រូបវន្តបុគ្គលដែលជាម្ចាស់ ឬ ជាប្រតិបត្តិករមធ្យោបាយដឹកជញ្ជូនអ្នកដំណើរតាមផ្លូវគោក ផ្លូវសមុទ្រ ផ្លូវទន្លេ ចាំបាច់ត្រូវអនុវត្តតាមបទដ្ឋានបច្ចេកទេស និង ចំណុះផ្ទុករបស់គ្រប់មធ្យាបាយធ្វើអាជីវកម្មដឹកជញ្ជូនអ្នកដំណើរ[22] ។ ករណីបុគ្គលដែលប្រកបអាជីវកម្មដឹកជញ្ជូនអ្នកដំណើរតាមមធ្យោបាយដឹកជញ្ជូននានា មិនមានការធានារ៉ាប់រងភារៈទទួលខុសត្រូវចំពោះអ្នកដំណើរដែលជិះតាមមធ្យោបាយរបស់ខ្លួន ត្រូវពិន័យតាមមាត្រា ៩៧ កថាខណ្ឌទី ៣ នៃច្បាប់ស្តីពីការធានារ៉ាប់រង ឆ្នាំ ២០១៤ ។ នៅពេលផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូន ឬ លិខិតអនុញ្ញាតបន្តធ្វើអាជីវកម្មដឹកជញ្ជូនអ្នកដំណើរដល់ម្ចាស់ ឬ ប្រតិបត្តិករមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ ក្រសួងសាធារណការ និង ដឹកជញ្ជូន ត្រូវតម្រូវអោយម្ចាស់ ឬ ប្រតិបត្តិករមធ្យោបាយដឹកជញ្ជូនបង្ហាញនូវឯកសារកាតព្វកិច្ចធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរ ។ ប្រសិនបើម្ចាស់ ឬប្រតិបត្តិករខកខានមិនបានទិញធានារ៉ាប់រងកាតព្វកិច្ចទេនោះ អាជ្ញាធរមានសមត្ថកិច្ចដូចបានពោលខាងលើ ត្រូវដកហូតលិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូន និងវិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈ

[20] ប្រការ ១ នៃប្រកាសអន្តរក្រសួងស្តីពីកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន, ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០២

[21] ប្រការ ៣ នៃ ប្រកាសដដែល

[22] ប្រការ ១ នៃប្រកាសអន្តរក្រសួងស្តីពីកាតព្វកិច្ចធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរ, ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០២

បច្ចេកទេសជាបណ្តោះអាសន្នរហូតដល់ម្ចាស់ ឬ ប្រតិបត្តិករ បានផ្តល់ឯកសារកាតព្វកិច្ចធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរត្រឹមត្រូវតាមការកំណត់[23] ។

នៅពេលមានគ្រោះថ្នាក់កើតឡើងពាក់ព័ន្ធនឹងអ្នកដំណើរនៅពេលឡើងជិះ ពេលកំពុងជិះ ក៏ដូចពេលចុះពីមធ្យោបាយធ្វើដំណើរដែលមានការធានារ៉ាប់រង ប្រតិបត្តិករមធ្យោបាយធ្វើដំណើរត្រូវរិះរកគ្រប់វិធីដើម្បីជួយសង្គ្រោះជនរងគ្រោះភ្លាមៗ ទន្ទឹមនឹងនោះ ត្រូវរាយការណ៍ទៅក្រុមហ៊ុនធានារ៉ាប់រងរបស់ខ្លួនជាបន្ទាន់[24] ។ ម្ចាស់មធ្យោបាយដឹកជញ្ជូនអ្នកដំណើរ ត្រូវបានក្រុមហ៊ុនធានារ៉ាប់រងចេញប្រាក់សំណងជំនួសជូនដល់ជនរងគ្រោះទៅតាមកម្រិតទទួលខុសត្រូវ ដែលបានព្រមព្រៀងគ្នាក្នុងកិច្ចសន្យា ឬ ក្នុងកំណត់សំអាង ។ សំណងត្រូវតែដោះស្រាយអោយបានក្នុងរយៈពេល ១០ ថ្ងៃយ៉ាងយូរ ក្រោយពេលដែលបានទទួលសំណុំលិខិតគ្រោះថ្នាក់ចរាចរគ្រប់គ្រាន់រួចហើយ រួមទាំងរបាយការណ៍នគរបាលចរាចរផងដែរ លើកលែងតែក្រុមហ៊ុនធានារ៉ាប់រងយល់ឃើញថាសំណងនេះគ្មាននៅក្នុងលក្ខខណ្ឌនៃកិច្ចព្រមព្រៀងធានារ៉ាប់រង ឬ សំណងមានច្រើនហួសហេតុ[25] ។ ចំនួនទឹកប្រាក់កាតព្វកិច្ចធានារ៉ាប់រងអប្បបរមាដែលត្រូវបានកម្រិតសម្រាប់ការដឹកជញ្ជូនអ្នកដំណើរត្រូវកំណត់មានដូចជា ៖ ៥ ០០០ ដុល្លាអាមេរិកសម្រាប់របួសរាងកាយ ឬ ស្លាប់ក្នុងមនុស្សម្នាក់ ។ ៥០ ០០០ ដុល្លាអាមេរិកសម្រាប់របួសរាងកាយ ឬ ស្លាប់ក្នុងគ្រោះថ្នាក់មួយករណី ។ ១ ០០០ ដុល្លារអាមេរិកសម្រាប់ខូចខាតទ្រព្យសម្បត្តិ ។ ១០០ ០០០ ដុល្លាអាមេរិកសម្រាប់របួសរាងកាយ ឬ ស្លាប់ក្នុងគ្រោះថ្នាក់មួយករណីចំពោះម្ចាស់មធ្យោបាយដឹកជញ្ជូនណាដែលដឹកអ្នកដំណើរមានចំនួន ១០ នាក់ ឬ លើសពី ១០នាក់ ។ ២៥០ ០០០ ដុល្លាអាមេរិកសម្រាប់របួសរាងកាយ ឬស្លាប់ក្នុងគ្រោះថ្នាក់មួយករណីចំពោះម្ចាស់មធ្យោបាយជញ្ជូនណាដែលដឹកអ្នកដំណើរមានចំនួន ៥០នាក់ ឬ លើស ៥០ នាក់ ។

នៅក្នុងការប្រតិបត្តិសព្វថ្ងៃ ក្រុមហ៊ុនធានារ៉ាប់រង កាមិនកូ មានផលិតផលនៃការធានារ៉ាប់រងភារៈទទួលខុសត្រូវដឹកជញ្ជូនអ្នកដំណើរមួយឈ្មោះថា សេវាធានារ៉ាប់រងគ្រោះថ្នាក់លើការធ្វើដំណើរនៅទូទាំងពិភពលោក ។ សេវាធានារ៉ាប់រងគ្រោះថ្នាក់លើការធ្វើដំណើរនៅទូទាំងពិភពលោក រួមមានការធានារ៉ាប់រងគ្រោះថ្នាក់លើការធ្វើដំណើរក្រៅប្រទេស និង ការធានារ៉ាប់រងគ្រោះថ្នាក់លើការធ្វើដំណើរក្នុងប្រទេស ។ ការធានារ៉ាប់រងគ្រោះថ្នាក់លើការធ្វើដំណើរក្រៅប្រទេស គឺជាការធានារ៉ាប់រងលើរបួសរូបរាងកាយដែលបណ្តាលមកពីគ្រោះថ្នាក់ដោយចៃដន្យ ឬ ជម្ងឺដែលទើបនឹងកើតឡើង និង

[23] ប្រការ ៧ នៃប្រកាសអន្តរក្រសួងស្តីពីកាតព្វកិច្ចធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរ, ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០២

[24] ប្រការ ៥ នៃប្រកាសដដែល

[25] ប្រការ ៦ នៃប្រកាសដដែល

ការខូចខាតបាត់បង់សម្ភារៈមួយចំនួន ដូចជា ៖ លិខិតឆ្លងដែន អត្តសញ្ញាណប័ណ្ណ អីវ៉ាន់...ខណៈពេលធ្វើដំណើរទៅក្រៅប្រទេសដើម្បីទេសចរណ៍ ឬ អាជីវកម្ម ។ រីឯការធានារ៉ាប់រងគ្រោះថ្នាក់លើការធ្វើដំណើរក្នុងប្រទេស គឺជាការធានារ៉ាប់រងលើរបួសរាងកាយ ពិការភាព ឬ មរណភាពដែលបណ្តាលមកពីគ្រោះថ្នាក់ដោយចៃដន្យខណៈពេលធ្វើដំណើរក្នុងប្រទេស[26] ។

### ១.១.៣. ការធានារ៉ាប់រងសុខភាព

ការធានារ៉ាប់រងសុខភាព ជាកិច្ចសន្យាធានារ៉ាប់រងលើការចំណាយសម្រាប់ការព្យាបាលរបួស ជម្ងឺ ឬ ការចំណាយផ្សេងៗ ដូចជាការចំណាយសម្រាប់ការថែរក្សាអ្នកជម្ងឺក្នុងរយៈពេលវែងជាដើម ដល់អ្នកត្រូវបានធានារ៉ាប់រងដែលទទួលរងគ្រោះបណ្តាលមកពីគ្រោះថ្នាក់ទាំងឡាយដល់រូបកាយ ឬ ជម្ងឺផ្សេងៗ[27] ។

នៅក្នុងការប្រតិបត្តិសព្វថ្ងៃ ក្រុមហ៊ុនធានារ៉ាប់រង ហ្វតេ (កម្ពុជា) ភីអិលស៊ី មានផលិតផលនៃការធានារ៉ាប់រងសុខភាពមួយឈ្មោះថា សេវាធានារ៉ាប់រងគាំពារសុខភាពគ្រួសារ ។ សេវាធានារ៉ាប់រងគាំពារសុខភាពគ្រួសារ គឺជាសេវាដែលធានារ៉ាប់រងទៅលើស្ថានភាពសុខភាពរបស់សមាជិកទាំងអស់ក្នុងគ្រួសារដោយមិនកំណត់អាយុ ។ នៅក្នុងនោះ ក្រុមហ៊ុននឹងធ្វើការទូទាត់ចំណាយដោយផ្ទាល់ជាមួយមន្ទីរពេទ្យដៃគូទាំងការព្យាបាលក្នុងប្រទេស និង ក្រៅប្រទេសកម្ពុជា ។ ការព្យាបាលមានដូចជា ការព្យាបាលជម្ងឺក្រៅបន្ទាប់ពីមានគ្រោះថ្នាក់ចៃដន្យ ការព្យាបាលជម្ងឺសម្រាកក្នុងមន្ទីរពេទ្យ ការព្យាបាលមុននិងក្រោយពេលចូលព្យាបាលក្នុងមន្ទីរពេទ្យ ការសម្រាលកូន និង ការព្យាបាលជម្ងឺក្រៅសម្រាប់ការព្យាបាលដោយការវះកាត់ លាងឈាម និង ការព្យាបាលដោយវិទ្យុសកម្ម និង ចាក់គីមី[28] ។

## ១.២. ការធានារ៉ាប់រងអាយុជីវិត

ការធានារ៉ាប់រងអាយុជីវិត ជាកិច្ចសន្យាធានារ៉ាប់រងដែលធ្វើឡើងរវាងអ្នកត្រូវបានធានារ៉ាប់រង និង ក្រុមហ៊ុនធានារ៉ាប់រង ដែលក្នុងនោះ ការបង់បុព្វលាភធានារ៉ាប់រងត្រូវធ្វើឡើងដើម្បីធានាទៅលើការស្លាប់ ឬ ការរស់រានមានជីវិតដោយអាចរួមបញ្ចូលការធានារ៉ាប់រងលើគ្រោះថ្នាក់បុគ្គល ជម្ងឺធ្ងន់ធ្ងរ ឬ ជម្ងឺទូទៅ ។ ប្រភេទផលិតផលធានារ៉ាប់រងអាយុជីវិតមាន ការធានារ៉ាប់រងអាយុជីវិតមានកាលកំណត់ ការធានារ៉ាប់រងមួយជីវិតកាល ការធានារ៉ាប់រងទាយជ្ជទាន ការធានារ៉ាប់រង

[26] ខិត្តបណ្ណផលិតផលអំពីសេវាធានារ៉ាប់រងគ្រោះថ្នាក់លើការធ្វើដំណើរនៅទូទាំងពិភពលោក របស់ក្រុមហ៊ុន កាមិនកូ
[27] មាត្រា ២៣ កថាខណ្ឌទី ៤ នៃច្បាប់ស្តីពីការធានារ៉ាប់រង, ចុះថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ២០១៤
[28] ខិត្តបណ្ណផលិតផលអំពីសេវាធានារ៉ាប់រងគាំពារសុខភាពគ្រួសារ របស់ក្រុមហ៊ុន ហ្វតេ

ផនលាភ[29] ។

### ១.២.១. ការធានារ៉ាប់រងអាយុជីវិតមានកាលកំណត់

ការធានារ៉ាប់រងអាយុជីវិតមានកាលកំណត់ ជាការធានារ៉ាប់រងអាយុជីវិតនៅពេលដែលអ្នកត្រូវបានធានារ៉ាប់រងបានស្លាប់នៅក្នុងរយៈពេលកំណត់ជាក់លាក់ណាមួយដូចជា ៥ (ប្រាំ) ឆ្នាំ ឬ ១០ (ដប់) ឆ្នាំ ឬស្លាប់នៅអាយុដែលបានកំណត់ទុកដោយផ្តល់ផលប្រយោជន៍ទៅឱ្យអ្នកទទួលផល ដូចបានកំណត់ក្នុងកិច្ចសន្យានោះ ។ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងនៅមានជីវិតបន្ទាប់ពីរយៈពេលដែលកំណត់ទុកក្នុងកិច្ចសន្យានោះ អ្នកទទួលផលមិនអាចទទួលផលប្រយោជន៍ពីការធានារ៉ាប់រងនេះឡើយ[30] ។

នៅក្នុងប្រតិបត្តិការធានារ៉ាប់រងសព្វថ្ងៃ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតមេនូឡាយហ្វ៍ មានផលិតផលនៃការធានារ៉ាប់រងអាយុជីវិតមានកាលកំណត់មួយឈ្មោះថា គម្រោងអនាគតគ្រួសារខ្ញុំ ។ គម្រោងអនាគតគ្រួសារខ្ញុំ គឺជាគម្រោងផ្តល់ប្រាក់សំណងដល់គ្រួសាររបស់អ្នកត្រូវបានធានារ៉ាប់រងក្នុងករណីមានរឿងហេតុអកុសលណាមួយកើតឡើង ។ អ្នកត្រូវបានធានារ៉ាប់រងអាចជ្រើសរើសរយៈពេលនៃការការពារសមស្របទៅតាមតម្រូវការហិរញ្ញវត្ថុគ្រួសារ ( ៧ ឆ្នាំ, ១០ ឆ្នាំ, ១៥ ឆ្នាំ, ២០ ឆ្នាំ, ២៥ ឆ្នាំ ឬ ៣០ ឆ្នាំ )[31] ។

### ១.២.២. ការធានារ៉ាប់រងមួយជីវិតកាល

ការធានារ៉ាប់រងមួយជីវិតកាល ជាកិច្ចសន្យាធានារ៉ាប់រងដែលធានារ៉ាប់រងលើការស្លាប់របស់អ្នកត្រូវបានធានារ៉ាប់រង ហើយបុព្វលាភធានារ៉ាប់រងអាចត្រូវបង់សម្រាប់រយៈពេលច្បាស់លាស់ ឬមួយជីវិត ។ ក្នុងការធានារ៉ាប់រងមួយជីវិតកាល គេអាចកំណត់ចំនួនបុព្វលាភធានារ៉ាប់រងដែលត្រូវបង់ក្នុងចំនួនស្មើគ្នាជារៀងរាល់ឆ្នាំ ក្នុងអំឡុងពេលដែលអ្នកត្រូវបានធានារ៉ាប់រងនៅមានជីវិត ។ ក្រុមហ៊ុនធានារ៉ាប់រងត្រូវផ្តល់ផលប្រយោជន៍ទៅអោយក្រុមគ្រួសាររបស់អ្នកស្លាប់ ឬ ទៅអោយអ្នកទទួលផលណាម្នាក់ដែលមានសិទ្ធិទទួល នៅពេលដែលអ្នកត្រូវបានធានារ៉ាប់រងបានទទួលមរណៈភាព[32] ។

---

[29] មាត្រា ២៦ កថាខណ្ឌទី ១ នៃច្បាប់ស្តីពីការធានារ៉ាប់រង, ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៤

[30] មាត្រា ២៦ កថាខណ្ឌទី ២ នៃច្បាប់ដដែល

[31] ខិត្តបណ្ណផលិតផលអំពីសេវាធានារ៉ាប់រងអានាគតគ្រួសារខ្ញុំ របស់ក្រុមហ៊ុន មេនូឡាយហ្វ៍

[32] មាត្រា ២៦ កថាខណ្ឌទី ៣ នៃច្បាប់ដដែល

### ១.២.៣ ការធានារ៉ាប់រងទាយជ្ជទាន

ការធានារ៉ាប់រងទាយជ្ជទាន ជាការធានារ៉ាប់រងអាយុជីវិតដែលផលប្រយោជន៍បានមកពីការធានារ៉ាប់រងអាចត្រូវផ្តល់ទៅអោយអ្នកត្រូវបានធានារ៉ាប់រង ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងនោះនៅរស់រានមានជីវិតអំឡុងពេលដែលត្រូវបានធានាដូចបានកំណត់ក្នុងកិច្ចសន្យា ។ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងស្លាប់មុនកាលបរិច្ឆេទដែលបានកំណត់ក្នុងកិច្ចសន្យានោះ ផលប្រយោជន៍ត្រូវផ្តល់ទៅអោយអ្នកទទួលផលវិញ[33] ។

នៅក្នុងការប្រតិបត្តិសព្វថ្ងៃ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត មេនូឡាយហ្វ៍ មានផលិតផលនៃការធានារ៉ាប់រងទាយជ្ជទានមួយឈ្មោះថា គម្រោងមរតកខ្ញុំ ។ គម្រោងនេះ គឺជាគម្រោងដែលផ្តល់ជូនទាំងការការពារលើអាយុជីវិត និង ការសន្សំប្រាក់ សម្រាប់គ្រួសាររបស់អ្នកត្រូវបានធានារ៉ាប់រងនាពេលអនាគត ។ គម្រោងនេះផ្តល់ជម្រើសសម្រាប់រយៈពេលនៃការការពារចំនួន ១០ ឆ្នាំ ឬ ១៥ឆ្នាំ[34] ។

### ១.១.៤ ការធានារ៉ាប់រងធនលាភ

ការធានារ៉ាប់រងធនលាភ ជាកិច្ចសន្យាធានារ៉ាប់រងដែលផ្តល់ប្រាក់ចំណូលដល់អ្នកត្រូវបានធានារ៉ាប់រងសម្រាប់អាយុកាលចូលនិវត្តន៍[35] ។ ការធានារ៉ាប់រងនេះ អ្នកត្រូវបានធានារ៉ាប់រងត្រូវបង់បុព្វលាភឱ្យទៅក្រុមហ៊ុនធានារ៉ាប់រងរហូតដល់អាយុកាលដែលខ្លួនចូលនិវត្តន៍ ។ ជាទូទៅ អាយុកាលចូលនិវត្តន៍របស់បុគ្គលម្នាក់ៗគឺនៅអាយុ ៦៥ ឆ្នាំ ។ ពោលគឺអ្នកត្រូវបានធានារ៉ាប់រងត្រូវបង់បុព្វលាភឱ្យទៅក្រុមហ៊ុនរហូតដល់អាយុ ៦៥ ឆ្នាំ ទើបបញ្ឈប់ការបង់ ។

នៅក្នុងការប្រតិបត្តិជាក់ស្តែង ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត មេនូឡាយហ្វ៍ មានផលិតផលទាក់ទងនឹងការធានារ៉ាប់រងធនលាភមួយឈ្មោះថា គម្រោងមេនូឡាយហ្វ៍ជីវិតខ្ញុំ ។ គម្រោងនេះ គឺជាគម្រោងដែលផ្តល់ជូននូវកញ្ចប់សាច់ប្រាក់ដល់អ្នកត្រូវបានធានារ៉ាប់រងចាប់ពីអាយុ ៦៥ ឆ្នាំឡើងទៅ ជារៀងរាល់៥ ឆ្នាំម្តង រហូតដល់អាយុ ១០០ ឆ្នាំ ។ គម្រោងនេះធ្វើការការពារអាយុជីវិតរបស់អ្នកត្រូវបានធានារ៉ាប់រងរហូតដល់អាយុ ១០០ ឆ្នាំ ហើយនៅពេលដែលអ្នកត្រូវបានធានារ៉ាប់រងដល់អាយុ ៦៥ ឆ្នាំ អ្នកត្រូវបានធានារ៉ាប់រងពុំចាំបាច់បង់បុព្វលាភរ៉ាប់រងឡើយ[36] ។

---

[33] មាត្រា ២៦ កថាខណ្ឌទី ៤ នៃច្បាប់ស្តីពីការធានារ៉ាប់រង, ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៤

[34] ខិត្តបណ្ណផលិតផលអំពីគម្រោងមរតកខ្ញុំ របស់ក្រុមហ៊ុន មេនូឡាយហ្វ៍

[35] មាត្រា ២៦ កថាខណ្ឌទី ៥ នៃច្បាប់ដដែល

[36] ខិត្តបណ្ណផលិតផលអំពីគម្រោងមេនូឡាយហ្វ៍ជីវិតខ្ញុំ របស់ក្រុមហ៊ុន មេនូឡាយហ្វ៍

## ជំពូកទី២ ៖ កិច្ចសន្យាធានារ៉ាប់រង

មុននឹងឈានដល់ការបកស្រាយអំពីកិច្ចសន្យាធានារ៉ាប់រង យើងគប្បីយល់អំពីនិយមន័យនៃកិច្ចសន្យា និង ការធានារ៉ាប់រងជាមុនសិន ។ កិច្ចសន្យា គឺជាកិរិយាដែលបុគ្គលពីរនាក់ ឬ ច្រើននាក់ មានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬ រំលត់នូវកាតព្វកិច្ច ។ រីឯការធានារ៉ាប់រង សំដៅដល់ការធ្វើកិច្ចសន្យាធានារ៉ាប់រងដែលក្នុងនោះ អ្នកត្រូវបានធានារ៉ាប់រងត្រូវបង់បុព្វលាភធានារ៉ាប់រងទៅឱ្យក្រុមហ៊ុនធានារ៉ាប់រង ហើយក្រុមហ៊ុនធានារ៉ាប់រងត្រូវធ្វើសំណងដល់ការខូចខាត ឬ ការបាត់បង់ទ្រព្យសម្បត្តិដែលបង្កឡើងដោយហេតុការណ៍គ្រោះថ្នាក់ ឬ ក៏ធ្វើសំណងនៅពេលដែលអ្នកត្រូវបានធានារ៉ាប់រងស្លាប់ របួស ពិការ មានជម្ងឺ ឬ នៅពេលដែលបុគ្គលនោះ ឈានដល់កាលកំណត់ណាមួយដែលភាគីទាំងពីរបានព្រមព្រៀងគ្នា ដូចមានចែងក្នុងកិច្ចសន្យាធានារ៉ាប់រង ។

កិច្ចសន្យាធានារ៉ាប់រង សំដៅដល់កិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ ដែលធ្វើឡើងដោយក្រុមហ៊ុនធានារ៉ាប់រង និងអ្នកត្រូវបានធានារ៉ាប់រង ដែលតាមរយៈនោះ ក្រុមហ៊ុនធានារ៉ាប់រងព្រមទទួលនូវហានិភ័យជាក់លាក់ណាមួយ ដោយទទួលមកវិញនូវការបង់បុព្វលាភធានារ៉ាប់រងពីអ្នកដែលត្រូវបានធានារ៉ាប់រង ។ អ្នកត្រូវបានធានារ៉ាប់រង សំដៅដល់រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលទិញបណ្ណសន្យារ៉ាប់រង ក្នុងករណីមួយចំនួនអាចជាម្ចាស់បណ្ណសន្យារ៉ាប់រងផង និង អាចជាអ្នកត្រូវបានធានារ៉ាប់រងផង ។ រីឯក្រុមហ៊ុនធានារ៉ាប់រងសំដៅដល់ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ក្រុមហ៊ុនធានារ៉ាប់រងទូទៅ ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច និង ក្រុមហ៊ុនធានារ៉ាប់រងបន្ត[37] ។

កិច្ចសន្យាធានារ៉ាប់រង គឺជាកិច្ចសន្យាមូលា (កិច្ចសន្យាដែលយកតម្លៃថ្នូរ) និង ជាកិច្ចសន្យាមិនទៀង[38] ។ លើសពីនេះ កិច្ចសន្យាធានារ៉ាប់រង គឺជាកិច្ចសន្យាដែលមានលក្ខណៈទម្រង់ ដោយសារតែកិច្ចសន្យានេះទាមទារឱ្យមានការសរសេរជាលាយលក្ខណ៍អក្សរច្បាស់លាស់ មិនអាចបង្កើតឡើងត្រឹមតែការព្រមព្រៀងផ្ទាល់មាត់នោះទេ ។ ដោយហេតុថា ការធ្វើអាជីវកម្មធានារ៉ាប់រងគឺជាធុរៈកិច្ចដែលមានប្រភេទជាពាណិជ្ជកម្ម ដូច្នេះយើងអាចនិយាយបានថាកិច្ចសន្យាធានារ៉ាប់រងគឺជាកិច្ចសន្យាពាណិជ្ជកម្ម[39] ។ នៅពេលដែលពុំមានខចែងនៅក្នុងច្បាប់ដែលទាក់ទងនឹងកិច្ចសន្យាពាណិជ្ជកម្មទេ វិធានទូទៅនានានៃក្រមរដ្ឋប្បវេណី និង ច្បាប់ផ្សេងៗទៀតដែលនៅជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា ដែលទាក់ទងនឹងកាតព្វកិច្ច និង កិច្ចសន្យាត្រូវអនុវត្តចំពោះគ្រប់កិច្ចសន្យាពាណិជ្ជកម្មទាំងអស់ ។

---

[37] មាត្រា ៤ នៃច្បាប់ស្តីពីការធានារ៉ាប់រង, ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៤

[38] សាស្ត្រាចារ្យ ជិន វណ្ណារ៉ា, នីតិកិច្ចសន្យា, បោះពុម្ពឆ្នាំ ២០១៣, ទំព័រ ៣៩

[39] មាត្រា ៣ ចំណុច គ នៃសេចក្តីព្រាងច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម

ជាគោលការណ៍ កិច្ចសន្យាទាំងឡាយ រួមទាំងកិច្ចសន្យាធានារ៉ាប់រង ត្រូវតែគោរពលក្ខខណ្ឌនៃការបង្កើត ( ២.១ ) បន្ទាប់មកនាំឱ្យកិច្ចសន្យាមានអានុភាព ( ២.២ ) ជាចុងក្រោយគឺការបញ្ចប់កិច្ចសន្យាធានារ៉ាប់រង ( ២.៣ ) ។

## ២.១. លក្ខខណ្ឌនៃការបង្កើតកិច្ចសន្យាធានារ៉ាប់រង

ដើម្បីបង្កើតកិច្ចសន្យាធានារ៉ាប់រងអោយមានសុពលភាព យើងត្រូវគោរពលក្ខខណ្ឌពីរសំខាន់ៗ គឺ លក្ខខណ្ឌគ្រឹះ ( ២.១.១ ) និង លក្ខខណ្ឌទម្រង់ ( ២.១.២ ) ។

### ២.១.១. លក្ខខណ្ឌគ្រឹះ

ជាគោលការណ៍ កិច្ចសន្យាមួយត្រូវបានបង្កើតឡើងដោយមាន ការព្រមព្រៀងពីសំណាក់បុគ្គលដែលមានសមត្ថភាពគតិយុត្ត ទៅលើកម្មវត្ថុណាមួយជាក់លាក់ ។

#### ២.១.១.១. ការព្រមព្រៀង

ការព្រមព្រៀង គឺជាការបង្ហាញឆន្ទៈរបស់ភាគីនីមួយៗក្នុងការចុះកិច្ចសន្យា ។ ការព្រមព្រៀងត្រូវតែធ្វើឡើងនៅពេលដែលសំណើរបស់អ្នកទិញធានារ៉ាប់រង ជួបជាមួយនឹងស្វីការរបស់ក្រុមហ៊ុនធានារ៉ាប់រង ។ លើសពីនេះ ការព្រមព្រៀងត្រូវជៀសវាងនូវវិការៈដូចមានចែងក្នុងក្រមរដ្ឋប្បវេណីជាធរមាន ។

##### ក. ជំនួបនៃឆន្ទៈ

ជំនួបនៃឆន្ទៈ មានន័យថា នៅពេលដែលសំណើជួបជាមួយនឹងស្វីការ ។ កិច្ចព្រមព្រៀងខាងឆន្ទៈទាំងអស់នេះបង្កើតបានជាកិច្ចសន្យា លើកលែងកិច្ចសន្យាជាលក្ខណៈទម្រង់ ( សរសេរជាលាយលក្ខណ៍អក្សរ ) ។

##### ក.១. សំណើ

យោងតាមមាត្រា ៣៣៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ សំណើ គឺជាការសុំបង្កើតកិច្ចសន្យាដែលធ្វើឡើងដោយមានឆន្ទៈភ្ជាប់ខ្លួនជាមួយនឹងចំណងគតិយុត្ត ក្នុងករណីដែលមានស្វីការរបស់ភាគីម្ខាងទៀតចំពោះសំណើនេះ ។ សំណើត្រូវមានអានុភាពនៅពេលដែលសំណើនោះបានដល់ភាគីម្ខាងទៀត ។ ប៉ុន្តែ ប្រសិនបើដំណឹងអំពីការដកសំណើវិញ ដល់ភាគីម្ខាងទៀត នៅពេលព្រមគ្នានឹងពេលសំណើដល់ ឬ មុនពេលសំណើដល់ នោះអានុភាពសំណើមិនត្រូវកើតឡើយ ។

បុគ្គលគ្រប់រូបដែលមានបំណងចង់ទិញផលិតផល ឬ គម្រោងធានារ៉ាប់រងរបស់ក្រុមហ៊ុនធានារ៉ាប់រងណាមួយដែលខ្លួនពេញចិត្ត ត្រូវបំពេញពាក្យស្នើសុំ ឬ ទម្រង់បែបបទស្នើសុំធានារ៉ាប់រង ដើម្បីឱ្យក្រុមហ៊ុនធានារ៉ាប់រងនោះទទួលយកនូវសំណើរបស់ខ្លួន ។ បុគ្គលដែលបានបំពេញពាក្យស្នើសុំ ឬទម្រង់បែបបទស្នើសុំធានារ៉ាប់រងនេះហៅថា ‹ អ្នកស្នើសុំធានារ៉ាប់រង › ។ យោងតាមមាត្រា ៤ នៃច្បាប់ស្តីពីការធានារ៉ាប់រង ឆ្នាំ២០១៤ បានឱ្យនិយមន័យថា អ្នកស្នើសុំធានារ៉ាប់រង សំដៅដល់រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលអាចនឹងក្លាយជាអ្នកត្រូវបានធានារ៉ាប់រងនាពេលអនាគតដែលបំពេញ និង ចុះហត្ថលេខាលើទម្រង់បែបបទជាលាយលក្ខណ៍អក្សររបស់ក្រុមហ៊ុនធានារ៉ាប់រងអំពីស្ថានភាពផ្ទាល់របស់បុគ្គលនោះ ។

### ក.២. ស្វីការ

ស្វីការ គឺជាការបង្ហាញឆន្ទៈដែលអ្នកទទួលសំណើយល់ព្រមចំពោះសំណើនោះ ។ ស្វីការត្រូវមានអានុភាពនៅពេលដែលស្វីការនោះបានដល់អ្នកស្នើ ។ ប៉ុន្តែ ប្រសិនបើដំណឹងអំពីការដកស្វីការវិញដល់អ្នកស្នើ នៅពេលព្រមគ្នានឹងពេលស្វីការដល់ ឬ មុនពេលស្វីការដល់ នោះអានុភាពនៃស្វីការមិនត្រូវកើតឡើយ ។ ស្វីការអាចធ្វើឡើងដោយច្បាស់លាស់ និង ដោយស្ងៀមស្ងាត់ ។ ស្វីការច្បាស់លាស់ គឺជាស្វីការដែលមានជាលាយលក្ខណ៍អក្សរបង្ហាញឆន្ទៈយល់ព្រមរបស់ខ្លួនយ៉ាងច្បាស់លាស់ ។ រីឯស្វីការដោយការស្ងៀមស្ងាត់ គឺជាការព្រមព្រៀងដូចជា ការងក់ក្បាល ការធ្វើសញ្ញាណាមួយតាមរយៈកាយវិការ ជាដើម...។

នៅពេលដែលសំណើរបស់អ្នកស្នើសុំធានារ៉ាប់រងបានមកដល់ក្រុមហ៊ុនធានារ៉ាប់រង នោះក្រុមហ៊ុននឹងធ្វើការត្រួតពិនិត្យ និង ផ្ទៀងផ្ទាត់ព័ត៌មានទាំងឡាយដែលមាននៅក្នុងពាក្យស្នើសុំ ឬ ទម្រង់បែបបទស្នើសុំធានារ៉ាប់រងនោះ ថាតើមានភាពពេញលេញ ត្រឹមត្រូវពិតប្រាកដហើយឬនៅ ? ប្រសិនបើពត៌មានទាំងនោះគ្រប់គ្រាន់ និង ត្រឹមត្រូវអស់ហើយ ក្រុមហ៊ុននឹងយល់ព្រមទទួលយកសំណើរបស់បុគ្គលនោះ ដោយព្រមធានារ៉ាប់រងទៅលើហានិភ័យណាមួយដែលនឹងកើតឡើងនាពេលអនាគត ដែលជាថ្នូរនឹងការទទួលបានមកវិញនូវការបង់បុព្វលាភរ៉ាប់រងរបស់បុគ្គលនោះ ។

### ខ. ការព្រមព្រៀងដោយគ្មានវិការៈ

ការព្រមព្រៀងដោយគ្មានវិការៈ មានន័យថាជាការព្រមព្រៀងទាំងឡាយណាដែលពុំមានវិការៈណាមួយនាំឱ្យប៉ះពាល់ដល់ការព្រមព្រៀង ។ មាត្រា ៣៤៥ នៃក្រមរដ្ឋប្បវេណី ចាត់ទុកថាជាការបង្ហាញឆន្ទៈមានវិការៈតាមរូបភាពមួយចំនួនដូចជា ការភាន់ច្រឡំ ការឆបោក ការគម្រាមកំហែង ការបង្ហាញព័ត៌មានមិនពិត និង ការកេងចំណេញហួសហេតុ ។ល។

### ខ.១. ការភាន់ច្រឡំ

ការភាន់ច្រឡំ មានន័យថា នៅក្នុងករណីដែលអ្នកបង្ហាញឆន្ទៈ បានធ្វើការបង្ហាញឆន្ទៈ ដែលមានលក្ខណៈខុសគ្នាទៅនឹងឆន្ទៈពិតរបស់ខ្លួន ហើយគេក៏មិនបានដឹងអំពីភាពខុសគ្នានេះ នៅពេលដែលគេធ្វើការបង្ហាញឆន្ទៈឡើយ[40] ។

### ខ.២ ការឆបោក

ការបង្ហាញឆន្ទៈដោយការឆបោក មានន័យថាបុគ្គលណាម្នាក់ ឬ តតិយជន បានធ្វើឱ្យអ្នកបង្ហាញឆន្ទៈ មានការភាន់ច្រឡំដោយសារមធ្យោបាយឆបោក ហើយអ្នកបង្ហាញឆន្ទៈបានបង្ហាញឆន្ទៈរបស់ខ្លួន ដោយខុសពីឆន្ទៈពិតប្រាកដរបស់ខ្លួន និង គាត់មិនបានដឹងពីភាពខុសគ្នានេះ នៅពេលដែលគាត់ធ្វើការបង្ហាញឆន្ទៈ[41] ។

### ខ.៣ ការគម្រាមកំហែង

ការបង្ហាញឆន្ទៈដោយមានការគម្រាមកំហែង សំដៅទៅលើករណីដែលអ្នកបង្ហាញឆន្ទៈបានបង្ហាញឆន្ទៈរបស់ខ្លួន ដែលផ្ទុយនឹងគោលបំណងរបស់ខ្លួន ដោយសារមានការភ័យខ្លាចភាគីម្ខាងទៀត ឬ តតិយជន[42] ។

### ខ.៤ ព័ត៌មានមិនពិត

ព័ត៌មានមិនពិត សំដៅទៅលើមូលហេតុដែលត្រូវបានលើកឡើងដោយភាគី សម្រាប់ជាមូលដ្ឋាននៅក្នុងការបង្កើតកិច្ចសន្យា គឺខុសពីការពិត ។ ទន្ទឹមនឹងនេះ ប្រសិនបើអ្នកបង្ហាញឆន្ទៈបានដឹងថា ហេតុនោះមិនជាការពិត នោះខ្លួននឹងមិនបង្ហាញឆន្ទៈទេ[43] ។

### ខ.៥ ការរំលោភបំពានលើស្ថានភាព

ការរំលោភបំពានលើស្ថានភាព សំដៅទៅលើករណីដែលភាគីម្ខាងបានធ្វើកិច្ចសន្យាដោយឆ្លៀតឱកាសដែលភាគីម្ខាងទៀតកំពុងជួបប្រទះនូវការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬ សង្គម ឬ បានប្រើដោយមិនត្រឹមត្រូវនូវស្ថានភាពផ្សេងទៀត ដែលភាគីម្ខាងទៀតមិនអាចប្រឆាំងតបបានទេ ។ នៅក្នុងករណីនេះ ភាគីដែលបានរំលោភបំពានលើស្ថានភាពមិនត្រូវបានចាត់ទុកថាបានធ្វើការ

[40] ក្រុមការងារនៃអនាគតគម្រោងបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ១-២, កែសម្រួលការបោះពុម្ពលើកទី១ ឆ្នាំ ២០១៣, ទំព័រ ១២០

[41] សៀវភៅដដែល, ទំព័រ ១២៧

[42] សៀវភៅដដែល, ទំព័រ ១៣១

[43] សៀវភៅដដែល, ទំព័រ ១៣២

គម្រាមកំហែងឡើយ ព្រោះគាត់មិនបានប្រើវិធានការបង្ខំ ។ ក៏ប៉ុន្តែ ដើម្បីកំណត់បានជាការរំលោភបំពានលើស្ថានភាព វាមានភាពចាំបាច់ដែលភាគីម្ខាងទៀតឆ្លៀតឱកាសនៃស្ថានភាពទន់ខ្សោយរបស់អ្នកបង្ហាញឆន្ទៈ[44] ។

### ខ.៦ អំពើកេងចំណេញហួសហេតុ

អំពើកេងយកចំណេញហួសហេតុ សំដៅទៅលើករណីដែលភាគីម្ខាងបានធ្វើកិច្ចសន្យាដោយឆ្លៀតឱកាសដែលភាគីម្ខាងទៀតកំពុងជួបប្រទះការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬ ភាពល្ងង់ខ្លៅ ឬ ការខ្វះបទពិសោធន៍ ហើយបានកេងយកចំណេញយ៉ាងសន្ធឹកសន្ធាប់ពីកិច្ចសន្យានោះ[45] ។

### ២.១.១.២. សមត្ថភាព

ដើម្បីអោយកិច្ចសន្យាមួយមានសុពលភាព ទាមទារឱ្យភាគីនីមួយៗនៃកិច្ចសន្យាមានសមត្ថភាពគតិយុត្ត ។ សមត្ថភាព សំដៅទៅលើលក្ខណៈសម្បត្តិរបស់បុគ្គលដែលតម្រូវដោយច្បាប់ រួមមាន ៖ លក្ខណៈសម្បត្តិដែលអាចក្លាយជាម្ចាស់សិទ្ធិ និង កាតព្វកិច្ច ( សមត្ថភាពទទួលសិទ្ធិ ) លក្ខណៈសម្បត្តិដែលអាចយល់ដឹង និង វិនិច្ឆ័យបានអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ( សមត្ថភាពខាងឆន្ទៈ ) និង លក្ខណៈសម្បត្តិដែលអាចធ្វើឱ្យសកម្មភាពរបស់ខ្លួនមានអានុភាពតាមផ្លូវច្បាប់ ( សមត្ថភាពក្នុងការធ្វើសកម្មភាព ) ។ សមត្ថភាពគតិយុត្តរបស់ភាគីនៃកិច្ចសន្យាធានារ៉ាប់រងមាន សមត្ថភាពរបស់អ្នកទិញធានារ៉ាប់រង និង សមត្ថភាពរបស់ក្រុមហ៊ុនធានារ៉ាប់រង ។

### ក. សមត្ថភាពរបស់អ្នកទិញធានារ៉ាប់រង

អ្នកទិញធានារ៉ាប់រង អាចជារូបវន្តបុគ្គល ឬ នីតិបុគ្គលទាំងឡាយណាដែលអាចមានលក្ខណៈសម្បត្តិជាពាណិជ្ជករ ឬ មិនមែនជាពាណិជ្ជករ។ ជាទូទៅ អ្នកទិញធានារ៉ាប់រង គឺជានីតិជនដែលមានសមត្ថភាពចុះកិច្ចសន្យាពោលគឺ ជាជនដែលមានការយល់ដឹង និង អាចវិនិច្ឆ័យបានអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ។ លើសពីនេះអ្នកដែលទិញធានារ៉ាប់រងត្រូវតែជាបុគ្គលដែលអាចបង្ហាញឆន្ទៈប្រកបដោយប្រសិទ្ធភាពជាស្ថាពរ និង ដោយឯករាជ្យ។ ក្រមរដ្ឋប្បវេណីបានធ្វើចំណាត់ថ្នាក់បុគ្គលដែលមិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើកិច្ចការដោយឯករាជ្យ និង បានបង្កើតឱ្យមានអ្នកអាណាព្យាបាលសម្រាប់ពួកគាត់ ។ ជនដែលត្រូវបានធ្វើចំណាត់ថ្នាក់ទាំងនោះមានបីប្រភេទ មានដូចជា អនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និង ជននៅក្រោមហិតូបត្ថម្ភ ដើម្បីរក្សាតុល្យភាពរវាងការការពារជនដែលត្រូវបានកម្រិតសមត្ថភាព និង ថែរក្សានូវស្ថិរភាពនៅ

[44] ក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ១-២, កែសម្រួលការបោះពុម្ពលើកទី១ ឆ្នាំ ២០១៣, ទំព័រ ១៣៣

[45] សៀវភៅដដែល, ទំព័រ ១៣៣

ក្នុងការប្រកបកិច្ចការជំនួញ[46] ។ ចំពោះអនីតិជន អាចក្លាយជាអ្នកត្រូវបានធានារ៉ាប់រងអាយុជីវិត ចំពោះបុគ្គលដែលមានវិបត្តិផ្នែកបញ្ញាស្មារតី បុគ្គលដែលកំពុងព្យាបាលជម្ងឺវិកលចរិតមិនអាចក្លាយជាកម្មវត្ថុនៃការស្នើសុំធានារ៉ាប់រងអាយុជីវិតបានឡើយ ។

### ខ. សមត្ថភាពរបស់ក្រុមហ៊ុនធានារ៉ាប់រង

គ្រឹះស្ថានធានារ៉ាប់រងមានដូចជា ក្រុមហ៊ុនធានារ៉ាប់រងទូទៅ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច ក្រុមហ៊ុនធានារ៉ាប់រងបន្ត ភ្នាក់ងារធានារ៉ាប់រង ជើងសារធានារ៉ាប់រង និង ក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រង ។ ក្រុមហ៊ុនធានារ៉ាប់រងទាំងអស់ដែលផ្តល់សេវាធានារ៉ាប់រង ទោះបីជារបស់រដ្ឋក្តី ជារបស់ឯកជនក្តី ឬ ជាក្រុមហ៊ុនចម្រុះក្តីអាចត្រូវបានអនុញ្ញាតឱ្យធ្វើប្រតិបត្តិការធានារ៉ាប់រងនៅព្រះរាជាណាចក្រកម្ពុជា តែក្នុងទ្រង់ទ្រាយជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតតែប៉ុណ្ណោះ ។ ជាដំបូង ក្រុមហ៊ុនធានារ៉ាប់រងត្រូវចុះបញ្ជីពាណិជ្ជកម្ម នៅក្រសួងពាណិជ្ជកម្ម ដើម្បីក្លាយខ្លួនជាប្រធាននៃសិទ្ធិ និង កាតព្វកិច្ច ។ បន្ទាប់មកក្រុមហ៊ុនធានារ៉ាប់រងត្រូវដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីធ្វើអាជីវកម្មធានារ៉ាប់រង ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានសិទ្ធិក្នុងការសម្រេច ឬ បដិសេដសំណើសុំអាជ្ញាប័ណ្ណធានារ៉ាប់រងក្នុងរយៈពេល ៩០ ថ្ងៃ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំដែលមានសំណុំលិខិតគ្រប់គ្រាន់ ។ ប្រតិបត្តិករធានារ៉ាប់រងទាំងអស់ អាចធ្វើអាជីវកម្មលើវិស័យធានារ៉ាប់រងនៅព្រះរាជាណាចក្រកម្ពុជាបានលុះត្រាតែ ៖ មានអាជ្ញាបណ្ណ និង បានចុះបញ្ជីត្រឹមត្រូវតាមច្បាប់សម្រាប់ប្រភេទធានារ៉ាប់រងណាមួយ ឬ ទាំងពីរប្រភេទ ។ បានផ្តល់ជូនក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនូវលិខិត ឬ ឯកសារដែលបញ្ជាក់អះអាងថាបានដាក់ប្រាក់តម្កល់ចំនួនស្មើនឹង ១០ ភាគរយ នៃដើមទុនចុះបញ្ជីនៅរតនាគារជាតិនៃព្រះរាជាណាចក្រកម្ពុជា ។ បានផ្តល់ជូនក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នូវលិខិត ឬ ឯកសារដែលបញ្ជាក់អះអាងថាបានរក្សាទុកទឹកប្រាក់ជាកម្រិតសាធនភាពមិនតិចជាង ៥០ ភាគរយ នៃដើមទុនចុះបញ្ជីនៅធនាគារពាណិជ្ជណាមួយ នៅព្រះរាជាណាចក្រកម្ពុជា ដែលមានការទទួលស្គាល់ពីធនាគារជាតិនៃកម្ពុជា[47] ។

### ២.១.១.៣. កម្មវត្ថុ

កម្មវត្ថុ ជាលក្ខខណ្ឌមួយដ៏សំខាន់សម្រាប់បង្កើតកិច្ចសន្យា ។ កម្មវត្ថុនៃការធានារ៉ាប់រងមានដូចជា ទ្រព្យសម្បត្តិ រូបរាងកាយ និង អាយុជីវិត ។ កម្មវត្ថុនៃការធានារ៉ាប់រងទ្រព្យសម្បត្តិមានដូចជា នាវា យានយន្ត អគារ សំណង់ ការដ្ឋាន ផ្សេងៗ ។ កម្មវត្ថុនៃការធានារ៉ាប់រងរូបកាយ មានដូចជា ការធានារ៉ាប់រងសុខភាព គ្រោះថ្នាក់ផ្សេងៗដែលបង្កឱ្យមានផលប៉ះពាល់ដល់រូបកាយរបស់អ្នកត្រូវបាន

[46] ក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ១-២, កែសម្រួលការបោះពុម្ពលើកទី១ ឆ្នាំ ២០១៣, ទំព័រ ១៦

[47] ប្រការ ២ នៃប្រកាសស្តីពីការកំណត់ទូទៅចំពោះប្រតិបត្តិការធានារ៉ាប់រង, ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០១

ធានារ៉ាប់រង។ កម្មវត្ថុនៃការធានារ៉ាប់រងអាយុជីវិត មានដូចជា អ្នកត្រូវបានធានារ៉ាប់រងអាយុជីវិតទៅលើការស្លាប់ ឬ ការរស់រានមានជីវិតដោយរួមបញ្ចូលការធានារ៉ាប់រងលើគ្រោះថ្នាក់បុគ្គល ជម្ងឺធ្ងន់ធ្ងរ ឬ ជម្ងឺទូទៅ និង អ្នកទទួលផលក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព ។ កម្មវត្ថុនៃកិច្ចសន្យាធានារ៉ាប់រង ត្រូវបានធានារ៉ាប់រងក្នុងចិរវេលាច្បាស់លាស់ ដូចជា រយៈពេល ៥ឆ្នាំ ១០ឆ្នាំ ជាដើម ។

ចំពោះកិច្ចសន្យាធានារ៉ាប់រងមួយចំនួន ចំណងកាតព្វកិច្ចរបស់ភាគីម្ខាងកើតចេញពីច្បាប់កំណត់ ។ ច្បាប់តម្រូវឱ្យម្ចាស់អាជីវកម្មមួយចំនួនត្រូវតែទិញធានារ៉ាប់រងជាដាច់ខាត ។ អាស្រ័យហេតុនេះ កម្មវត្ថុនៃកិច្ចសន្យាបែបនេះដែលកើតចេញពីភាគីសំដែងឆន្ទៈពិតជាមានកត្តាច្បាប់មួយដែលផ្តល់ជាអាជ្ញាបញ្ជាទៅលើឆន្ទៈភាគី ដូចជា ការធ្វើអាជីវកម្មដឹកជញ្ជូនអ្នកដំណើរ សហគ្រាសសាងសង់ ជាដើម ។ ជាសម្អាងលើរឿងនេះ ប្រការ ២ នៃប្រកាសអន្តរក្រសួងស្តីពីកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្ត ឬ ធានារ៉ាប់រងតតិយជន បានបញ្ញត្តិអំពីប្រភេទយានយន្តដែលត្រូវបំពេញកាតព្វកិច្ចធានារ៉ាប់រងតតិយជន មានដូចជា យានយន្តគ្រប់ប្រភេទដែលធ្វើអាជីវកម្មដឹកជញ្ជូនទំនិញ ដឹកជញ្ជូនអ្នកដំណើរ...។ និង ប្រការ ២ នៃប្រកាសអន្តរក្រសួងស្តីពីកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន បានបញ្ញត្តិថា គ្រប់ការដ្ឋានសាងសង់ ជួសជុល តម្លើងទាំងអស់ដែលទទួលខុសត្រូវដោយសហគ្រិន អ្នកម៉ៅការ ឬ អ្នកម៉ៅការបន្ត ចាំបាច់ត្រូវតែមានការធានារ៉ាប់រងលើភារៈទទួលខុសត្រូវការដ្ឋាន តែក៏មានការលើកលែងចំពោះប្រភេទការដ្ឋានខ្លះផងដែរ...។ រីឯកិច្ចសន្យាធានារ៉ាប់រងខ្លះទៀត គឺធ្វើឡើងតាមការព្រមព្រៀងរបស់គូភាគី ដូចជា ការធានារ៉ាប់រងអាយុជីវិត ការធានារ៉ាប់រងសុខភាព ការធានារ៉ាប់រងយានយន្ត ។ល។

ក្រៅពីកម្មវត្ថុដូចដែលបានបកស្រាយខាងលើ នៅមានកម្មវត្ថុមួយទៀតសំខាន់ខ្វះមិនបានគឺបុព្វលាភរ៉ាប់រង ។ បុព្វលាភរ៉ាប់រង សំដៅដល់ចំនួនទឹកដែលប្រាក់ដែលអ្នកត្រូវបានធានារ៉ាប់រងត្រូវបង់ឱ្យក្រុមហ៊ុនធានារ៉ាប់រងតាមការកំណត់របស់របស់ក្រុមហ៊ុនធានារ៉ាប់រងនៅក្នុងបណ្ណសន្យារ៉ាប់-រង ។ បុព្វលាភធានារ៉ាប់រង គឺជាផលប្រយោជន៍ដែលក្រុមហ៊ុនធានារ៉ាប់រងទទួលបានពីការបង់របស់អ្នកត្រូវបានធានារ៉ាប់រង ។ ចំពោះរបៀបនៃការបង់បុព្វលាភធានារ៉ាប់រង គឺធ្វើឡើងតាមការព្រមព្រៀងរបស់គូភាគី អ្នកទិញធានារ៉ាប់រងអាចជ្រើសរើសរបៀបបង់បុព្វលាភរ៉ាប់រងប្រចាំខែក៏បាន ឬ បង់ប្រចាំឆ្នាំក៏បាន ។ នៅពេលដែលមានហានិភ័យកើតឡើង ក្រុមហ៊ុនមានកាតព្វកិច្ចធ្វើសំណងធានារ៉ាប់រងឱ្យទៅអ្នកទិញធានារ៉ាប់រង ។ ដោយសារតែកិច្ចសន្យាធានារ៉ាប់រងជាកិច្ចសន្យាមិនទៀង ដូច្នេះក្រុមហ៊ុនធានារ៉ាប់រងមានកាតព្វកិច្ចធ្វើសំណង នៅពេលដែលអ្នកទិញធានារ៉ាប់រងជួបហានិភ័យដូចបានចែងក្នុងកិច្ចសន្យាធានារ៉ាប់រងតែប៉ុណ្ណោះ ។

### ២.១.២. លក្ខខណ្ឌទម្រង់

ទម្រង់នៃកិច្ចសន្យាមានពីរប្រភេទធំៗគឺ ទម្រង់មិនសរសេរ និង ទម្រង់សរសេរ ។ ប៉ុន្តែក្នុងករណីដែលច្បាប់តម្រូវឱ្យសរសេរជាលាយលក្ខណ៍អក្សរ គូភាគីចាំបាច់ត្រូវតែសរសេរជាលាយ-លក្ខណ៍អក្សរ បើមិនដូច្នោះទេ កិច្ចសន្យានោះត្រូវចាត់ទុកជាមោឃៈ ។ ក្រៅពីទម្រង់សរសេរដែលច្បាប់ទាមទារសម្រាប់សុពលភាព ការសរសេរជាលាយលក្ខណ៍អក្សរក៏ជាទម្រង់ភស្តុតាងផងដែរ ។ ចំណែកឯកិច្ចសន្យាធានារ៉ាប់រងច្បាប់តម្រូវឱ្យសរសេរជាលាយលក្ខណ៍អក្សរ ចុះហត្ថលេខាដោយភាគីទាំងពីរ ហើយត្រូវកំណត់រយៈពេល និង លក្ខខណ្ឌផ្សេងៗទាក់ទងនឹងការធានារ៉ាប់រង ។ កិច្ចសន្យាធានារ៉ាប់រង ត្រូវចែងឱ្យបានច្បាស់លាស់អំពីទំនាក់ទំនងរវាងសិទ្ធិ និង កាតព្វកិច្ចរបស់អ្នកត្រូវបានធានារ៉ាប់រង និង ក្រុមហ៊ុនធានារ៉ាប់រង ។ កិច្ចសន្យាធានារ៉ាប់រងត្រូវរៀបចំដោយយកភាសាខ្មែរជាគោល និង ត្រូវមានចុះហត្ថលេខា និង/ឬ ផ្តិតមេដៃរបស់ភាគីទាំងសងខាង[48] ។ កិច្ចសន្យាធានារ៉ាប់រងមានលក្ខណៈស្មុគស្មាញដោយសារតែវាទាមទារឱ្យមានលិខិតឯកសារបញ្ជាក់ជាច្រើន ដើម្បីធ្វើឱ្យមានភាពច្បាស់លាស់អំពីព័ត៌មានរបស់អ្នកដែលត្រូវធានារ៉ាប់រង ដែលនឹងត្រូវផ្តល់ជូនក្រុមហ៊ុនធានារ៉ាប់រងក៏ដូចជាភាពច្បាស់លាស់អំពីប្រភេទនៃការធានារ៉ាប់រង និង អត្ថប្រយោជន៍ផ្សេងទៀតដែលក្រុមហ៊ុនត្រូវផ្តល់ជូនអ្នកដែលត្រូវបានធានារ៉ាប់រង ។

ក្រោយពេលដែលភាគីទាំងពីរបានព្រមព្រៀងគ្នា និង បានចុះកិច្ចសន្យារួចមក ក្រុមហ៊ុនធានារ៉ាប់រងត្រូវចេញបណ្ណសន្យារ៉ាប់រងដែលភ្ជាប់មកជាមួយនូវវិញ្ញាបនបត្រធានារ៉ាប់រង ឬ ចេញកំណត់សំអាង និង/ឬ ឯកសារពាក់ព័ន្ធផ្សេងទៀតទៅឱ្យអ្នកស្នើសុំធានារ៉ាប់រង ។ បណ្ណសន្យារ៉ាប់រងដែលភ្ជាប់មកជាមួយនូវវិញ្ញាបនបត្រធានារ៉ាប់រង និង/ឬ ឯកសារពាក់ព័ន្ធផ្សេងទៀត ត្រូវមានចែងនិងកំណត់ខ្លឹមសារសំខាន់ជាទូទៅដែលបានព្រមព្រៀងជាមុនរវាងភាគីទាំងពីរ[49] ។

#### ២.១.២.១. បណ្ណសន្យារ៉ាប់រង

បណ្ណសន្យារ៉ាប់រង គឺជាឯកសាឆ្លុះបញ្ចាំងអំពីទម្រង់នៃកិច្ចសន្យាធានារ៉ាប់រងដ៏ជាក់លាក់មួយ និង ជាភស្តុតាងនៃកិច្ចសន្យានោះ ។ ឯកសារនេះត្រូវចុះហត្ថលេខាដោយក្រុមហ៊ុនធានារ៉ាប់រង ឬ ភ្នាក់ងារធានារ៉ាប់រង ។ នៅពេលចុះកិច្ចសន្យាធានារ៉ាប់រង អ្នកត្រូវបានធានារ៉ាប់រងអាចពិភាក្សាជាមួយក្រុមហ៊ុនធានារ៉ាប់រង ដើម្បីជ្រើសរើសយកការចុះកិច្ចសន្យារយៈពេលខ្លី ឬ រយៈពេលវែង

[48] មាត្រា ៨ នៃច្បាប់ស្តីពីការធានារ៉ាប់រង, ចុះថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០១៤
[49] មាត្រា ១១ កថាខណ្ឌទី២ នៃច្បាប់ដដែល

បានតាមការព្រមព្រៀងគ្នា[50] ។ វីអាចហៅបានម៉្យាងទៀតថា បណ្ណសន្យារ៉ាប់រង សំដៅដល់ឯកសារចងភ្ជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ដែលចេញដោយក្រុមហ៊ុនធានារ៉ាប់រង ដោយកំណត់អំពីខ្លឹមសារសំខាន់ និង ចែងពីលក្ខខណ្ឌលម្អិតដែលបានព្រមព្រៀងរវាងក្រុមហ៊ុនធានារ៉ាប់រង និង អ្នកត្រូវបានធានារ៉ាប់រងនៅក្នុងកិច្ចសន្យាធានារ៉ាប់រង ។ បណ្ណសន្យារ៉ាប់រងត្រូវភ្ជាប់មកជាមួយនូវវិញ្ញាបនបត្រធានារ៉ាប់រង ឬ ឯកសារពាក់ព័ន្ធផ្សេងៗទៀត[51] ។

បណ្ណសន្យារ៉ាប់រង គឺជាតឹកតាងនៃកិច្ចសន្យាធានារ៉ាប់រងដែលធ្វើឡើងជាលាយលក្ខណ៍អក្សរដោយមានការចុះបំពេញនូវគោលបំណងរបស់អ្នកត្រូវបានធានារ៉ាប់រង ក្រោមការឯកភាពគ្នារវាងភាគីទាំងសងខាងនៃកិច្ចសន្យា ។ លក្ខខណ្ឌនៃបណ្ណសន្យារ៉ាប់រងត្រូវបែងចែកជាពីរផ្នែកចម្បងៗ គឺ លក្ខខណ្ឌទូទៅ និង លក្ខខណ្ឌដោយឡែក ។ លក្ខខណ្ឌទូទៅ គឺជាឯកសារដែលមានកំណត់នូវគោលការណ៍សំខាន់ពីរ ស្តីអំពី ៖ ប្រភេទហានិភ័យដែលត្រូវបានទទួលធានារ៉ាប់រងឱ្យ និង ប្រភេទហានិភ័យដែលមិនត្រូវបានទទួលធានារ៉ាប់រងឱ្យ ។ លក្ខខណ្ឌដោយឡែក ហៅថា ‹ វិញ្ញាបនបត្រធានារ៉ាប់រង › គឺជាឯកសារដែលមានការចុះបំពេញនូវសំណូមពរដោយឡែករបស់អ្នកត្រូវបានធានារ៉ាប់រង តាមការប្រកាសនៅក្នុងពាក្យស្នើសុំធានារ៉ាប់រងរបស់ខ្លួន ដែលត្រូវមានហត្ថលេខាពីក្រុមហ៊ុនធានារ៉ាប់រង[52] ។

### ២.១.២.២. វិញ្ញាបនបត្រធានារ៉ាប់រង

វិញ្ញាបនបត្រធានារ៉ាប់រង សំដៅដល់ឯកសារដែលចេញដោយក្រុមហ៊ុនធានារ៉ាប់រងដើម្បីបញ្ជាក់ថាអ្នកត្រូវបានធានារ៉ាប់រងបានទិញការធានារ៉ាប់រងពីក្រុមហ៊ុនធានារ៉ាប់រង[53] ។ វិញ្ញាបនបត្រធានារ៉ាប់រងត្រូវបញ្ជាក់អំពី ៖ គោត្តនាម នាម និង អាសយដ្ឋានរបស់គូភាគីនៃកិច្ចសន្យា ។ បុគ្គល ឬ វត្ថុដែលត្រូវបានធានារ៉ាប់រង ។ ប្រភេទហានិភ័យដែលត្រូវបានធានារ៉ាប់រង ។ ពេលវេលាចាប់ផ្តើម និង ទីកន្លែងនៃហានិភ័យដែលត្រូវបានធានារ៉ាប់រង ។ ចំនួនទឹកប្រាក់ដែលត្រូវបានធានារ៉ាប់រង ។ បុព្វលាភធានារ៉ាប់រងដែលត្រូវបង់ និង របៀបបង់បុព្វលាភធានារ៉ាប់រង ។ របៀប និង លក្ខខណ្ឌមួយចំនួននៃសេចក្តីប្រកាសគ្រោះថ្នាក់ ។ រយៈពេលនៃកិច្ចសន្យា និង រយៈពេលនៃការធានារ៉ាប់រង ។ លក្ខខណ្ឌទាំងឡាយដែលកំណត់មោឃភាព និងការបាត់បង់សិទ្ធិព្រមទាំងលក្ខខណ្ឌដែលអនុញ្ញាតឱ្យគូភាគីនីមួយៗបញ្ឈប់កិច្ចសន្យាបានមុនកាលកំណត់ ។ ក្រៅពីចំណុចដែលមានកំណត់ខាងលើ

---

[50] មាត្រា ៨ កថាខណ្ឌទី២ នៃអនុក្រឹត្យស្តីពីការធានារ៉ាប់រង, ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០១

[51] មាត្រា ៩ កថាខណ្ឌទី៧ នៃច្បាប់ស្តីពីការធានារ៉ាប់រង, ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៤

[52] មាត្រា ១០ នៃអនុក្រឹត្យដដែល

[53] មាត្រា ៩ កថាខណ្ឌទី ១២ នៃច្បាប់ដដែល

គូភាគីអាចដាក់បន្ថែមនូវចំណុចផ្សេងៗទៀតបានដោយមានការព្រមព្រៀងគ្នាជាមុន[54] ។

#### ២.១.២.៣. កំណត់សំអាង

ក្នុងករណីចាំបាច់ និង បន្ទាន់ដែលមិនអាចធ្វើកិច្ចសន្យា និង ចេញបណ្ណសន្យាធានារ៉ាប់រងបាន នោះការធានារ៉ាប់រងអាចប្រព្រឹត្តទៅបាន ដោយប្រើ ‹ កំណត់សំអាង › ជំនួសជាបណ្ដោះអាសន្ន ។ កំណត់សំអាង គឺជាឯកសារដែលចេញដោយក្រុមហ៊ុនធានារ៉ាប់រង ឬ ភ្នាក់ងារធានារ៉ាប់រង ។ ឯកសារនេះជំនួសបណ្ណសន្យារ៉ាប់រង ឬ ជាកិច្ចសន្យាបន្ថែម ក្នុងពេលរង់ចាំការចេញបណ្ណសន្យារ៉ាប់រងជាស្ថាពរ ។ នៅពេលចេញកំណត់សំអាង ភាគីទាំងសងខាងត្រូវចុះហត្ថលេខា ហើយអ្នកត្រូវបានធានារ៉ាប់រងត្រូវបង់បុព្វលាភរ៉ាប់រង តាមការព្រមព្រៀងគ្នាដូចមានចែងក្នុងបណ្ណសន្យារ៉ាប់រងនោះស្រាប់[55] ។

## ២.២. អានុភាពនៃកិច្ចសន្យាធានារ៉ាប់រង

នៅពេលដែលកិច្ចសន្យាធានារ៉ាប់រងមានសុពលភាព កិច្ចសន្យានោះនឹងមានអានុភាពដែលបង្កើតឡើងនូវសិទ្ធិ និង កាតព្វកិច្ចចំពោះគូភាគីនៃកិច្ចសន្យានោះ ។ ការប្រើសិទ្ធិ និង ការអនុវត្តកាតព្វកិច្ចរបស់គូភាគីនៃកិច្ចសន្យាធានារ៉ាប់រងត្រូវគោរពតាមគោលការណ៍សុចរិត និង ភាពស្មោះត្រង់ដើម្បីផ្ដល់ភាពកក់ក្ដៅ ក៏ដូចជាទំនុកចិត្តដល់គ្នាទៅវិញទៅមក ជៀសវាងការកើតមាននូវវិវាទផ្សេងៗ ។

### ២.២.១. សិទ្ធិ និង កាតព្វកិច្ចរបស់ក្រុមហ៊ុនធានារ៉ាប់រង

បន្ទាប់ពីចុះកិច្ចសន្យាធានារ៉ាប់រងរួចហើយ ក្រុមហ៊ុនធានារ៉ាប់រងមានសិទ្ធិ និង កាតព្វកិច្ចចំពោះអ្នកទិញធានារ៉ាប់រងដូចជា ៖

#### ២.២.១.១. សិទ្ធិទទួលបានបុព្វលាភ

ក្រុមហ៊ុនធានារ៉ាប់រងមានសិទ្ធិទទួលបាននូវបុព្វលាភពីអ្នកត្រូវបានធានារ៉ាប់រង ឬ ម្ចាស់បណ្ណសន្យារ៉ាប់រងតាមកាលកំណត់ដែលមានចែងនៅក្នុងកាលវិភាគនៃបុព្វលាភរ៉ាប់រង ។

#### ២.២.១.២. កាតព្វកិច្ចពន្យល់

ក្រុមហ៊ុនធានារ៉ាប់រង មានកាតព្វកិច្ចពន្យល់អ្នកត្រូវបានធានារ៉ាប់រងឱ្យបានយល់ច្បាស់អំពី

[54] មាត្រា ១២ នៃច្បាប់ស្ដីពីការធានារ៉ាប់រង, ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៤

[55] មាត្រា ៩ នៃអនុក្រឹត្យស្ដីពីការធានារ៉ាប់រង, ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០១

លក្ខខណ្ឌនៃកិច្ចសន្យាធានារ៉ាប់រង និង ខ្លឹមសារនៃបណ្ណសន្យារ៉ាប់រងដែលភ្ជាប់ជាមួយនឹងវិញ្ញាបនបត្រធានារ៉ាប់រង និង/ឬ ឯកសារពាក់ព័ន្ធផ្សេងៗ[56] ។ នៅក្នុងករណីដែលអ្នកធានារ៉ាប់រងប្រាប់ព័ត៌មានមិនពិត ឬ លាក់បាំងនូវហេតុផលពិតប្រាកដដោយចេតនា ហើយអ្នកត្រូវបានធានារ៉ាប់រងបានបង្ហាញឆន្ទៈដោយផ្អែកទៅលើការភាន់ច្រឡំ នោះអ្នកត្រូវបានធានារ៉ាប់រងអាចលុបចោលកិច្ចសន្យាធានារ៉ាប់រងដោយ ផ្អែកលើមាត្រាដែលទាក់ទងនឹងវិការៈនៅក្នុងការបង្ហាញឆន្ទៈ ។

#### ២.២.១.៣. កាតព្វកិច្ចធ្វើសំណង

ក្រុមហ៊ុនធានារ៉ាប់រង មានកាតព្វកិច្ចធ្វើសំណងចំពោះការខូចខាត ឬ ការបាត់បង់ នៅពេលមានហានិភ័យកើតឡើងបណ្តាលមកពីមូលហេតុចៃដន្យ គ្រោះថ្នាក់ធម្មជាតិ និង រាល់មូលហេតុដែលមិនមែនជាអំពើចេតនារបស់អ្នករបស់អ្នកត្រូវបានធានារ៉ាប់រង ។ ក្រុមហ៊ុនធានារ៉ាប់រងធានាផងដែរ ចំពោះការបាត់បង់ និង ការខូចខាតដែលបង្កឡើងដោយបុគ្គលទាំងឡាយដែលស្ថិតក្រោមការទទួលខុសត្រូវរបស់អ្នកត្រូវបានធានារ៉ាប់រង ទោះជាប្រភេទ និង ភាពធ្ងន់ធ្ងរនៃកំហុសទាំងនោះបែបណាក៏ដោយ ។ ហើយក្រុមហ៊ុនត្រូវធ្វើសំណងត្រឹមត្រូវតាមពេលវេលាកំណត់តាមទំហំនៃការខូចខាតជាក់ស្តែង និង តាមទឹកប្រាក់ធានារ៉ាប់រង[57] ។ ប៉ុន្តែក្រុមហ៊ុនធានារ៉ាប់រង មិនធ្វើសំណងចំពោះការបាត់បង់ ឬ ការខូចខាតទាំងឡាយណាដែលបណ្តាលមកពីកំហុសដោយចេតនា ឬដោយបន្លំបោកប្រាស់របស់អ្នកត្រូវបានធានារ៉ាប់រងឡើយ[58] ។

### ២.២.២. សិទ្ធិ និង កាតព្វកិច្ចរបស់អ្នកទិញធានារ៉ាប់រង

បន្ទាប់ពីបានចុះកិច្ចសន្យាធានារ៉ាប់រងរួចមក អ្នកទិញធានារ៉ាប់រងមានសិទ្ធិ និង កាតព្វកិច្ចចំពោះក្រុមហ៊ុនធានារ៉ាប់រងដូចជា ៖

#### ២.២.២.១. សិទ្ធិទទួលបានប្រាក់សំណងធានារ៉ាប់រង

នៅពេលដែលមានហានិភ័យ ឬ គ្រោះថ្នាក់កើតឡើងដូចដែលបានកំណត់នៅក្នុងបណ្ណសន្យារ៉ាប់រង អ្នកត្រូវបានធានារ៉ាប់រងមានសិទ្ធិទាមទារសំណងធានារ៉ាប់រងពីក្រុមហ៊ុនធានារ៉ាប់រង ។ សំណងធានារ៉ាប់រង សំដៅដល់សំណងជាប្រាក់ ឬ វត្ថុ សំណងរួមជាប្រាក់និងជាវត្ថុដែលត្រូវសងដោយក្រុមហ៊ុនធានារ៉ាប់រង ។

---

[56] មាត្រា ១០ នៃច្បាប់ស្តីពីការធានារ៉ាប់រង, ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៤

[57] មាត្រា ៧ នៃអនុក្រឹត្យស្តីពីការធានារ៉ាប់រង, ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០១

[58] មាត្រា ១៨ នៃច្បាប់ដដែល

### ២.២.២.២. សិទ្ធិធ្វើអនុប្បទានការធានារ៉ាប់រង

ក្នុងករណីដែលវត្ថុក្នុងការធានារ៉ាប់រងត្រូវបានលក់បន្ត ការធានារ៉ាប់រងនោះអាចត្រូវបន្តទៅទៀត បាននៅក្រោមលក្ខខណ្ឌដែលម្ចាស់កម្មសិទ្ធិថ្មីបានជូនដំណឹងភ្លាមទៅក្រុមហ៊ុនធានារ៉ាប់រង ហើយសុំឱ្យធ្វើកិច្ចសន្យាបន្ថែម ដើម្បីផ្ទេរការធានារ៉ាប់រងមកឈ្មោះរបស់ខ្លួនជាផ្លូវការ ។ អ្នកលក់បន្តនៅតែមានកាតព្វកិច្ចបង់បុព្វលាភរ៉ាប់រងរហូតតាមកិច្ចសន្យា ប្រសិនបើគេមិនបានជូនដំណឹងពីការលក់បន្តនោះទៅក្រុមហ៊ុនធានារ៉ាប់រងរបស់ខ្លួន តាមរយៈលិខិតអនុសិដ្ឋ ឬ លិខិតជូនដំណឹងដែលត្រូវបញ្ជាក់តបវិញច្បាស់លាស់ពីការបានទទួលនោះទេ ។ ប៉ុន្តែក្រុមហ៊ុនធានារ៉ាប់រង និងម្ចាស់កម្មសិទ្ធិថ្មី មានសិទ្ធិលុបចោលជាស្ថាពរនូវកិច្ចសន្យាធានារ៉ាប់រងពីខាងដើម[59] ។

### ២.២.២.៣. សិទ្ធិសុំដកមកវិញនូវបុព្វលាភនៅពេលធ្វើអនុប្បទាន

អ្នកដែលបានលក់បន្តនូវកម្មវត្ថុក្នុងការធានារ៉ាប់រង មានសិទ្ធិសុំដកមកវិញនូវបុព្វលាភរ៉ាប់រងចំនួនកៅសិបភាគរយ ( ៩០% ) នៃទឹកប្រាក់សម្រាប់រយៈពេលដែលនៅសល់ ក្រោយពីបានជូនដំណឹងទៅក្រុមហ៊ុនធានារ៉ាប់រងរបស់ខ្លួន តាមរយៈលិខិតជាផ្លូវការដែលត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយឺតបំផុតម្ភៃបួនម៉ោងបន្ទាប់ពីការលក់ និង ប្រសិនបើម្ចាស់កម្មសិទ្ធិថ្មីមិនបានមកសុំឱ្យធ្វើកិច្ចសន្យាបន្ថែម ដើម្បីផ្ទេរកិច្ចសន្យាពីខាងដើមមកឈ្មោះរបស់ខ្លួននៅឡើយទេ[60] ។

### ២.២.២.៤. កាតព្វកិច្ចបង់បុព្វលាភរ៉ាប់រង

បន្ទាប់ពីបានធ្វើកិច្ចសន្យាធានារ៉ាប់រងរួចហើយ អ្នកត្រូវបានធានារ៉ាប់រងត្រូវបង់បុព្វលាភធានារ៉ាប់រងជូនក្រុមហ៊ុនធានារ៉ាប់រងគ្រប់ចំនួនតាមការព្រមព្រៀងគ្នាក្នុងកិច្ចសន្យា ។ ការបង់បុព្វលាភរ៉ាប់រងចំពោះហានិភ័យណាមួយគឺជាកាតព្វកិច្ចទីមួយរបស់អ្នកត្រូវបានធានារ៉ាប់រង ។ បុព្វលាភរ៉ាប់រងត្រូវបង់ត្រឹមត្រូវតាមរយៈពេលធានា និង តាមចំនួនទឹកប្រាក់ធានារ៉ាប់រងសរុបដោយគិតផ្អែកលើមូលដ្ឋាននៃតារាងបុព្វលាភរ៉ាប់រងរបស់ក្រុមហ៊ុននីមួយៗ ។ ក្នុងការបង់បុព្វលាភអ្នកត្រូវបានធានារ៉ាប់រងអាចពិភាក្សាហើយព្រមព្រៀងជាមួយក្រុមហ៊ុនធានារ៉ាប់រង ដើម្បីធ្វើការបង់តែមួយលើក ឬ ច្រើនលើកបាន[61] ។

### ២.២.២.៥. កាតព្វកិច្ចជូនដំណឹង

អ្នកត្រូវបានធានារ៉ាប់រងត្រូវជូនដំណឹងដល់ក្រុមហ៊ុនធានារ៉ាប់រងឱ្យបានឆាប់រហ័សបំផុតនៅ

[59] មាត្រា ២១ នៃអនុក្រឹត្យស្តីពីការធានារ៉ាប់រង, ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០១

[60] មាត្រា ២២ នៃអនុក្រឹត្យដដែល

[61] មាត្រា ១១ នៃអនុក្រឹត្យដដែល

ពេលមានហានិភ័យកើតឡើង ដើម្បីទទួលបានសំណងពីក្រុមហ៊ុនធានារ៉ាប់រង[62] ។ ក្នុងករណីមួយចំនួនទៀត ដូចជា ករណីដែលអ្នកត្រូវបានធានារ៉ាប់រងមានបំណងសុំបញ្ឈប់ការធានារ៉ាប់រងមុនកាលកំណត់ ៖ ករណីសុំផ្អាកសកម្មភាពដើម្បីធ្វើការជួសជុលធំ ករណីដែលអ្នកត្រូវបានធានារ៉ាប់រងធនក្ស័យមុនកាលកំណត់ដែលចែងក្នុងកិច្ចសន្យាធានារ៉ាប់រង អ្នកត្រូវបានធានារ៉ាប់រងចាំបាច់ត្រូវជូនដំណឹងមកក្រុមហ៊ុនធានារ៉ាប់រង នៅក្នុងរយៈពេលដប់ថ្ងៃយ៉ាងយូរបំផុត[63] ។

#### ២.២.២.៦. ភាតព្វកិច្ចសហការ

អ្នកត្រូវបានធានារ៉ាប់រងត្រូវសហការផ្តល់ព័ត៌មាន និង ឯកសារដែលពាក់ព័ន្ធដល់ហានិភ័យតាមសំណូមពររបស់ក្រុមហ៊ុនធានារ៉ាប់រង[64] ។

## ២.៣. ការបញ្ចប់កិច្ចសន្យាធានារ៉ាប់រង

មូលហេតុដែលនាំឱ្យកិច្ចសន្យាធានារ៉ាប់រងត្រូវបានបញ្ចប់មានមូលហេតុជាច្រើនដូចជា ៖ ការបញ្ចប់កិច្ចសន្យាធានារ៉ាប់រងតាមរយៈការកំណត់របស់ច្បាប់ ការលុបចោលកិច្ចសន្យាធានារ៉ាប់រង និង តាមការព្រមព្រៀង ។

### ២.៣.១. តាមការកំណត់របស់ច្បាប់

ច្បាប់ស្តីពីការធានារ៉ាប់រង ឆ្នាំ២០១៤ បានអនុញ្ញាតឱ្យភាគីអាចបញ្ចប់កិច្ចសន្យាធានារ៉ាប់រងមុនកាលកំណត់បាន ប៉ុន្តែត្រូវមានមូលហេតុសមរម្យ ត្រឹមត្រូវតាមរយៈបទបញ្ញត្តិជាធរមាន ។ ក្នុងករណីដែលមានបំណងសុំបញ្ឈប់ការធានារ៉ាប់រងមុនកាលកំណត់ អ្នកត្រូវបានធានារ៉ាប់រងសាមីចាំបាច់ត្រូវជូនដំណឹងឱ្យក្រុមហ៊ុនធានារ៉ាប់រងរបស់ខ្លួនបានដឹងមុនចំនួនដប់ថ្ងៃយ៉ាងតិច ។ ផ្អែកលើមូលហេតុសមស្រប ក្រុមហ៊ុនធានារ៉ាប់រងនឹងបង្វិលសងវិញចំនួនកៅសិបភាគរយ (៩០%) នៃបុព្វលាភរ៉ាប់រងដែលនៅសល់ ។ ក្នុងករណីសុំបញ្ឈប់ការធានារ៉ាប់រងក្រោយពេលមានហានិភ័យកើតឡើង ហើយក្រុមហ៊ុនបានទូទាត់សំណងរួចហើយនោះ បុព្វលាភរ៉ាប់រងចំពោះរយៈពេលដែលនៅសល់មិនត្រូវបានក្រុមហ៊ុនធានារ៉ាប់រងបង្វិលសងវិញឡើយ[65] ។ មូលហេតុដែលអាចសុំបញ្ចប់កិច្ចសន្យាធានារ៉ាប់រងមានដូចជា ៖

---

[62] មាត្រា ៦ នៃអនុក្រឹត្យស្តីពីការធានារ៉ាប់រង, ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០១
[63] មាត្រា ១២ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃអនុក្រឹត្យដដែល
[64] មាត្រា ៦ កថាខណ្ឌទី៣ នៃអនុក្រឹត្យដដែល
[65] មាត្រា ១២ នៃអនុក្រឹត្យដដែល

### ២.៣.១.១. ការជួសជុលធំ

ក្នុងករណីសុំផ្អាកសកម្មភាពដើម្បីធ្វើការជួសជុលធំ អ្នកត្រូវបានធានារ៉ាប់រងសាមីចាំបាច់ត្រូវជូនដំណឹងដល់ក្រុមហ៊ុនធានារ៉ាប់រងរបស់ខ្លួនជាមុនចំនួនដប់ថ្ងៃយ៉ាងតិច ។ ក្រុមហ៊ុនធានារ៉ាប់រងនឹងទូទាត់សងវិញ បន្ទាប់ពីពេលចាប់ដំណើរការឡើងវិញ នូវចំនួនកៅសិបភាគរយ (៩០%) នៃបុព្វលាភរ៉ាប់រងសម្រាប់រយៈពេលដែលបានផ្អាក[66] ។

### ២.៣.១.២. ធនក្ស័យ

ក្នុងករណីដែលអ្នកត្រូវបានធានារ៉ាប់រងធនក្ស័យមុនកាលកំណត់ដែលចែងក្នុងកិច្ចសន្យាធានារ៉ាប់រង ចាំបាច់ត្រូវមានការជូនដំណឹងមកក្រុមហ៊ុនធានារ៉ាប់រង នៅក្នុងរយៈពេលដប់ថ្ងៃយ៉ាងយឺតបំផុត មុនការប្រកាសធនក្ស័យតាមរយៈលិខិតអនុសិដ្ឋ ឬ លិខិតជូនដំណឹងដែលត្រូវបញ្ជាក់តបវិញច្បាស់លាស់ពីការបានទទួល ។ ក្រុមហ៊ុនធានារ៉ាប់រងនឹងបង្វិលសងវិញចំនួន កៅសិបភាគរយ ( ៩០% ) នៃបុព្វលាភធានារ៉ាប់រងដែលនៅសល់[67] ។

### ២.៣.១.៣. មរណភាព

ក្នុងករណីដែលអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព ការធានារ៉ាប់រងត្រូវធ្លាក់ទៅលើទាយាទនៃវត្ថុដែលត្រូវបានធានារ៉ាប់រង ។ ទាយាទជាអ្នកទទួលមរតកបន្តនោះមានកាតព្វកិច្ចដូចអ្នកត្រូវបានធានារ៉ាប់រងដែរ ។ ផ្តើមចេញពីលក្ខខណ្ឌនេះ ទាយាទត្រូវជូនដំណឹងដល់ក្រុមហ៊ុនធានារ៉ាប់រងពីមរណភាពនៃអ្នកត្រូវបានធានារ៉ាប់រងពីខាងដើម ហើយសុំឱ្យធ្វើកិច្ចសន្យាបន្ថែមដើម្បីផ្ទេរការធានារ៉ាប់រងនោះមកឈ្មោះរបស់ខ្លួនជាផ្លូវការ ។ ប៉ុន្តែ ក្រុមហ៊ុនធានារ៉ាប់រង និង ទាយាទមានសិទ្ធិលុបចោលជាស្ថាពរ នូវកិច្ចសន្យាធានារ៉ាប់រងពីខាងដើមនោះបាន[68] ។ ចំពោះការធានារ៉ាប់រងអាយុជីវិត នៅពេលដែលអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព អ្នកទទួលផលត្រូវទទួលបានផលប្រយោជន៍ជាប្រាក់សំណងរ៉ាប់រងពីក្រុមហ៊ុនធានារ៉ាបរង ។ ប៉ុន្តែអ្នកទទួលផលមិនអាចទទួលផលប្រយោជន៍ពីការធានារ៉ាប់រងអាយុជីវិតបានទេ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងធ្វើអត្តឃាត ឬ អ្នកទទួលផលនោះជាចារី សហចារី អ្នកផ្តើមគំនិត ឬ អ្នកសមគំនិតក្នុងការប្រព្រឹត្តបទឃាតកម្មទៅលើអ្នកត្រូវបានធានារ៉ាប់រង[69] ។

---

[66] មាត្រា ១៣ នៃអនុក្រឹត្យស្តីពីការធានារ៉ាប់រង, ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០១

[67] មាត្រា ១៤ នៃអនុក្រឹត្យដដែល

[68] មាត្រា ២០ នៃអនុក្រឹត្យដដែល

[69] មាត្រា ៣០ និង មាត្រា ៣១ នៃច្បាប់ស្តីពីការធានារ៉ាប់រង, ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៤

### ២.៣.១.៤. ការបាត់បង់ទាំងស្រុងនូវកម្មវត្ថុ

ករណីមានការបាត់បង់ទាំងស្រុងនូវកម្មវត្ថុដែលត្រូវបានធានារ៉ាប់រងបណ្តាលមកពីហេតុការណ៍ណាមួយដែលពុំបានគ្រោងទុកជាមុនក្នុងបណ្ណសន្យារ៉ាប់រងទេ ការធានារ៉ាប់រងត្រូវបញ្ចប់ដោយស្របច្បាប់ ហើយក្រុមហ៊ុនធានារ៉ាប់រងត្រូវសងទៅអ្នកត្រូវបានធានារ៉ាប់រងវិញចំនួន ៩០% នៃបុព្វលាភធានារ៉ាប់រងចំពោះរយៈពេលដែលនៅសល់[70] ។

### ២.៣.២. ការលុបចោលកិច្ចសន្យា

មូលហេតុដែលនាំឱ្យកិច្ចសន្យាធានារ៉ាប់រងត្រូវបានលុបចោលមានដូចជា ៖ ការមិនអនុវត្តកាតព្វកិច្ចរបស់អ្នកទិញធានារ៉ាប់រង ការលាក់លៀម ឬ ធ្វើប្រតិវេទន៍ខុស និង វិការៈក្នុងការបង្ហាញឆន្ទៈ ។

### ២.៣.២.១. ការមិនអនុវត្តកាតព្វកិច្ចរបស់អ្នកទិញធានារ៉ាប់រង

ក្នុងករណីដែលអ្នកត្រូវបានធានារ៉ាប់រងពុំបានបង់បុព្វលាភធានារ៉ាប់រងណាមួយ តាមកាលកំណត់នោះ សុពលភាពនៃកិច្ចសន្យាធានារ៉ាប់រងមិនអាចព្យួរទុកឱ្យហួសពីរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតពីកាលបរិច្ឆេទនៃការចុះហត្ថលេខាលើកិច្ចសន្យាធានារ៉ាប់រងឡើយ ។ ២០ (ម្ភៃ) ថ្ងៃក្រោយពីការចុះកិច្ចសន្យាធានារ៉ាប់រង ក្រុមហ៊ុនធានារ៉ាប់រងត្រូវជូនដំណឹងដោយលិខិតអនុសិដ្ឋ ឬ ដោយលិខិតដែលមានបញ្ជាក់ការទទួលច្បាស់លាស់ដល់អ្នកត្រូវបានធានារ៉ាប់រង ឬ ម្ចាស់បណ្ណ-សន្យារ៉ាប់រងឱ្យយកបុព្វលាភធានារ៉ាប់រងមកបង់នៅទីកន្លែងដែលព្រមព្រៀងគ្នា ។ ក្រោយពីបានទទួលដំណឹងរួចហើយ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រង ឬ ម្ចាស់បណ្ណសន្យារ៉ាប់រងនៅតែមិនមកបង់បុព្វលាភធានារ៉ាប់រងក្នុងរយៈពេល ១០ (ដប់) ថ្ងៃ នោះក្រុមហ៊ុនធានារ៉ាប់រងមានសិទ្ធិលុបចោលកិច្ចសន្យាចោល[71] ។

### ២.៣.២.២. ការលាក់លៀម ឬ ធ្វើប្រតិវេទន៍ខុស

កិច្ចសន្យាធានារ៉ាប់រងអាចត្រូវបានលុបចោល នៅពេលដែលក្រុមហ៊ុនធានារ៉ាប់រងបានរកឃើញថាអ្នកត្រូវបានធានារ៉ាប់រងមានការលាក់លៀម ឬ ធ្វើប្រតិវេទន៍ខុសដោយចេតនាហើយបណ្តាលឱ្យមានការផ្លាស់ប្តូរកម្មវត្ថុនៃហានិភ័យ ។ ការភ្លេចភ្លាំង ឬ ការធ្វើប្រតិវេទន៍មិនច្បាស់លាស់

---

[70] មាត្រា ២៤ នៃច្បាប់ស្តីពីការធានារ៉ាប់រង, ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៤

[71] មាត្រា ១៧ នៃច្បាប់ដដែល

ដោយអចេតនារបស់អ្នកត្រូវបានធានារ៉ាប់រង នឹងមិននាំទៅដល់ការលុបចោលនូវការធានារ៉ាប់រងទេ[72] ។

#### ២.៣.២.៣. វិការៈក្នុងការបង្ហាញឆន្ទៈ

ជាទូទៅ កិច្ចសន្យាដែលត្រូវបានបង្កើតឡើងដោយដោយការព្រមព្រៀងរបស់គូភាគី មានកម្មវត្ថុស្របច្បាប់ ហើយធ្វើឡើងដោយសមត្ថជន នោះកិច្ចសន្យានឹងមានអានុភាពអនុវត្ត ។ ប៉ុន្តែនៅក្នុងករណីមួយចំនួនកិច្ចសន្យាដែលបំពេញគ្រប់លក្ខខណ្ឌខាងលើ នៅតែត្រូវបានលុបចោលដោយសារមានវិការៈតាមរូបភាពមួយចំនួន ដូចជា ការភាន់ច្រឡំ ការឆបោក ការគម្រាមកំហែង ព័ត៌មានមិនពិត ជាដើម (មាត្រា ៣៩៥ នៃក្រមរដ្ឋប្បវេណី) ។ សកម្មភាពដែលមានវិការៈទាំងនេះត្រូវបានគេហៅថា សកម្មភាពដែលអាចលុបចោលបាន (មាត្រា ៣៥៨ នៃក្រមរដ្ឋប្បវេណី) ។

ដូច្នេះ ប្រសិនបើមានភាគីណាម្ខាងនៃកិច្ចសន្យាធានារ៉ាប់រងបានធ្វើការបង្ហាញឆន្ទៈដោយមានវិការៈ នោះគេអាចធ្វើការលុបចោលកិច្ចសន្យានោះបាន ដោយយោងតាមបទបញ្ញត្តិស្តីពីវិការៈក្នុងការបង្ហាញឆន្ទៈ ដែលមានចែងក្នុងក្រមរដ្ឋប្បវេណី ។

### ២.៣.៣. ការព្រមព្រៀង

ក្រៅពីមូលហេតុពីរដូចបានបកស្រាយខាងលើ គូភាគីអាចបញ្ចប់កិច្ចសន្យាធានារ៉ាប់រងបានតាមរយៈការព្រមព្រៀង ។ កិច្ចសន្យាធានារ៉ាប់រងនឹងត្រូវបញ្ចប់នៅពេលដែលកាលបរិច្ឆេទបញ្ចប់ដល់កាលកំណត់ និង ការបញ្ចប់មុនកាលកំណត់តាមការព្រមព្រៀងគ្នា ។

#### ២.៣.៣.១. ការបញ្ចប់មុនកាលកំណត់

មាត្រា ២២ នៃច្បាប់ស្តីពីការធានារ៉ាប់រង ឆ្នាំ ២០១៤ បានអនុញ្ញាតឱ្យភាគីនៃកិច្ចសន្យាធានារ៉ាប់រងមានសិទ្ធិបញ្ចប់កិច្ចសន្យាមុនកាលកំណត់បាន ។ លក្ខខណ្ឌនិងនីតិវិធីនៃការបញ្ចប់កិច្ចសន្យាមុនកាលកំណត់ ត្រូវកំណត់ដោយអនុក្រឹត្យ ប៉ុន្តែមកទល់ពេលនេះ អនុក្រឹត្យមួយនេះមិនទាន់បានអនុម័តនៅឡើយទេ ។ ដូច្នេះភាគីអាចបញ្ចប់កិច្ចសន្យាធានារ៉ាប់រងមុនកាលកំណត់បានតាមការព្រមព្រៀងគ្នាដូចមានចែងក្នុងកិច្ចសន្យាធានារ៉ាប់រង ។

#### ២.៣.៣.២. កាលបរិច្ឆេទដល់កាលកំណត់

យោងតាម វាក្យខណ្ឌទី ១ មាត្រា ១៤ នៃច្បាប់ធានារ៉ាប់រង ឆ្នាំ ២០១៤ បានចែងថា រយៈពេលនៃកិច្ចសន្យាធានារ៉ាប់រងមានកំណត់នៅក្នុងបណ្ណសន្យារ៉ាប់រង ។ រយៈពេលនៃកិច្ចសន្យាធានារ៉ាប់រង

[72] មាត្រា ១៩ នៃច្បាប់ស្តីពីការធានារ៉ាប់រង, ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៤

ឬ រយៈពេលនៃបណ្ណសន្យារ៉ាប់រង គឺជារយៈពេលដែលគិតចាប់ពីកាលបរិច្ឆេទបណ្ណសន្យារ៉ាប់រងចាប់ផ្តើមមានសុពលភាព រហូតដល់កាលបរិច្ឆេទដល់កាលកំណត់នៃបណ្ណសន្យារ៉ាប់រង ។ ដូច្នេះ កិច្ចសន្យាធានារ៉ាប់នឹងអស់សុពលភាពនៅកាលបរិច្ឆេទដល់កាលកំណត់ ដែលបានចែងនៅក្នុងបណ្ណសន្យាធានារ៉ាប់រង ។

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានបកស្រាយប្រធានបទ ប្រតិបត្តិការធានារ៉ាប់រង រួចមក យើងឃើញថា ការធានារ៉ាប់រងមានដូចជា ការធានារ៉ាប់រងទូទៅ និង ការធានារ៉ាប់រងអាយុជីវិតដែលកំពុងតែត្រូវបានក្រុមហ៊ុនធានារ៉ាប់រងមួយចំនួនធ្វើប្រតិបត្តិការនៅក្នុងទីផ្សារកម្ពុជានាពេលបច្ចុប្បន្ននេះ ។

វិស័យធានារ៉ាប់រងនៅកម្ពុជាមានលក្ខណៈក្មេងខ្ចីនៅឡើយ បើប្រៀបធៀបទៅនឹងបណ្តាប្រទេសមួយចំនួននៅលើពិភពលោក ។ ទោះបីជាយ៉ាងណាក៏ដោយ រាជរដ្ឋាភិបាលបាននិងកំពុងតែយកចិត្តទុកដាក់ ប្រឹងប្រែងកំណត់ដាក់ចេញនូវយុទ្ធសាស្ត្រនិងផែនការអនាគត ដែលមានចែងនៅក្នុង ‹យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០› ដើម្បីធ្វើការអភិវឌ្ឍវិស័យធានារ៉ាប់រងនេះកាន់តែមានការរីកចម្រើនបន្ថែមទៀត ។ លើសពីនេះ រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងក្នុងការរៀបចំកសាងនូវលិខិតបទដ្ឋានគតិយុត្តនានា ដូចជា ច្បាប់ អនុក្រឹត្យ ប្រកាស ជាដើម ដើម្បីជាជំនួយនៅក្នុងប្រតិបត្តិការធានារ៉ាប់រងឱ្យកាន់តែមានប្រសិទ្ធិភាព ។

តែទោះបីជាយ៉ាងនេះក្តី នៅក្នុងការអនុវត្តជាក់ស្តែង យើងឃើញថាលិខិតបទដ្ឋានគតិយុត្តជាធរមាននៅភាពខ្វះចន្លោះនៅឡើយ មិនទាន់គ្រប់គ្រាន់ និង បំពេញតាមសេចក្តីត្រូវការនៃប្រតិបត្តិ-ការធានារ៉ាប់រងក្នុងពេលបច្ចុប្បន្នឡើយ ។

ម៉្យាងទៀត ការយល់ដឹងរបស់ប្រជាពលរដ្ឋទាក់ទងនឹងការធានារ៉ាប់រងនេះនៅមានកម្រិតនៅឡើយ ដែលជាហេតុធ្វើឱ្យវិស័យធានារ៉ាប់រងនៅកម្ពុជាមិនទាន់មានភាពសកម្មខ្លាំងខ្លាដូចបណ្តាប្រទេសដទៃទៀត ។ មួយវិញទៀត ក្រុមហ៊ុន ឬ សហគ្រាសធ្វើអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលជាប់កាតព្វកិច្ចត្រូវតែទិញធានារ៉ាប់រងដូចជា កាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវលើយានយន្ត កាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវលើការដ្ឋាន កាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវលើដឹកជញ្ជូនអ្នកដំណើរ មិនទាន់បានអនុវត្តកាតព្វកិច្ចនេះឱ្យបានខ្ជាប់ខ្ជួននៅឡើយទេ ។

ដើម្បីចូលរួមចំណែកធ្វើអោយវិស័យធានារ៉ាប់រងបង្ហាញសកម្មភាពរីកចម្រើនកាន់តែមានសន្ទុះទៅមុខ មតិជាអនុសាសន៍មួយចំនួនត្រូវបានបង្ហាញដូចខាងក្រោម ៖

១-ក្រុមហ៊ុនធានារ៉ាប់រងគួរពន្យល់ដល់អតិថិជនឱ្យបានច្បាស់អំពីការចុះកិច្ចសន្យាធានារ៉ាប់រង ដូចជា ការថ្លែងបញ្ជាក់ទៅលើអត្ថប្រយោជន៍ទាក់ទងនឹងចំនួនទឹកប្រាក់សំណងធានារ៉ាប់រង ព្រមទាំងសម្រួលនីតិវិធីងាយស្រួលនៅពេលទទួលបានសំណងធានារ៉ាប់រង ។

២-រាជរដ្ឋាភិបាលគួរបង្កើនប្រាក់បៀវត្សន៍មន្ត្រីរាជការបន្ថែមទៀតដើម្បីជាការលើកទឹកចិត្ត និងជំរុញឱ្យមន្ត្រីរាជការមានលទ្ធភាពទិញធានារ៉ាប់រង ដូចជា ការធានារ៉ាប់រងសុខភាព ជាដើម ។

៣-រាជរដ្ឋាភិបាលគួរជំរុញការងារបង្កើតលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យធានារ៉ាប់រងឱ្យបានច្រើនបន្ថែមទៀត ដើម្បីបំពេញសេចក្តីត្រូវការ និង ភាពខ្វះចន្លោះ ពិព្រោះច្បាប់ស្តីពីការធានារ៉ាប់រងឆ្នាំ ២០១៤ បានបញ្ញត្តិអំពីអនុក្រឹត្យជាច្រើន តែមកទល់ពេលនេះ អនុក្រឹត្យទាំងនោះមិនទាន់បានអនុម័តនៅឡើយទេ មានដូចជា អនុក្រឹត្យស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការបញ្ចប់កិច្ចសន្យាមុនកាលកំណត់ ។ អនុក្រឹត្យស្តីពីប្រភេទយានយន្តប្រកបអាជីវកម្មទាំងឡាយដែលត្រូវមានការធានារ៉ាប់រង ។ អនុក្រឹត្យស្តីពីប្រភេទការដ្ឋានដែលត្រូវមានការធានារ៉ាប់រង ។ អនុក្រឹត្យស្តីពីប្រភេទមធ្យោបាយដឹកជញ្ជូនអ្នកដំណើរដែលត្រូវមានការធានារ៉ាប់រង ។ អនុក្រឹត្យស្តីពីការធានារ៉ាប់រងខ្នាតតូច ។ល។

៤-រាជរដ្ឋាភិបាលគួរចាត់វិធានការត្រួតពិនិត្យចំពោះសហគ្រាស និង/ឬ ក្រុមហ៊ុនទាំងឡាយណាដែលជាប់កាតព្វកិច្ចនឹងការធានារ៉ាប់រងជាកាតព្វកិច្ច ដូចជា ក្រុមហ៊ុនដឹកជញ្ជូនអ្នកដំណើរ ការដ្ឋានសាងសង់ ។ល។

៥-ក្រសួងអប់រំយុវជន និងកីឡា គួរតែរៀបចំសៀវភៅដែលត្រូវបង្ហាញអំពី មេរៀនស្តីពីខ្លឹមសារអត្ថន័យ និង ផលប្រយោជន៍នៃការធានារ៉ាប់រងដើម្បីឱ្យសិស្សានុសិស្សសិក្សាស្វែងយល់ ។ លើសពីនេះ សាកលវិទ្យាល័យទាំងឡាយណាដែលមិនទាន់បានដាក់បញ្ចូលការធានារ៉ាប់រងទៅក្នុងកម្មវិធីអប់រំរបស់ខ្លួនទេ គួរតែបង្កើតឱ្យមានមុខវិជ្ជាមួយនេះ ដើម្បីជាទុនក្នុងការបណ្តុះបណ្តាលនិស្សិតឱ្យមានជំនាញវិជ្ជាជីវៈច្បាស់លាស់ទៅលើវិស័យនេះ ។

# ឯកសារយោង

## ក. បទដ្ឋានគតិយុត្ត

១. ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧

២. ច្បាប់ស្តីពីការធានារ៉ាប់រង ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៤

៣. អនុក្រឹត្យលេខ ១០៦ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០១ ស្តីពីការធានារ៉ាប់រង

៤. ប្រកាសលេខ ៦៥៣ ប្រក.សហវ-សក-ទច-មផ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០២ ស្តីពីកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្ត ឬធានារ៉ាប់រងតតិយជន

៥. ប្រកាសលេខ ៦៥៤ ប្រក.សហវ-សក-ទច-មផ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០២ ស្តីពីកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវការដឹកជញ្ជូនអ្នកដំណើរ

៦. ប្រកាសលេខ ៦៥៥ ប្រក.សហវ-ជនស-មផ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០២ ស្តីពីកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន

៧. ប្រកាសលេខ ៩៣៤ សហវ.ប្រក ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីការកំណត់ទូទៅចំពោះប្រតិបត្តិការធានារ៉ាប់រង

## ខ. សៀវភៅ

១.ក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ១-២, កែសម្រួលការបោះពុម្ពលើកទី១ ឆ្នាំ ២០១៣

២. សាស្ត្រាចារ្យ ជិន វណ្ណារ៉ា, នីតិកិច្ចសន្យា, បោះពុម្ពឆ្នាំ ២០១៣

## គ. គេហទំព័រ

១. www.gdfi.mef.gov.kh ពិគ្រោះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១៧

# ព្រះរាជក្រម

នស/រកម/០៨១៤/០២១

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការធានារ៉ាប់រង ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៤ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៤ នាសម័យប្រជុំលើកទី៥ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់

# ស្ដីពី

# ការធានារ៉ាប់រង

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.–**

ច្បាប់នេះមានគោលបំណងធានានូវ៖

-ការអភិវឌ្ឍប្រកបដោយចីរភាពនៃវិស័យធានារ៉ាប់រង

-ផលប្រយោជន៍សាធារណៈ និងទំនុកចិត្តដល់សេវាធានារ៉ាប់រង

-សង្គតិភាពជាមួយនឹងគោលការណ៍គ្រឹះធានារ៉ាប់រងអន្តរជាតិ

-ផលប្រយោជន៍របស់រូបវន្តបុគ្គល និងនីតិបុគ្គលដែលជាអ្នកត្រូវបានធានារ៉ាប់រង ។

**មាត្រា ២.–**

ច្បាប់នេះមានគោលដៅ៖

-ពង្រឹងការគ្រប់គ្រង និងការត្រួតពិនិត្យអាជីវកម្មធានារ៉ាប់រង

-កំណត់អំពីការគ្រប់គ្រងកិច្ចប្រតិបត្តិការ និងការធ្វើអាជីវកម្មធានារ៉ាប់រង

-ជំរុញការប្រកួតប្រជែង ភាពស្មោះត្រង់ និងតម្លាភាពក្នុងវិស័យធានារ៉ាប់រង ។

**មាត្រា ៣.–**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះសកម្មភាពធានារ៉ាប់រងទាំងអស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែមានបទប្បញ្ញត្តិដោយឡែកដូចមានចែងក្នុងជំពូកទី ១២ នៃច្បាប់នេះ ។

**មាត្រា ៤.–**

វាក្យសព្ទដែលប្រើនៅក្នុងច្បាប់នេះ មាននិយមន័យដូចតទៅ៖

- **ការធានារ៉ាប់រង** សំដៅដល់ការធ្វើកិច្ចសន្យាធានារ៉ាប់រងដែលក្នុងនោះ អ្នកត្រូវបានធានារ៉ាប់រងត្រូវបង់បុព្វលាភធានារ៉ាប់រងទៅឲ្យក្រុមហ៊ុនធានារ៉ាប់រង ហើយក្រុមហ៊ុនធានារ៉ាប់រងត្រូវធ្វើសំណងដល់ការខូចខាត ឬការបាត់បង់ទ្រព្យសម្បត្តិដែលបង្កឡើងដោយហេតុការណ៍គ្រោះថ្នាក់ ឬក៏ធ្វើសំណងនៅពេលដែលអ្នកត្រូវបានធានារ៉ាប់រងស្លាប់ របួស ពិការ មានជំងឺ ឬនៅពេលដែលបុគ្គលនោះ ឈានដល់កាលកំណត់ណាមួយដែលភាគីទាំងពីរបានព្រមព្រៀងគ្នា ដូចមានចែងក្នុងកិច្ចសន្យាធានារ៉ាប់រង ។

- **ការធានារ៉ាប់រងជាកាតព្វកិច្ច** សំដៅដល់ការធ្វើកិច្ចសន្យាធានារ៉ាប់រង ដែលអ្នកត្រូវបានធានារ៉ាប់រង ត្រូវបំពេញជាកាតព្វកិច្ចតាមការកំណត់នៃច្បាប់ និងបទប្បញ្ញត្តិស្តីពីការធានារ៉ាប់រងក្នុងគោលបំណងបម្រើ និងការពារផលប្រយោជន៍សាធារណៈ ។

- **កិច្ចសន្យាធានារ៉ាប់រង** សំដៅដល់កិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ ដែលធ្វើឡើងរវាងក្រុមហ៊ុនធានារ៉ាប់រង និងអ្នកត្រូវបានធានារ៉ាប់រង ដែលតាមរយៈនោះ ក្រុមហ៊ុនធានារ៉ាប់រងព្រម

ទទួលនូវហានិភ័យជាក់លាក់ណាមួយ ដោយទទួលមកវិញនូវការបង់បុព្វលាភធានារ៉ាប់រងពីអ្នកដែលត្រូវបានធានារ៉ាប់រង ។

- **កំណត់សំគាល់** សំដៅដល់ឯកសារបណ្តោះអាសន្នដែលចេញដោយក្រុមហ៊ុនធានារ៉ាប់រង ឬភ្នាក់ងារធានារ៉ាប់រង ជំនួសបណ្ណសន្យារ៉ាប់រងស្ថាពរ ។

- **ក្រុមហ៊ុនធានារ៉ាប់រង** សំដៅដល់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ក្រុមហ៊ុនធានារ៉ាប់រងទូទៅ ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច និងក្រុមហ៊ុនធានារ៉ាប់រងបន្ត ។

- **គ្រឹះស្ថានធានារ៉ាប់រង** សំដៅដល់ក្រុមហ៊ុនធានារ៉ាប់រង ភ្នាក់ងារធានារ៉ាប់រង ជើងសាធានារ៉ាប់រង និងក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រង ។

- **បណ្ណសន្យារ៉ាប់រង** សំដៅដល់ឯកសារចងភ្ជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ ដែលចេញដោយក្រុមហ៊ុនធានារ៉ាប់រង ដោយមានកំណត់ពីខ្លឹមសារសំខាន់និងចែងពីលក្ខខណ្ឌលំអិតដែលបានព្រមព្រៀងរវាងក្រុមហ៊ុនធានារ៉ាប់រង និងអ្នកត្រូវបានធានារ៉ាប់រងនៅក្នុងកិច្ចសន្យាធានារ៉ាប់រង ។ បណ្ណសន្យារ៉ាប់រងត្រូវភ្ជាប់មកជាមួយនូវវិញ្ញាបនបត្រធានារ៉ាប់រង ឬឯកសារពាក់ព័ន្ធផ្សេងៗទៀត ។

- **បណ្ណសន្យារ៉ាប់រងគ្រោះថ្នាក់បុគ្គល** សំដៅដល់កិច្ចសន្យាធានារ៉ាប់រងដែលផលប្រយោជន៍របស់វាជាប្រាក់ ឬផលប្រយោជន៍សំណងជាវត្ថុ ឬផលប្រយោជន៍សំណងរួមមានជាប្រាក់និងជាវត្ថុទៅឲ្យអ្នកត្រូវបានធានារ៉ាប់រងនៅពេលមានហានិភ័យកើតឡើង ដើម្បីធានាលើគ្រោះថ្នាក់ទាំងឡាយ ។

- **បុព្វលាភធានារ៉ាប់រង** សំដៅដល់ចំនួនទឹកប្រាក់ដែលអ្នកត្រូវបានធានារ៉ាប់រងត្រូវបង់ទៅឲ្យក្រុមហ៊ុនធានារ៉ាប់រង តាមការកំណត់របស់ក្រុមហ៊ុនធានារ៉ាប់រងនៅក្នុងបណ្ណសន្យារ៉ាប់រង ។

- **ពិន័យអន្តរការណ៍** សំដៅដល់ការផាកពិន័យជាទឹកប្រាក់ចំពោះទង្វើរបស់ក្រុមហ៊ុនធានារ៉ាប់រងដែលអនុវត្តផ្ទុយពីការណែនាំរបស់បញ្ញត្តិករធានារ៉ាប់រង ។

- **ម្ចាស់បណ្ណសន្យារ៉ាប់រង** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសិទ្ធិស្របច្បាប់លើបណ្ណសន្យារ៉ាប់រង ។

- **វិញ្ញាបនបត្រធានារ៉ាប់រង** សំដៅដល់ឯកសារដែលចេញដោយក្រុមហ៊ុនធានារ៉ាប់រង ដើម្បីបញ្ជាក់ថាអ្នកត្រូវបានធានារ៉ាប់រងបានទិញការធានារ៉ាប់រងពីក្រុមហ៊ុនធានារ៉ាប់រង ។

- **សំណងធានារ៉ាប់រង** សំដៅដល់សំណងជាប្រាក់ឬជាវត្ថុ ឬសំណងរួមជាប្រាក់និងជាវត្ថុដែលត្រូវសងដោយក្រុមហ៊ុនធានារ៉ាប់រង ។

- **អភិបាលបណ្តោះអាសន្ន** សំដៅដល់អ្នកគ្រប់គ្រងបណ្តោះអាសន្ន ដែលតែងតាំងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីបំពេញភារកិច្ចក្រុមហ៊ុនធានារ៉ាប់រងមុនពេលធ្វើការជម្រះបញ្ជីដើម្បីវាយតម្លៃលើស្ថានភាពសាធនភាពរបស់ក្រុមហ៊ុន ។

- **អ្នកជម្រះបញ្ជី** សំដៅដល់រូបវន្តបុគ្គលដែលត្រូវបានតែងតាំងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬតុលាការ ដើម្បីធ្វើការដោះស្រាយទូទាត់បំណុលនៅពេលដែលក្រុមហ៊ុនធានារ៉ាប់រងត្រូវជម្រះបញ្ជី ។

- **អ្នកត្រូវបានធានារ៉ាប់រង** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលទិញបណ្ណសន្យារ៉ាប់រង ក្នុងករណីមួយចំនួនអាចជាម្ចាស់បណ្ណសន្យារ៉ាប់រងផង និងអាចជាអ្នកត្រូវបានធានារ៉ាប់រងផង ។

- **អ្នកទទួលផល** សំដៅដល់តតិយជននៃកិច្ចសន្យា ដែលត្រូវបានកំណត់ថាមានសិទ្ធិស្របច្បាប់ក្នុងការទទួលផលប្រយោជន៍ពីកិច្ចសន្យាទាំងឡាយណាដែលទាក់ទង នឹងការធានារ៉ាប់រងលើអាយុជីវិតតែប៉ុណ្ណោះ ។

- **អ្នកស្នើសុំធានារ៉ាប់រង** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលអាចនឹងក្លាយជាអ្នកត្រូវបានធានារ៉ាប់រងនាពេលអនាគត ដែលបំពេញនិងចុះហត្ថលេខាលើទម្រង់បែបបទជាលាយលក្ខណ៍អក្សររបស់ក្រុមហ៊ុនធានារ៉ាប់រងអំពីស្ថានភាពផ្ទាល់របស់បុគ្គលនោះ ។

- **យានយន្ត** សំដៅដល់យានដែលធ្វើចរាចរណ៍ដោយម៉ាស៊ីនលើផ្លូវគោក និងផ្លូវទឹក ។

## ជំពូកទី ២
## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា ៥.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានសមត្ថកិច្ចក្នុងការចេញបទប្បញ្ញត្តិ គ្រប់គ្រងនិងត្រួតពិនិត្យការធ្វើអាជីវកម្មធានារ៉ាប់រង ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៦.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានសមត្ថកិច្ចបង្កើតនិងគ្រប់គ្រងមូលនិធិអភិវឌ្ឍវិស័យធានារ៉ាប់រង ដើម្បីជំរុញការអភិវឌ្ឍ ការទ្រទ្រង់ និងការលើកកម្ពស់ការផ្សព្វផ្សាយអំពីសារប្រយោជន៍នៃការធានារ៉ាប់រងដល់សាធារណជន ។

## ជំពូកទី ៣
## កិច្ចសន្យាធានារ៉ាប់រង
## ផ្នែកទី ១
## បែបបទទូទៅ

ការធានារ៉ាប់រងដែលមានអត្ថប្រយោជន៍ដល់រូបវន្តបុគ្គល ឬនីតិបុគ្គលជាអ្នកត្រូវបានធានារ៉ាប់[illegible]ហានិភ័យទាំងឡាយ ទោះបីជាប្រភេទធានារ៉ាប់រងអាយុជីវិតក្តី ឬជាប្រភេទធានារ៉ាប់រងទូទៅ

ក្តី ត្រូវតែជាការចុះកិច្ចសន្យាធានារ៉ាប់រងជាមួយក្រុមហ៊ុនធានារ៉ាប់រងដែលមានអាជ្ញាបណ្ណឲ្យធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## មាត្រា ៨.-

កិច្ចសន្យាធានារ៉ាប់រង ត្រូវចែងឲ្យបានច្បាស់លាស់អំពីទំនាក់ទំនងរវាងសិទ្ធិនិងកាតព្វកិច្ចរបស់អ្នកត្រូវបានធានារ៉ាប់រង និងក្រុមហ៊ុនធានារ៉ាប់រង ។ កិច្ចសន្យាធានារ៉ាប់រងត្រូវរៀបចំដោយយកភាសាខ្មែរជាគោល និងត្រូវមានចុះហត្ថលេខា និង/ឬផ្តិតមេដៃរបស់ភាគីទាំងសងខាង ។

## មាត្រា ៩.-

ក្នុងការធ្វើកិច្ចសន្យាធានារ៉ាប់រង អ្នកត្រូវបានធានារ៉ាប់រង និងក្រុមហ៊ុនធានារ៉ាប់រងត្រូវគោរពតាមគោលការណ៍ស្មោះត្រង់ ដែលមានផលប្រយោជន៍ទៅវិញទៅមក មានការស្រុះស្រួលគ្នាដោយឆ្លងតាមការចរចា និងមិនធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈឡើយ ។

## មាត្រា ១០.-

ក្រុមហ៊ុនធានារ៉ាប់រងមានកាតព្វកិច្ចពន្យល់អ្នកត្រូវបានធានារ៉ាប់រងឲ្យបានយល់ច្បាស់អំពីលក្ខខណ្ឌនៃកិច្ចសន្យាធានារ៉ាប់រង និងខ្លឹមសារនៃបណ្ណសន្យារ៉ាប់រងដែលភ្ជាប់ជាមួយ នឹងវិញ្ញាបនបត្រធានារ៉ាប់រង និង/ឬឯកសារពាក់ព័ន្ធផ្សេងៗ ។

## មាត្រា ១១.-

នៅពេលដែលរូបវន្តបុគ្គល ឬនីតិបុគ្គលធ្វើសំណើសុំការធានារ៉ាប់រង ហើយក្រុមហ៊ុនធានារ៉ាប់រងយល់ព្រមទទួលសំណើ ព្រមទាំងមានការឯកភាពគ្នារវាងភាគីទាំងពីរលើលក្ខខណ្ឌផ្សេងៗ នៃកិច្ចសន្យាហើយនោះ កិច្ចសន្យាធានារ៉ាប់រងអាចចាត់ទុកថាបានឯកភាពលើខ្លឹមសាររួចហើយ ។

បន្ទាប់ពីបានចុះកិច្ចសន្យារួចមក ក្រុមហ៊ុនធានារ៉ាប់រងត្រូវចេញបណ្ណសន្យារ៉ាប់រងដែលភ្ជាប់មកជាមួយនូវវិញ្ញាបនបត្រធានារ៉ាប់រង ឬចេញកំណត់សំអាង និង/ឬឯកសារពាក់ព័ន្ធផ្សេងៗទៀតទៅឲ្យអ្នកស្នើសុំធានារ៉ាប់រង ។ បណ្ណសន្យារ៉ាប់រងដែលភ្ជាប់មកជាមួយនូវវិញ្ញាបនបត្រធានារ៉ាប់រង និង/ឬឯកសារពាក់ព័ន្ធផ្សេងៗទៀត ត្រូវមានចែងនិងកំណត់ខ្លឹមសារសំខាន់ជាទូទៅដែលបានព្រមព្រៀងជាមុនរវាងភាគីទាំងពីរ ។

## មាត្រា ១២.-

វិញ្ញាបនបត្រធានារ៉ាប់រងត្រូវបញ្ជាក់អំពី៖

- គោត្តនាម និងនាម និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា
- បុគ្គល ឬវត្ថុដែលត្រូវបានធានារ៉ាប់រង
- ប្រភេទហានិភ័យដែលត្រូវបានធានារ៉ាប់រង
- ពេលវេលាចាប់ផ្តើមនិងទីកន្លែងនៃហានិភ័យដែលត្រូវបានធានារ៉ាប់រង

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- ចំនួនទឹកប្រាក់ដែលត្រូវបានធានារ៉ាប់រង
- បុព្វលាភធានារ៉ាប់រងដែលត្រូវបង់ និងរបៀបបង់បុព្វលាភធានារ៉ាប់រង
- របៀបនិងលក្ខខណ្ឌមួយចំនួននៃសេចក្ដីប្រកាសគ្រោះថ្នាក់
- រយៈពេលនៃកិច្ចសន្យា និងរយៈពេលនៃការធានារ៉ាប់រង
- លក្ខខណ្ឌទាំងឡាយដែលកំណត់មោឃភាព និងការបាត់បង់សិទ្ធិព្រមទាំងលក្ខខណ្ឌដែលអនុញ្ញាតឲ្យគូភាគីនីមួយៗបញ្ឈប់កិច្ចសន្យាបានមុនកាលកំណត់ ។

ក្រៅពីចំណុចដែលមានកំណត់ខាងលើ គូភាគីអាចដាក់បន្ថែមនូវចំណុចផ្សេងៗទៀតបានដោយមានការព្រមព្រៀងគ្នាជាមុន ។

## មាត្រា ១៣.-

មានតែបណ្ណសន្យារ៉ាប់រង ឬកំណត់សំអាងទេដែលកត់ត្រាការធានាទៅវិញទៅមករវាងក្រុមហ៊ុនធានារ៉ាប់រង និងអ្នកត្រូវបានធានារ៉ាប់រង ។

សំណើសុំបន្ត ឬកែប្រែ ឬដាក់ឲ្យអនុវត្តឡើងវិញនូវកិច្ចសន្យាធានារ៉ាប់រងមួយដែលបានព្យួរទុកត្រូវបានចាត់ថាយល់ព្រម ប្រសិនបើក្រុមហ៊ុនធានារ៉ាប់រងមិនបដិសេធនូវសំណើនោះក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ។

## មាត្រា ១៤.-

រយៈពេលនៃកិច្ចសន្យាធានារ៉ាប់រងមានកំណត់នៅក្នុងបណ្ណសន្យារ៉ាប់រង ។ រាល់ការបន្ថែម ឬកែប្រែលើបណ្ណសន្យារ៉ាប់រងដើម ត្រូវធ្វើឡើងដោយកិច្ចសន្យាបន្ថែម និងត្រូវមានចុះហត្ថលេខារបស់ភាគីទាំងសងខាង ។

## មាត្រា ១៥.-

អ្នកត្រូវបានធានារ៉ាប់រង ត្រូវមានផលប្រយោជន៍ពីការធានារ៉ាប់រងដែលស្ថិតក្នុងកម្មវត្ថុដែលត្រូវបានធានារ៉ាប់រង ។

ផលប្រយោជន៍ពីការធានារ៉ាប់រង គឺជាការធ្វើសំណងដែលផ្អែកលើកម្មវត្ថុដែលត្រូវបានធានារ៉ាប់រង ។

កម្មវត្ថុដែលត្រូវបានធានារ៉ាប់រងមានទៅលើទ្រព្យសម្បត្តិ រូបរាងកាយ និងអាយុជីវិត ។

## មាត្រា ១៦.-

បន្ទាប់ពីបានធ្វើកិច្ចសន្យាធានារ៉ាប់រងរួចហើយ អ្នកត្រូវបានធានារ៉ាប់រងត្រូវបង់បុព្វលាភធានារ៉ាប់រងដែលបានព្រមព្រៀងគ្នាក្នុងកិច្ចសន្យា ។

ការធានារ៉ាប់រងមានប្រសិទ្ធភាពចាប់ពីកាលបរិច្ឆេទដែលអ្នកត្រូវបានធានារ៉ាប់រងបានបង់បុព្វលាភធានារ៉ាប់រងតាមកាលកំណត់ក្នុងកិច្ចសន្យា ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

## មាត្រា ១៧.-

ក្នុងករណីដែលអ្នកត្រូវបានធានារ៉ាប់រងពុំបានបង់បុព្វលាភធានារ៉ាប់រងណាមួយតាមកាលកំណត់ នោះ សុពលភាពនៃកិច្ចសន្យាធានារ៉ាប់រងមិនអាចព្យួរទុកឲ្យហួសពីរយៈពេល ៣០(សាមសិប) ថ្ងៃ គិតពីកាលបរិច្ឆេទនៃការចុះហត្ថលេខាលើកិច្ចសន្យាធានារ៉ាប់រងឡើយ ។ ២០(ម្ភៃ) ថ្ងៃក្រោយពីការចុះកិច្ចសន្យាធានារ៉ាប់រង ក្រុមហ៊ុនធានារ៉ាប់រងត្រូវជូនដំណឹងដោយលិខិតអនុសិដ្ឋ ឬដោយលិខិតដែលមានបញ្ជាក់ការទទួលច្បាស់លាស់ដល់អ្នកត្រូវបានធានារ៉ាប់រង ឬម្ចាស់បណ្ណសន្យារ៉ាប់រងឲ្យយកបុព្វលាភធានារ៉ាប់រងមកបង់នៅទីកន្លែងដែលបានព្រមព្រៀងគ្នា ។ ក្រោយពីបានទទួលដំណឹងរួចហើយ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រង ឬម្ចាស់បណ្ណសន្យារ៉ាប់រងនៅតែមិនមកបង់បុព្វលាភធានារ៉ាប់រងក្នុងរយៈពេល ១០(ដប់)ថ្ងៃ នោះក្រុមហ៊ុនធានារ៉ាប់រងមានសិទ្ធិលុបកិច្ចសន្យាចោល ។

## មាត្រា ១៨.-

ការបាត់បង់ ឬការខូចខាតទាំងឡាយបណ្តាលមកពីហានិភ័យដែលមានចែងក្នុងបណ្ណសន្យារ៉ាប់រង ត្រូវស្ថិតនៅក្នុងបន្ទុកធ្វើសំណងរបស់ក្រុមហ៊ុនធានារ៉ាប់រង ។ ប៉ុន្តែក្រុមហ៊ុនធានារ៉ាប់រងមិនធ្វើសំណងចំពោះការបាត់បង់ ឬការខូចខាតទាំងឡាយដែលបណ្តាលមកពីកំហុសដោយចេតនា ឬដោយបន្លំបោកប្រាស់របស់អ្នកត្រូវបានធានារ៉ាប់រងឡើយ ។

ក្រុមហ៊ុនធានារ៉ាប់រងធានាផងដែរ ចំពោះការបាត់បង់និងការខូចខាតដែលបង្កឡើងដោយបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់អ្នកត្រូវបានធានារ៉ាប់រង ទោះជាប្រភេទនិងភាពធ្ងន់ធ្ងរនៃកំហុសទាំងនោះបែបណាក៏ដោយ ។

## មាត្រា ១៩.-

កិច្ចសន្យាធានារ៉ាប់រងមួយអាចត្រូវបានលុបចោល នៅពេលដែលក្រុមហ៊ុនធានារ៉ាប់រងបានរកឃើញថាអ្នកត្រូវបានធានារ៉ាប់រងមានការលាក់លៀម ឬធ្វើប្រតិវេទន៍ខុសដោយចេតនា ហើយបណ្តាលឲ្យមានការផ្លាស់ប្តូរកម្មវត្ថុនៃហានិភ័យ ។

ការភ្លេចភ្លាំង ឬការធ្វើប្រតិវេទន៍មិនច្បាស់លាស់ដោយអចេតនារបស់អ្នកត្រូវបានធានារ៉ាប់រង នឹងមិននាំទៅដល់ការលុបចោលនូវការធានារ៉ាប់រងទេ ។

## មាត្រា ២០.-

ប្រសិនបើគ្រោះថ្នាក់បានបង្កើតឡើងដោយចេតនាតែបន្លំរបស់អ្នកត្រូវបានធានារ៉ាប់រង ហើយក្រុមហ៊ុនធានារ៉ាប់រងបានរកឃើញភស្តុតាងច្បាស់លាស់នៃអំពើនោះ ក្រុមហ៊ុនធានារ៉ាប់រងមានសិទ្ធិប្តឹងទៅតុលាការ ដើម្បីបដិសេធការទទួលខុសត្រូវក្នុងករណីដែលមិនទាន់បានធ្វើសំណង ឬដើម្បីទារសំណងមកវិញក្នុងករណីបានធ្វើសំណងរួចហើយ ។

### មាត្រា ២១.-

ក្នុងប្រភេទធានារ៉ាប់រងភារៈទទួលខុសត្រូវ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងបានបង្កឲ្យមានការខូចខាត ឬបាត់បង់ដល់តតិយជន ក្រុមហ៊ុនធានារ៉ាប់រងត្រូវធ្វើសំណងផ្ទាល់ទៅតតិយជនដែលរងគ្រោះនោះ ។

### មាត្រា ២២.-

ក្នុងការអនុវត្តកិច្ចសន្យាធានារ៉ាប់រង ភាគីមានសិទ្ធិបញ្ចប់កិច្ចសន្យាមុនកាលកំណត់ ។ លក្ខខណ្ឌនិងនីតិវិធីនៃការបញ្ចប់កិច្ចសន្យាមុនកាលកំណត់ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ផ្នែកទី ២
## ការធានារ៉ាប់រងទូទៅ

### មាត្រា ២៣.-

ការធានារ៉ាប់រងទូទៅ ជាកិច្ចសន្យាធានារ៉ាប់រងដែលធ្វើឡើងរវាងអ្នកត្រូវបានធានារ៉ាប់រង និងក្រុមហ៊ុនធានារ៉ាប់រងដែលក្នុងនោះ ការបង់បុព្វលាភធានារ៉ាប់រងត្រូវធ្វើឡើងដើម្បីធានាហានិភ័យលើទ្រព្យសម្បត្តិ ភារៈទទួលខុសត្រូវ និងសុខភាព ។ ប្រភេទផលិតផលធានារ៉ាប់រងទូទៅរួមមានការធានារ៉ាប់រងទ្រព្យសម្បត្តិ ការធានារ៉ាប់រងភារៈទទួលខុសត្រូវ និងការធានារ៉ាប់រងសុខភាព ។

ការធានារ៉ាប់រងទ្រព្យសម្បត្តិ ជាកិច្ចសន្យាធានារ៉ាប់រងដែលធ្វើសំណងដល់អ្នកត្រូវបានធានារ៉ាប់រងនៅពេលដែលទ្រព្យសម្បត្តិរបស់បុគ្គលនោះបានខូចខាត បាត់បង់ ឬអន្តរាយដោយសារហានិភ័យដែលត្រូវបានធានា ។ សំណងដែលត្រូវផ្តល់ដោយក្រុមហ៊ុនធានារ៉ាប់រងទៅឲ្យអ្នកត្រូវបានធានារ៉ាប់រង មិនអាចមានតម្លៃលើសពីវត្ថុដែលបានធ្វើប្រតិវេទន៍ នៅពេលចុះកិច្ចសន្យាធានារ៉ាប់រងឡើយ លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះ ។ ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការធានារ៉ាប់រងទ្រព្យសម្បត្តិមានដូចជា អគារ នាវា ជាដើម ។

ការធានារ៉ាប់រងភារៈទទួលខុសត្រូវ ជាកិច្ចសន្យាធានារ៉ាប់រងលើទឹកប្រាក់សំណងដែលអ្នកត្រូវបានធានារ៉ាប់រងមានកាតព្វកិច្ចបង់ឲ្យតតិយជនដែលទទួលរងរបួសលើរូបរាងកាយ ឬអាយុជីវិត ឬទទួលរងការខូចខាតលើទ្រព្យសម្បត្តិ ដោយសារទង្វើរបស់អ្នកត្រូវបានធានារ៉ាប់រង ឬសកម្មភាពដែលស្ថិតក្រោមការទទួលខុសត្រូវរបស់អ្នកត្រូវបានធានារ៉ាប់រង ។ ប្រភេទផលិតផលធានារ៉ាប់រងភារៈទទួលខុសត្រូវរួមមាន ការធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្ត ការធានារ៉ាប់រងភារៈទទួលខុសត្រូវការងារ ការធានារ៉ាប់រងភារៈទទួលខុសត្រូវការដឹកជញ្ជូនអ្នកដំណើរ ។

ការធានារ៉ាប់រងសុខភាព ជាកិច្ចសន្យាធានារ៉ាប់រងលើការចំណាយសម្រាប់ការព្យាបាលរបួស ជំងឺ និងការចំណាយផ្សេងៗ ដូចជាការចំណាយសម្រាប់ការថែរក្សាអ្នកជំងឺក្នុងរយៈពេលវែងជាដើម ដល់អ្នកត្រូវបានធានារ៉ាប់រងដែលទទួលរងគ្រោះបណ្តាលមកពីគ្រោះថ្នាក់ទាំងឡាយដល់រូបរាងកាយ ឬជំងឺផ្សេងៗ ។

## មាត្រា ២៤.-

ករណីមានការបាត់បង់ទាំងស្រុងនូវកម្មវត្ថុដែលត្រូវបានធានារ៉ាប់រងបណ្តាលមកពីហេតុការណ៍ណាមួយដែលពុំបានគ្រោងទុកជាមុនក្នុងបណ្ណសន្យារ៉ាប់រងទេ ការធានារ៉ាប់រងត្រូវបញ្ចប់ដោយស្របច្បាប់ ហើយក្រុមហ៊ុនធានារ៉ាប់រងត្រូវសងទៅអ្នកត្រូវបានធានារ៉ាប់រងវិញចំនួន ៩០(កៅសិប) ភាគរយនៃបុព្វលាភធានារ៉ាប់រងចំពោះរយៈពេលដែលនៅសល់ ។

## មាត្រា ២៥.-

នៅពេលដែលក្រុមហ៊ុនធានារ៉ាប់រងបានធ្វើសំណងរួចហើយ អ្នកត្រូវបានធានារ៉ាប់រងត្រូវផ្ទេរសិទ្ធិទៅឲ្យក្រុមហ៊ុនធានារ៉ាប់រង ក្នុងការប្តឹងតទល់ជាមួយនឹងតតិយជនដែលបានបង្កឲ្យមានការខូចខាតដើម្បីទាមទារមកវិញនូវទឹកប្រាក់ស្មើនឹងចំនួនដែលបានធ្វើសំណងនោះ ប៉ុន្តែក្រុមហ៊ុនធានារ៉ាប់រងមិនអាចប្តឹងទាមទារសំណងពីបច្ចាញាតិ បុព្វញាតិ ញាតិពន្ធ អ្នកគ្រប់គ្រង និងកម្មករ និយោជិតដែលរស់នៅជម្មតាក្នុងលំនៅឋានរបស់អ្នកត្រូវបានធានារ៉ាប់រងទេ លើកលែងតែករណីដែលមានភស្តុតាងបញ្ជាក់ថា មានការប្រព្រឹត្តកំហុសធ្ងន់ធ្ងរដោយចេតនាដោយជនណាម្នាក់ក្នុងចំណោមជនទាំងនោះ ។

# ផ្នែកទី ៣
# ការធានារ៉ាប់រងអាយុជីវិត

## មាត្រា ២៦.-

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦.០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និង ដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦.១៥ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០០/០២ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យ លេខ ១០៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០១ ស្តីពីការធានារ៉ាប់រង
- យោងតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# សំរេច

ប្រការ ១ :

ក្រុមហ៊ុនធានារ៉ាប់រង ដែលអនុវត្តកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្ត ឬ ធានារ៉ាប់រងតតិយជន ត្រូវដោះស្រាយសំណងបណ្តាលមកពីគ្រោះថ្នាក់ចរាចរ ដែលបង្កឡើងដោយយានយន្តដែលមានការធានារ៉ាប់រង។

ប្រការ ២ :

ប្រភេទយានយន្តដែលត្រូវបំពេញកាតព្វកិច្ចធានារ៉ាប់រងតតិយជន សម្រាប់គ្រោះថ្នាក់ដែលកើតឡើងក្នុងព្រះរាជាណាចក្រកម្ពុជា រួមមាន :

- យានយន្តគ្រប់ប្រភេទដែលធ្វើអាជីវកម្មដឹកជញ្ជូនទំនិញ ដឹកជញ្ជូនអ្នកដំណើរ ដឹកជញ្ជូនភ្ញៀវទេសចរ នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- យានយន្តគ្រប់ប្រភេទ ដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុន សហគ្រាស រោងចក្រ
- យានយន្តរបស់អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ និង សមាគមនានា
- ឧបករណ៍លាយស៊ីម៉ង់ត៍ ដែលធ្វើចលនាផ្លាស់ប្តូរទីកន្លែងដោយម៉ាស៊ីនផ្ទាល់ ឬ ដោយអូសសណ្តោង
- ត្រីចក្រយានយន្ត ដែលប្រើប្រាស់សម្រាប់ធ្វើអាជីវកម្មដឹកជញ្ជូនទំនិញ ឬ ដឹកជញ្ជូនអ្នកដំណើរ ។

ប្រការ ៣ :

កម្រិតទឹកប្រាក់កាតព្វកិច្ចធានារ៉ាប់រងអប្បបរមាលើភារៈទទួលខុសត្រូវយានយន្ត ឬ ធានារ៉ាប់រងតតិយជន ត្រូវកំណត់ដូចខាងក្រោម:

ក-ចំពោះយានយន្តដែលមានកង់បួន ឬ ច្រើនជាងបួន:

- ៥ ០០០ ដុល្លារអាមេរិកជាកម្រិតទឹកប្រាក់កាតព្វកិច្ចធានារ៉ាប់រងអប្បបរមាលើភារៈទទួលខុសត្រូវ យានយន្ត ឬ ធានារ៉ាប់រងតតិយជនសម្រាប់របួសរាងកាយ ឬ ស្លាប់ ក្នុងមនុស្សម្នាក់
- ២៥ ០០០ ដុល្លារអាមេរិកជាកម្រិតទឹកប្រាក់កាតព្វកិច្ចធានារ៉ាប់រងអប្បបរមាលើភារៈទទួលខុសត្រូវ យានយន្ត ឬ ធានារ៉ាប់រងតតិយជនសម្រាប់របួសរាងកាយ ឬ ស្លាប់ក្នុងគ្រោះថ្នាក់មួយករណី
- ១០ ០០០ ដុល្លារអាមេរិកជាកម្រិតទឹកប្រាក់កាតព្វកិច្ចធានារ៉ាប់រងអប្បបរមាលើភារៈទទួលខុសត្រូវ យានយន្ត ឬ ធានារ៉ាប់រងតតិយជនសម្រាប់ការខូចខាតទ្រព្យសម្បត្តិ។

ខ-ចំពោះយានយន្តដែលមានកង់តិចជាងបួន:

- ៥ ០០០ ដុល្លារអាមេរិកជាកម្រិតទឹកប្រាក់កាតព្វកិច្ចធានារ៉ាប់រងអប្បបរមាលើភារៈទទួលខុសត្រូវ យានយន្ត ឬ ធានារ៉ាប់រងតតិយជនសម្រាប់របួសរាងកាយ ឬ ស្លាប់ក្នុងមនុស្សម្នាក់
- ១២ ៥០០ ដុល្លារអាមេរិកជាកម្រិតទឹកប្រាក់កាតព្វកិច្ចធានារ៉ាប់រងអប្បបរមាលើភារៈទទួលខុសត្រូវ យានយន្ត ឬ ធានារ៉ាប់រងតតិយជនសម្រាប់របួសរាងកាយ ឬ ស្លាប់ក្នុងគ្រោះថ្នាក់មួយករណី

- ៥ ០០០ ដុល្លារអាមេរិកជាកម្រិតទឹកប្រាក់កាតព្វកិច្ចធានារ៉ាប់រងអប្បបរមាលើភារៈទទួលខុសត្រូវយានយន្ត ឬ ធានារ៉ាប់រងតតិយជនសម្រាប់ការខូតខាតទ្រព្យសម្បត្តិ ។

ប្រការ ៤ :

ម្ចាស់យានយន្ត ដែលបានបំពេញកាតព្វកិច្ចធានារ៉ាប់រងតតិយជន ត្រូវបង់បុព្វលាភរ៉ាប់រងគ្រប់ចំនួន និងត្រឹមត្រូវតាមកាលកំណត់ដែលបានព្រមព្រៀងគ្នាជាមួយក្រុមហ៊ុនធានារ៉ាប់រង ។ បុព្វលាភរ៉ាប់រងអាចបង់ជាសាច់ប្រាក់ ឬជាមូលប្បទានប័ត្រ ឬ ដោយបង្វែរគណនី ។

នៅពេលមានគ្រោះថ្នាក់ចរាចរកើតឡើង ម្ចាស់យានយន្ត អ្នកបើកបរ ឬ នគរបាលចរាចរខេត្ត-ក្រុង ត្រូវជូនដំណឹងជាបន្ទាន់ទៅក្រុមហ៊ុនធានារ៉ាប់រង ដែលបានទទួលធានាយានយន្តរបស់ខ្លួន។ ក្នុងអំឡុងពេលយ៉ាងយូរ ៥ថ្ងៃ គិតចាប់ពីថ្ងៃកើតមានគ្រោះថ្នាក់ចរាចរ ម្ចាស់យានយន្ត ឬ អ្នកបើកបរត្រូវបញ្ជាក់ជាលាយលក្ខណ៍អក្សរអំពីការទាមទារសំណងមកក្រុមហ៊ុនធានារ៉ាប់រង ។

ម្ចាស់យានយន្ត ត្រូវបានក្រុមហ៊ុនធានារ៉ាប់រងចេញប្រាក់សំណងជំនួសជូនដល់ជនរងគ្រោះទៅតាមកម្រិតទទួលខុសត្រូវដែលភាគីទាំងសងខាងបានព្រមព្រៀងគ្នាក្នុងកិច្ចសន្យាធានារ៉ាប់រង ឬ ក្នុងកំណត់សំអាង។

ប្រការ ៥ :

នៅក្នុងក្របខ័ណ្ឌនៃកាតព្វកិច្ចធានារ៉ាប់រងលើភារៈទទួលខុសត្រូវយានយន្ត ឬ ធានារ៉ាប់រងតតិយជន ក្រុមហ៊ុនធានារ៉ាប់រងមិនទទួលខុសត្រូវចេញសំណងឱ្យអ្នកត្រូវបានធានារ៉ាប់រងក្នុងករណី :

- អ្នកបើកបរគ្មានប័ណ្ណបើកបរស្របច្បាប់ ឬ ប័ណ្ណបើកបរមិនត្រឹមត្រូវតាមប្រភេទយានយន្ត ឬ មានប័ណ្ណបើកបរហួសសុពលភាព
- អ្នកបើកបរស្ថិតនៅក្នុងភាពស្រវឹងជាក់ស្តែង ហើយមានអត្រាជាតិអាកុលចាប់ពី ០,៨០ ក្រាមក្នុងឈាមមួយលីត្រឡើងទៅ ឬ ស្ថិតនៅក្រោមឥទ្ធិពលនៃគ្រឿងញៀន ផ្អែកតាមការធ្វើកោសល្យវិច្ច័យរបស់មន្ទីរពេទ្យ ដោយភ្ជាប់មកជាមួយនឹងកំណត់ហេតុភ្នាក់ងារត្រួតពិនិត្យរបស់ក្រុមហ៊ុនធានារ៉ាប់រង ឬ នគរបាលចរាចរខេត្ត-ក្រុង
- ការខូតខាតដែលកើតមានឡើងចំពោះអ្នកដំណើរនៅក្នុងយានយន្តដែលជាប់កាតព្វកិច្ចធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរ ហើយម្ចាស់ ឬ អ្នកបើកបរគ្មានការធានារ៉ាប់រង
- នាយកដ្ឋានឧស្សាហកម្ម និង ហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានបញ្ជាក់ថាប័ណ្ណធានារ៉ាប់រងនោះមិនត្រឹមត្រូវ ។

ប្រការ ៦ :

គ្រប់យានយន្តដែលមានការធានារ៉ាប់រង ត្រូវបិទលតាប័ត្រធានារ៉ាប់រងដែលក្រុមហ៊ុនធានារ៉ាប់រងបានចេញជូននៅលើកញ្ចក់ផ្នែកខាងមុខ ។ លតាប័ត្រធានារ៉ាប់រងនេះ ត្រូវបញ្ជាក់ពីឈ្មោះក្រុមហ៊ុនធានារ៉ាប់រង និង កាលបរិច្ឆេទអស់សុពលភាព ។

នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ

ប្រការ ៧ :

ក្រុមហ៊ុនធានារ៉ាប់រងត្រូវមានភារកិច្ច :

- សហការជាមួយនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់ម្ចាស់យានយន្តទាំងអស់ឱ្យចូលរួមអនុវត្តកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្ត ឬ ធានារ៉ាប់រងតតិយជន
- ដោះស្រាយរាល់សំណងជូនជនរងគ្រោះជំនួសម្ចាស់យានយន្ត ឬ អ្នកបើកបរ ដែលមានការធានារ៉ាប់រងក្នុងរយៈពេល ១០ ថ្ងៃយ៉ាងយូរ ក្រោយពេលដែលបានទទួលសំណុំលិខិតគ្រោះថ្នាក់ចរាចរគ្រប់គ្រាន់រួចហើយរួមទាំងរបាយការណ៍នគរបាលចរាចរដែរ លើកលែងតែក្រុមហ៊ុនធានារ៉ាប់រងយល់ឃើញថាសំណងនេះគ្មាននៅក្នុងល័ក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងធានារ៉ាប់រង ឬ សំណងមានច្រើនហួសហេតុ
- ធ្វើរបាយការណ៍ និង ស្ថិតិពាក់ព័ន្ធអាជីវកម្មធានារ៉ាប់រងរបស់ខ្លួនជូននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ជូនដំណឹងដល់ក្រសួងសាធារណការ និង ដឹកជញ្ជូន និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងករណីដែលក្រុមហ៊ុនធានារ៉ាប់រងលុបចោលនូវការធានារបស់ខ្លួនមកពីមូលហេតុម្ចាស់យានយន្ត ឬ អ្នកបើកបរមិនបានបង់បុព្វលាភរ៉ាប់រងតាមកិច្ចសន្យា ឬ ដោយការមិនគោរពតាមល័ក្ខខ័ណ្ឌធានារ៉ាប់រង
- បង្កើតកម្មវិធីអប់រំដល់អ្នកបើកបរពីវិធានការទប់ស្កាត់គ្រោះថ្នាក់ចរាចរ ។

ប្រការ ៨ :

នៅពេលមានគ្រោះថ្នាក់ចរាចរកើតឡើង :

- ភាគីទាំងអស់ ដែលពាក់ព័ន្ធក្នុងគ្រោះថ្នាក់ ត្រូវធ្វើរបាយការណ៍ជាលាយល័ក្ខណ៍អក្សរ ផ្ញើជូនក្រុមហ៊ុនធានារ៉ាប់រង ដោយបញ្ជាក់ពីមូលហេតុនៃគ្រោះថ្នាក់ចរាចរនេះ
- បើគ្មានការព្រមព្រៀងគ្នាទេ ភាគីទាំងអស់ត្រូវទាក់ទងឱ្យមានអន្តរាគមន៍ពីនគរបាលចរាចរខេត្តក្រុង ដើម្បីធ្វើកំណត់ហេតុអង្កេតគ្រោះថ្នាក់ចរាចរ
- នគរបាលចរាចរខេត្ត-ក្រុង ត្រូវកសាងកំណត់ហេតុអង្កេតគ្រោះថ្នាក់ ត្រួតពិនិត្យ និង ធ្វើប្លង់កន្លែងកើតហេតុឱ្យបានត្រឹមត្រូវ ហើយផ្ញើមកក្រុមហ៊ុនធានារ៉ាប់រង ក្នុងអំឡុងពេល ៤៨ ម៉ោង គិតចាប់ពីពេលធ្វើអង្កេតគ្រោះថ្នាក់ ដើម្បីឱ្យក្រុមហ៊ុនធានារ៉ាប់រងមានមូលដ្ឋានសម្រាប់គិតគូរធ្វើសំណងដល់ការខូចខាតទាំងឡាយដែលពាក់ព័ន្ធនឹងប័ណ្ណសន្យារ៉ាប់រង
- នៅតំបន់ដាច់ស្រយាលដែលគ្មាននគរបាលចរាចរជើងគោកឈរជើងទេនោះ ម្ចាស់យានយន្ត ឬ អ្នកបើកបរត្រូវទាក់ទងជាមួយអាជ្ញាធរមានសមត្ថកិច្ចដែនដី ដើម្បីបញ្ជាក់លើរបាយការណ៍គ្រោះថ្នាក់
- ក្នុងករណីដែលយានយន្តមានគ្រោះថ្នាក់ត្រូវបានឃុំឃាំងទុកដោយនគរបាលចរាចរ យានយន្តនោះ ត្រូវបានដោះលែងបន្ទាប់ពីបានទទួលនូវលិខិតជាផ្លូវការពីអ្នកធានារ៉ាប់រង ដែលមានការអនុញ្ញាតឱ្យធ្វើអាជីវកម្មធានារ៉ាប់រង នៅក្នុងព្រះរាជាណាចក្រកម្ពុជា ចំពោះយានយន្តដែលមានកាតព្វកិច្ចធានារ៉ាប់រង ។

ប្រការ ៩ ៖

នៅពេលផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូន ឬ លិខិតអនុញ្ញាតបន្តធ្វើអាជីវកម្មដឹកជញ្ជូនដល់យានយន្តគ្រប់ប្រភេទ ដូចមានចែងក្នុងប្រការ ២ អគ្គនាយកដ្ឋានដឹកជញ្ជូន ឬ មន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្ត-ក្រុង នៃក្រសួងសាធារណការ និង ដឹកជញ្ជូន ត្រូវតម្រូវឱ្យម្ចាស់យានយន្តផ្តល់ឯកសារធានារ៉ាប់រងតតិយជន ។ ក្នុងរយៈពេល ៦០ថ្ងៃ ម្ចាស់យានយន្តដែលមានលិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូនហើយ ត្រូវទិញធានារ៉ាប់រងតតិយជន ករណីនៅតែមិនព្រមទិញធានារ៉ាប់រងតតិយជនទេ អគ្គនាយកដ្ឋានដឹកជញ្ជូន ឬ មន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្ត-ក្រុង ត្រូវផ្អាកសិទ្ធិ ឬ ដកហូតលិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូន និង វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសជាបណ្តោះអាសន្ន រហូតដល់ម្ចាស់យានយន្តបានទិញធានារ៉ាប់រងតតិយជនត្រឹមត្រូវតាមការកំណត់។

ប្រការ ១០ ៖

នគរបាលចរាចរខេត្ត-ក្រុង ត្រូវត្រួតពិនិត្យលតាប័ត្រធានារ៉ាប់រងឱ្យបានម៉ត់ចត់នៅលើកញ្ចក់យានយន្ត ដែលអនុវត្តកាតព្វកិច្ចធានារ៉ាប់រងតតិយជន ដើម្បីរកឱ្យឃើញនូវយានយន្តទាំងឡាយណាដែលមិនបានអនុវត្តកាតព្វកិច្ចធានារ៉ាប់រង ។ ក្នុងករណីមិនមានលតាប័ត្រធានារ៉ាប់រងតតិយជន ម្ចាស់យានយន្ត ត្រូវទទួលការផាកពិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពីការធានារ៉ាប់រង ។ នគរបាលចរាចរខេត្ត-ក្រុងត្រូវ៖

១-ផាកពិន័យ និង ណែនាំឱ្យម្ចាស់ និង ប្រតិបត្តិករទៅទិញធានារ៉ាប់រងក្នុងរយៈពេលយ៉ាងយូរ ៧ ថ្ងៃ

២-ក្នុងករណីមិនព្រមអនុវត្តតាមការណែនាំខាងលើ ត្រូវដកហូតលិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូន និង វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេស

៣-ក្នុងករណីមិនរាងចាល ត្រូវឃាត់យានយន្តទុកជាបណ្តោះអាសន្នមិនឱ្យដំណើរការដឹកជញ្ជូនបន្តទៀត រហូតដល់ ម្ចាស់ ឬ ប្រតិបត្តិករ បានផ្តល់ឯកសារកាតព្វកិច្ចធានារ៉ាប់រង ភារៈទទួលខុសត្រូវយានយន្ត ឬ ធានារ៉ាប់រងតតិយជនត្រឹមត្រូវតាមការកំណត់។

ប្រការ ១១ ៖

ក្រសួងសាធារណការ និង ដឹកជញ្ជូន ទទួលខុសត្រូវលើការផ្តល់វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេស និង លិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូនដល់យានយន្តគ្រប់ប្រភេទ ដើម្បីរក្សាសណ្តាប់ធ្នាប់ និង ធានាសុវត្ថិភាពចរាចរតាមដងផ្លូវសាធារណៈ។

ក្រសួងទេសចរណ៍ មានភារកិច្ចធ្វើអធិការកិច្ចជាទៀងទាត់ចំពោះឯកសាររបស់ម្ចាស់ ឬ ប្រតិបត្តិករមធ្យោបាយដឹកជញ្ជូនភ្ញៀវទេសចរ ហើយទាមទាររកឯកសារធានារ៉ាប់រងដែលមានសុពលភាព និង ត្រូវទទួលខុសត្រូវក្នុងការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍ និង អប់រំដល់ផ្នែកឧស្សាហកម្មទេសចរណ៍អំពីកាតព្វកិច្ចធានារ៉ាប់រងលើការដឹកជញ្ជូនភ្ញៀវទេសចរ ហើយធ្វើយ៉ាងណាឱ្យភ្នាក់ងារទេសចរប្រើប្រាស់តែមធ្យោបាយដឹកជញ្ជូនណាដែលមានកាតព្វកិច្ចធានារ៉ាប់រង។

ការខកខានរបស់ម្ចាស់ ឬ ប្រតិបត្តិករមធ្យោបាយដឹកជញ្ជូនក្នុងការផ្តល់ឯកសារអំពីកាតព្វកិច្ចធានារ៉ាប់រង ត្រូវយកជាមូលដ្ឋានសម្រាប់ធ្វើការផាកពិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពីការធានារ៉ាប់រង និង សម្រាប់ការព្យួរ ឬ ការដកហូតអាជ្ញាប័ណ្ណទេសចរណ៍ ។

ក្រសួងមហាផ្ទៃ ទទួលខុសត្រូវលើការជំរុញម្ចាស់យានយន្តគ្រប់ប្រភេទឱ្យយកយានយន្តរបស់ខ្លួនទៅធ្វើការត្រួតពិនិត្យលក្ខណៈបច្ចេកទេស និង សុំលិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូនទៅក្រសួងសាធារណការ និង ដឹកជញ្ជូនឱ្យបានទៀងទាត់ក្នុងគោលបំណងជម្រុញម្ចាស់យានយន្តឱ្យបំពេញកាតព្វកិច្ចធានារ៉ាប់រងតតិយជន នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ទទួលខុសត្រូវត្រួតពិនិត្យ និង ជំរុញឱ្យក្រុមហ៊ុនធានារ៉ាប់រងឱ្យដោះស្រាយរាល់សំណងដល់ជនរងគ្រោះជំនួសម្ចាស់យានយន្តដែលបានអនុវត្តកាតព្វកិច្ចធានារ៉ាប់រង ។

ប្រការ ១២ :

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ១៣ :

គ្រប់ស្ថាប័ន ឬ អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងទាំងបួន ត្រូវអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ឧបនាយករដ្ឋមន្ត្រី [illegible] ស ខេង

[illegible] យូ ហុកគ្រី

[illegible] ចេង សិរីវុឌ្ឍ

[illegible] ដឹកជញ្ជូន [illegible]

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
គាត ឈន់

កន្លែងទទួល
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន
"ដើម្បីជូនជ្រាប"
-ដូចប្រការ ១៣
-គ្រប់សាលាខេត្ត-ក្រុង
"ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ក្រសួងសាធារណការ និង ដឹកជញ្ជូន

ក្រសួងទេសចរណ៍

ក្រសួងមហាផ្ទៃ

លេខ ៦៥៤ ប្រក.សហវ.សក.ទស.មហ

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែ[illegible] ឆ្នាំ ២០០២

# ប្រកាសអន្តរក្រសួង

## ស្តីពី

## កាតព្វកិច្ចធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួងសាធារណការ និង ដឹកជញ្ជូន ក្រសួងទេសចរណ៍ និង ក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៩៦ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦.០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និង ដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦.១៥ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០០/០២ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យលេខ ១០៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០១ ស្តីពីការធានារ៉ាប់រង
- យោងតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

[illegible]

## សំរេច

**ប្រការ ១ :**

ការធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើររួមទាំងភ្ញៀវទេសចរ មានសារៈសំខាន់ដើម្បីការពារសិទ្ធិ និង ផលប្រយោជន៍របស់អ្នកដំណើរតាមមធ្យោបាយដឹកជញ្ជូនអ្នកដំណើរ ដែលមានអាជ្ញាប័ណ្ណនៅក្នុងព្រះរាជាណាចក្រកម្ពុជា ចំពោះរាល់គ្រោះថ្នាក់ដែលកើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលជាម្ចាស់ ឬ ជាប្រតិបត្តិករមធ្យោបាយដឹកជញ្ជូនអ្នកដំណើរតាមផ្លូវគោក ផ្លូវសមុទ្រ ផ្លូវទន្លេ ចាំបាច់ត្រូវអនុវត្តតាមបទដ្ឋានបច្ចេកទេស និង ចំណុះផ្ទុករបស់គ្រប់មធ្យោបាយធ្វើអាជីវកម្មដឹកជញ្ជូនអ្នកដំណើរ ។

**ប្រការ ២ :**

មធ្យោបាយដឹកជញ្ជូនអ្នកដំណើរគ្រប់ប្រភេទ ដែលមានលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មដឹកជញ្ជូនអ្នកដំណើរនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានការធានារ៉ាប់រងលើភារៈទទួលខុសត្រូវចំពោះអ្នកដំណើររបស់ខ្លួន ។

**ប្រការ ៣ :**

កម្រិតទឹកប្រាក់កាតព្វកិច្ចធានារ៉ាប់រងអប្បបរមាការដឹកជញ្ជូនអ្នកដំណើរ ត្រូវកំណត់ដូចខាងក្រោម:

- ៥ ០០០ ដុល្លារអាមេរិកជាកម្រិតទឹកប្រាក់កាតព្វកិច្ចធានារ៉ាប់រងអប្បបរមាសម្រាប់របួសរាងកាយ ឬ ស្លាប់ក្នុងមនុស្សម្នាក់
- ៥០ ០០០ ដុល្លារអាមេរិកជាកម្រិតទឹកប្រាក់កាតព្វកិច្ចធានារ៉ាប់រងអប្បបរមាសម្រាប់របួសរាងកាយ ឬ ស្លាប់ក្នុងគ្រោះថ្នាក់មួយករណី
- ១ ០០០ ដុល្លារអាមេរិកជាកម្រិតទឹកប្រាក់កាតព្វកិច្ចធានារ៉ាប់រងអប្បបរមាសម្រាប់ការខូចខាតទ្រព្យសម្បត្តិ
- ១០០ ០០០ ដុល្លារអាមេរិកជាកម្រិតទឹកប្រាក់កាតព្វកិច្ចធានារ៉ាប់រងអប្បបរមាសម្រាប់របួសរាងកាយ ឬ ស្លាប់ក្នុងគ្រោះថ្នាក់មួយករណីចំពោះម្ចាស់មធ្យោបាយដឹកជញ្ជូនណាដែលដឹកអ្នកដំណើរមានចំនួន ១០ នាក់ ឬ លើសពី ១០ នាក់
- ២៥០ ០០០ ដុល្លារអាមេរិកជាកម្រិតទឹកប្រាក់កាតព្វកិច្ចធានារ៉ាប់រងអប្បបរមាសម្រាប់របួសរាងកាយ ឬ ស្លាប់ក្នុងគ្រោះថ្នាក់មួយករណីចំពោះម្ចាស់មធ្យោបាយដឹកជញ្ជូនណាដែលដឹកអ្នកដំណើរមានចំនួន ៥០ នាក់ ឬ លើសពី ៥០ នាក់ ។

**ប្រការ ៤ :**

កាតព្វកិច្ចធានារ៉ាប់រងអ្នកដំណើរគឺ ត្រូវបានតម្រូវឱ្យទិញនៅក្រុមហ៊ុនធានារ៉ាប់រងដែលមានអាជ្ញាប័ណ្ណធ្វើអាជីវកម្មធានារ៉ាប់រងនៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែក្នុងករណីក្រសួងសេដ្ឋកិច្ច និង

ហិរញ្ញវត្ថុកំណត់ថាលតាបត្រនេះមិនត្រូវបានបង់ឱ្យទិញនៅក្នុងក្រុមហ៊ុនធានារ៉ាប់រងក្នុងស្រុក ។ ចំពោះការដឹកជញ្ជូនអ្នកដំណើរជាលក្ខណៈអន្តរជាតិ កាតព្វកិច្ចធានារ៉ាប់រងអ្នកដំណើរ ត្រូវបានស្ថិតនៅក្នុងកិច្ចព្រមព្រៀងនៃការធ្វើដំណើរជាអន្តរជាតិរួចហើយ គឺមិនត្រូវគិតបញ្ចូលជាកាតព្វកិច្ចនៅក្នុងប្រកាសនេះទេ ។ កាតព្វកិច្ចធានារ៉ាប់រងអ្នកដំណើរមិនទទួលខុសត្រូវសំណងចំពោះអ្នកដំណើរទាំងឡាយណាដែលពុំបានបង់ថ្លៃធ្វើដំណើរឡើយ ។

**ប្រការ ៥ :**

ពេលមានគ្រោះថ្នាក់កើតឡើងពាក់ព័ន្ធនឹងអ្នកដំណើរនៅពេលឡើងជិះ ពេលកំពុងជិះ ក៏ដូចពេលចុះពីមធ្យោបាយធ្វើដំណើរដែលមានការធានារ៉ាប់រង ប្រតិបត្តិករមធ្យោបាយធ្វើដំណើរ ត្រូវរិះរកគ្រប់វិធីដើម្បីជួយសង្គ្រោះជនរងគ្រោះភ្លាមៗ ទន្ទឹមនឹងនោះ ត្រូវរាយការណ៍ទៅក្រុមហ៊ុនធានារ៉ាប់រងរបស់ខ្លួនជាបន្ទាន់ ។

**ប្រការ ៦ :**

ម្ចាស់មធ្យោបាយដឹកជញ្ជូនអ្នកដំណើរ ត្រូវបានក្រុមហ៊ុនធានារ៉ាប់រងចេញប្រាក់សំណងជំនួសជូនដល់ជនរងគ្រោះទៅតាមកម្រិតទទួលខុសត្រូវ ដែលបានព្រមព្រៀងគ្នាក្នុងកិច្ចសន្យា ឬ ក្នុងកំណត់សំអាង ។ សំណងត្រូវតែដោះស្រាយឱ្យបានក្នុងរយៈពេល ១០ ថ្ងៃយ៉ាងយូរ ក្រោយពេលដែលបានទទួលសំណុំលិខិតគ្រោះថ្នាក់ចរាចរគ្រប់គ្រាន់រួចហើយ រួមទាំងរបាយការណ៍នគរបាលចរាចរផងដែរ លើកលែងតែក្រុមហ៊ុនធានារ៉ាប់រងយល់ឃើញថាសំណងនេះ គ្មាននៅក្នុងល័ក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងធានារ៉ាប់រង ឬ សំណងមានច្រើនហួសហេតុ ។

**ប្រការ ៧ :**

នៅពេលផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូន ឬ លិខិតអនុញ្ញាតបន្តធ្វើអាជីវកម្មដឹកជញ្ជូនអ្នកដំណើរដល់ម្ចាស់ ឬ ប្រតិបត្តិករមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ ក្រសួងសាធារណការ និង ដឹកជញ្ជូន ត្រូវតម្រូវឱ្យម្ចាស់ ឬ ប្រតិបត្តិករមធ្យោបាយដឹកជញ្ជូនបង្ហាញនូវឯកសារកាតព្វកិច្ចធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរ ។

នៅពេលដែលប្រកាសនេះមានប្រសិទ្ធភាព ម្ចាស់ដែលមានលិខិតអនុញ្ញាតស្រាប់លើការដឹកជញ្ជូនអ្នកដំណើរ មានរយៈពេល ៦០ ថ្ងៃ សម្រាប់ផ្តល់ឯកសារកាតព្វកិច្ចធានារ៉ាប់រងចំពោះក្រសួងសាធារណការ និង ដឹកជញ្ជូន ។

ប្រសិនបើម្ចាស់ ឬ ប្រតិបត្តិករ ខកខានមិនបានទិញធានារ៉ាប់រងកាតព្វកិច្ចទេនោះ អាជ្ញាធរមានសមត្ថកិច្ចដូចបានពោលខាងលើ ត្រូវដកហូតលិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូន និង វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសជាបណ្តោះអាសន្នរហូតដល់ម្ចាស់ ឬ ប្រតិបត្តិករ បានផ្តល់ឯកសារកាតព្វកិច្ចធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរត្រឹមត្រូវតាមការកំណត់ ។

## ប្រការ ៨ :

នគរបាលចរាចរ និង នគរបាលសណ្តាប់ធ្នាប់ខេត្ត-ក្រុង ដែលមានភារកិច្ចត្រួតពិនិត្យតាមដងផ្លូវ និង នៅតាមចំណតរថយន្តឈ្នួលទាំងអស់ ត្រូវត្រួតពិនិត្យលតាប័ត្រធានារ៉ាប់រងឱ្យបានម៉ត់ចត់នៅលើគញ្ចក់មធ្យោបាយដឹកជញ្ជូនអ្នកដំណើរ ដើម្បីរកឱ្យឃើញនូវមធ្យោបាយដឹកជញ្ជូនទាំងឡាយណាដែលមិនបានអនុវត្តកាតព្វកិច្ចធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរ ។ ក្នុងករណីមិនមានលតាប័ត្រធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរ ម្ចាស់ ឬ ប្រតិបត្តិករមធ្យោបាយដឹកជញ្ជូន ត្រូវទទួលពិន័យតាមមាត្រា ៥២ នៃច្បាប់ស្តីពីការធានារ៉ាប់រង ។ នគរបាលចរាចរខេត្ត-ក្រុងត្រូវ:

១-ផាកពិន័យ និង ណែនាំឱ្យម្ចាស់ និង ប្រតិបត្តិករទៅទិញធានារ៉ាប់រងក្នុងរយៈពេលយ៉ាងយូរ ៧ ថ្ងៃ

២-ក្នុងករណីមិនព្រមអនុវត្តតាមការណែនាំខាងលើ ត្រូវដកហូតលិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូន និង វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេស

៣-ក្នុងករណីមិនរាងចាល ត្រូវឃាត់យានយន្តទុកជាបណ្តោះអាសន្នមិនឱ្យដំណើរការដឹកជញ្ជូនបន្តទៀត រហូតដល់ម្ចាស់ ឬ ប្រតិបត្តិករ បានផ្តល់ឯកសារកាតព្វកិច្ចធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរ ត្រឹមត្រូវតាមការកំណត់ ។

## ប្រការ ៩ :

ក្នុងករណីដែលលតាប័ត្រកាតព្វកិច្ចធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរ ត្រូវបានលុបចោលដោយអ្នកធានារ៉ាប់រង ដោយអ្នកត្រូវបានធានារ៉ាប់រងមិនបានទូទាត់បុព្វលាភរ៉ាប់រង ឬ ដោយការមិនគោរពតាមល័ក្ខខ័ណ្ឌធានារ៉ាប់រង នោះអ្នកធានារ៉ាប់រង ត្រូវជូនដំណឹងពីការលុបចោលលតាបត្រ័នេះទៅអាជ្ញាធរមានសមត្ថកិច្ច ដែលបានចេញលិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូនអ្នកដំណើរ ។

## ប្រការ ១០ :

ក្រសួងសាធារណការ និង ដឹកជញ្ជូន មានភារកិច្ចធ្វើអធិការកិច្ចជាទៀងទាត់ ចំពោះឯកសាររបស់ម្ចាស់ ឬ ប្រតិបត្តិករដឹកជញ្ជូនអ្នកដំណើរ ហើយទាមទារឯកសារធានារ៉ាប់រង ដែលមានសុពលភាព និង ត្រូវទទួលខុសត្រូវក្នុងការផ្តល់វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេស និង លិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូនអ្នកដំណើរទាំងអស់ ។ ការខកខានរបស់ម្ចាស់ ឬ ប្រតិបត្តិករមធ្យោបាយដឹកជញ្ជូនក្នុងការផ្តល់ឯកសារអំពីកាតព្វកិច្ចធានារ៉ាប់រង ត្រូវយកជាមូលដ្ឋានសម្រាប់ធ្វើការផាកពិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពីការធានារ៉ាប់រង និង សម្រាប់ការព្យួរ ឬ ការដកហូតលិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូនពីម្ចាស់ ឬ ប្រតិបត្តិករដឹកជញ្ជូនអ្នកដំណើរ ។

ក្រសួងទេសចរណ៍ មានភារកិច្ចធ្វើអធិការកិច្ចជាទៀងទាត់ចំពោះឯកសាររបស់ម្ចាស់ ឬ ប្រតិបត្តិករមធ្យោបាយដឹកជញ្ជូនភ្ញៀវទេសចរ ហើយទាមទាររកឯកសារធានារ៉ាប់រង ដែលមានសុពលភាព និង ត្រូវទទួលខុសត្រូវក្នុងការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍ និង មានភារកិច្ចអប់រំដល់ផ្នែកឧស្សាហកម្មទេសចរណ៍អំពីកាតព្វកិច្ចធានារ៉ាប់រង

នាយកដ្ឋានឯកសារអក្សរហិរញ្ញវត្ថុ

លើការដឹកជញ្ជូនភ្ញៀវទេសចរ ហើយធ្វើយ៉ាងណាឱ្យភ្នាក់ងារទេសចរប្រើប្រាស់តែមធ្យោបាយដឹកជញ្ជូនណាដែលមានកាតព្វកិច្ចធានារ៉ាប់រង ។ ការខកខានរបស់ម្ចាស់ ឬ ប្រតិបត្តិករមធ្យោបាយដឹកជញ្ជូនក្នុងការផ្តល់ឯកសារអំពីកាតព្វកិច្ចធានារ៉ាប់រង ត្រូវយកជាមូលដ្ឋានសម្រាប់ធ្វើការដាក់ពិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពីការធានារ៉ាប់រង និងសម្រាប់ការព្យួរ ឬ ការដកហូតអាជ្ញាប័ណ្ណទេសចរណ៍ ។

ក្រសួងមហាផ្ទៃ មានភារកិច្ចត្រួតពិនិត្យវិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេស លិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូនអ្នកដំណើរ ឬ អាជ្ញាប័ណ្ណទេសចរណ៍ និង លតាប័ត្រកាតព្វកិច្ចធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរចំពោះមធ្យោបាយដឹកជញ្ជូនអ្នកដំណើរគ្រប់ប្រភេទ ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានភារកិច្ចទទួលខុសត្រូវក្នុងការត្រួតពិនិត្យដោះស្រាយជាបន្ទាន់ប្រកបដោយយុត្តិធម៌ចំពោះពាក្យបណ្តឹងលើកាតព្វកិច្ចធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរ ។

**ប្រការ ១១ :**

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ១២ :**

គ្រប់ស្ថាប័ន ឬ អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងទាំងបួន ត្រូវអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀង១ខ្លួន ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រី
ក្រសួងមហាផ្ទៃ
ស ខេង

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងទេសចរណ៍
វេង សេរីវុឌ្ឍ

រដ្ឋមន្ត្រី
ក្រសួងសាធារណការ និង ដឹកជញ្ជូន
ឃី តាំងលីម

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
គាត ឈន់

**កន្លែងទទួល**

- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន

  " ដើម្បីជូនជ្រាប "
- -ដូចប្រការ ១២
- -គ្រប់សាលាខេត្ត-ក្រុង

  " ដើម្បីអនុវត្ត "
- -ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់

-ក្រសួងមហាផ្ទៃ

លេខ ៦៥៥ ប្រក.សហវ-ដនស-មផ

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែតុលា ឆ្នាំ ២០០២

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ភារកិច្ចធានារ៉ាប់រងតារៈទទួលខុសត្រូវការដ្ឋាន

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ-ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ និង ក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៨៦ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់ លេខ ៨៦/អនក្រ/បក ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៧
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០០/០២ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យ លេខ ១០៦ អនក្រ.ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០១ ណែនាំអនុវត្តច្បាប់ស្តីពីការធានារ៉ាប់រង
- យោងតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# សំរេច

**ប្រការ ១ :**

ការធានារ៉ាប់រងលើភារៈទទួលខុសត្រូវការដ្ឋាន មានសារៈសំខាន់ក្នុងកិច្ចការពារផលប្រយោជន៍របស់តតិយជនទាំងឡាយដែលរស់នៅក្នុង ឬ ជុំវិញការដ្ឋាន ឬ ធ្វើដំណើរឆ្លងកាត់ ឬ ក្បែរការដ្ឋាន ។ រាល់រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលជាម្ចាស់ការដ្ឋាន អ្នកម៉ៅការ អ្នកម៉ៅការបន្ត មានភារកិច្ចទទួលខុសត្រូវចំពោះគ្រោះថ្នាក់ទាំងឡាយ ទោះបីលើរូបរាងកាយក្តី ឬ ស្លាប់ក្តី ឬ ទ្រព្យសម្បត្តិក្តី របស់តតិយជនដែលបានបង្កឡើង ដោយសកម្មភាពរបស់ការដ្ឋាន ។

**ប្រការ ២ :**

គ្រប់ការដ្ឋានសាងសង់ ជួសជុល តម្លើងទាំងអស់ ដែលទទួលខុសត្រូវដោយសហគ្រិន អ្នកម៉ៅការ ឬ អ្នកម៉ៅការបន្ត ចាំបាច់ត្រូវមានការធានារ៉ាប់រងលើភារៈទទួលខុសត្រូវការដ្ឋាន ។

ប្រភេទការដ្ឋានដែលត្រូវបានលើកលែងមិនចាំបាច់មានការធានារ៉ាប់រងលើភារៈទទួលខុសត្រូវរួមមាន :

-ការដ្ឋានសាងសង់ដែលដំណើរការដោយស្ថាប័នរដ្ឋាភិបាល

-ការដ្ឋានសាងសង់ ជួសជុល តម្លើង ដែលទទួលបន្ទុកដោយនីតិបុគ្គលនៃនីតិសាធារណៈ ដើម្បីផលប្រយោជន៍សាធារណៈ ដែលក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ អះអាងថាមានលទ្ធភាពជួសជុលសងបានរាប់រហ័ស និង គ្រប់គ្រាន់នូវការខូចខាតទាំងឡាយ ។

-ការដ្ឋានសាងសង់ជួសជុលកែលំអតូចតាច ដែលមិនតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ ។

**ប្រការ ៣ :**

កម្រិតទឹកប្រាក់កាតព្វកិច្ចធានារ៉ាប់រងអប្បបរមាភារៈទទួលខុសត្រូវការដ្ឋានត្រូវកំណត់ដូចខាងក្រោម:

- ៥ 000 ដុល្លារអាមេរិកជាកម្រិតទឹកប្រាក់កាតព្វកិច្ចធានារ៉ាប់រងអប្បបរមាសម្រាប់របួសរាងកាយ ឬ ស្លាប់ក្នុងមនុស្សម្នាក់
- ២៥ 000 ដុល្លារអាមេរិកជាកម្រិតទឹកប្រាក់កាតព្វកិច្ចធានារ៉ាប់រងអប្បបរមាសម្រាប់របួសរាងកាយ ឬ ស្លាប់ក្នុងគ្រោះថ្នាក់មួយករណី
- ១0 000 ដុល្លារអាមេរិកជាកម្រិតទឹកប្រាក់កាតព្វកិច្ចធានារ៉ាប់រងអប្បបរមាសម្រាប់ការខូចខាតទ្រព្យសម្បត្តិ ។

**ប្រការ ៤ :**

ការដ្ឋានសំណង់ដែលប្រើប្រាស់ថវិកាឯកជន នៅពេលផ្តល់លិខិតអនុញ្ញាតសាងសង់ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ ឬ មន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និង សុរិយោដីខេត្ត-ក្រុង មានភារកិច្ចណែនាំដល់ម្ចាស់សំណង់ឱ្យចុះកិច្ចសន្យាតែជាមួយសហគ្រិន អ្នកម៉ៅការ ឬ អ្នកម៉ៅការបន្តណាដែលមានការធានារ៉ាប់រងលើភារៈទទួលខុសត្រូវការដ្ឋាន ។ ការដ្ឋានសាងសង់នឹងមិនអាចមានដំណើរការបានទេ ដរាបណាការដ្ឋាននោះនៅមិនទាន់មានកាតព្វកិច្ចធានារ៉ាប់រងលើភារៈទទួលខុសត្រូវការដ្ឋាន ។

**ប្រការ ៥ :**

គម្រោងសាងសង់ទាំងឡាយណាដែលមិនស្ថិតក្នុងប្រភេទការដ្ឋានដែលត្រូវបានលើកលែងពីកាតព្វកិច្ចធានារ៉ាប់រង ដូចមានចែងក្នុងប្រការ ២ ដោយប្រើប្រាស់គម្រោងថវិការដ្ឋ ឬ ថវិកាជំនួយនានា ក្រោយពេលដេញថ្លៃបាន អ្នកដេញថ្លៃបានត្រូវភ្ជាប់មកជាមួយសំណុំឯកសារដេញថ្លៃ នូវកំណត់សំអាងបណ្ដោះអាសន្ន ដែលចេញដោយក្រុមហ៊ុនធានារ៉ាប់រងណាមួយដែលមានអាជ្ញាប័ណ្ណត្រឹមត្រូវនៅក្នុងព្រះរាជាណាចក្រកម្ពុជា បញ្ជាក់អំពីការធានារ៉ាប់រងលើភារៈទទួលខុសត្រូវការដ្ឋាន ។ ក្នុងករណីសំណុំឯកសារមិនបានភ្ជាប់មកជាមួយនូវកំណត់សំអាងបណ្ដោះអាសន្នទេនោះ អ្នកស្នើសុំដេញថ្លៃនោះមិនមានសិទ្ធិទទួលបាននូវគម្រោងសាងសង់យកទៅបើកការដ្ឋានឡើយ ។ កំណត់សំអាងបណ្ដោះអាសន្ននេះ នឹងត្រូវជំនួសដោយវិញ្ញាបនបត្រធានារ៉ាប់រងវិញនៅពេលបើកការដ្ឋានសាងសង់ ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងមិនផ្ដល់ថវិកាទេ ដរាបណាគម្រោងសុំទូទាត់ថ្លៃសាងសង់មិនមានភ្ជាប់ជាមួយនូវឯកសារធានារ៉ាប់រង ។

**ប្រការ ៦ :**

នៅពេលសុំបើកការដ្ឋាន ម្ចាស់សំណង់ ត្រូវបង្ហាញឯកសារធានារ៉ាប់រងថាបានចុះកិច្ចសន្យាធានារ៉ាប់រងជាមួយក្រុមហ៊ុនធានារ៉ាប់រងណាមួយដែលមានអាជ្ញាប័ណ្ណត្រឹមត្រូវនៅព្រះរាជាណាចក្រ កម្ពុជារួចហើយ ។ បើសុំណុំឯកសារពុំមានភ្ជាប់ជាមួយនូវកំណត់សំអាង ឬ វិញ្ញាបនបត្រធានារ៉ាប់រងទេ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ ឬ មន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និង សុរិយោដីខេត្ត-ក្រុង មិនចេញលិខិតអនុញ្ញាតបើកការដ្ឋានឡើយ ។

**ប្រការ ៧ :**

ពេលការដ្ឋានកំពុងដំណើរការ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ ឬ មន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និង សុរិយោដីខេត្ត-ក្រុង និង អាជ្ញាធរមានសមត្ថកិច្ចនៅមូលដ្ឋាន មានភារកិច្ចត្រួតពិនិត្យផ្ទាល់ដល់ការដ្ឋាន និង សួររកវិញ្ញាបនបត្រធានារ៉ាប់រង ។ ក្នុងករណីគ្មានវិញ្ញាបនបត្រធានារ៉ាប់រងដែលតម្រូវទេនោះ ក្រុមត្រួតពិនិត្យការដ្ឋាននៅមូលដ្ឋាននោះត្រូវបញ្ឈប់សកម្មភាពការដ្ឋានជាបណ្ដោះអាសន្ន ហើយតម្រូវឱ្យទិញធានារ៉ាប់រង ។ ប្រសិនបើនៅតែមិនព្រមអនុវត្តតាម នឹងត្រូវទទួលរងនូវការពិន័យតាមមាត្រា ៥២ នៃច្បាប់ស្ដីពីការធានារ៉ាប់រង ។

**ប្រការ ៨ :**

ក្នុងករណីដែលអ្នកធានារ៉ាប់រងបានលុបចោលការធានារ៉ាប់រង ដោយអ្នកត្រូវបានធានារ៉ាប់រងមិនបានបង់នូវបុព្វលាភរ៉ាប់រង ឬ ដោយការមិនគោរពតាមល័ក្ខខ័ណ្ឌធានារ៉ាប់រង នោះអ្នកធានារ៉ាប់រងត្រូវជូនដំណឹងពីការលុបការធានារ៉ាប់រងនេះ ដល់ក្រសួងដែនដីនគរូបនីយកម្ម និង សំណង់ និង មន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និង សុរិយោដីខេត្ត-ក្រុង និងអាជ្ញាធរមានសមត្ថកិច្ចនៅមូលដ្ឋាន ។

**ប្រការ ៩ :**

ក្នុងករណីដែលម៉ៅការបាយដឹកជញ្ជូនមានការធានារ៉ាប់រងតតិយជន បានបង្កគ្រោះថ្នាក់ក្នុងការដ្ឋានដែលមានការធានារ៉ាប់រងលើភារៈទទួលខុសត្រូវការដ្ឋាន នោះអ្នកធានារ៉ាប់រងម៉ៅការបាយដឹកជញ្ជូន ត្រូវទទួលធ្វើសំណងជាមុន

និង អ្នកធានារ៉ាប់រងការៈទទួលខុសត្រូវការដ្ឋាន ត្រូវទទួលធ្វើសំណងបន្ទាប់ បើល័ក្ខខ័ណ្ឌនៃការធានារ៉ាប់រងការៈទទួលខុសត្រូវការដ្ឋានមានជាប់ កិច្ចសន្យាក្នុងករណីនេះ ។

**ប្រការ ១០ :**

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ១១ :**

គ្រប់ស្ថាប័ន ឬ អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងទាំងបី ត្រូវអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

| | | |
|---|---|---|
| ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី<br>សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ | រដ្ឋមន្ត្រី<br>ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |
| សរ ខេង    យូ ហុកគ្រី | អ៊ឹម ឈុនលឹម | គាត ឈន់ |

**កន្លែងទទួល**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ១១
- គ្រប់សាលាខេត្ត-ក្រុង
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

Manulife

# កិច្ចសន្យានៃប័ណ្ណសន្យារ៉ាប់រង

ឈ្មោះអ្នកត្រូវបានធានាអាយុជីវិត ជាភាសាអង់គ្លេស : IM CHANMONY
ឈ្មោះអ្នកត្រូវបានធានាអាយុជីវិត ជាភាសាខ្មែរ : ( ដូចក្នុងទម្រង់បែបបទស្នើសុំការធានារ៉ាប់រង )
លេខប័ណ្ណសន្យារ៉ាប់រង : 9000275305

បុព្វលាភរ៉ាប់រង ដែលត្រូវបានបង្ហាញនៅក្នុង "កាលវិភាគនៃបុព្វលាភរ៉ាប់រង" នៅលើទំព័រទី3 នឹងត្រូវបង់ក្នុងអំឡុងពេលនៃការបង់បុព្វលាភរ៉ាប់រង។

ប័ណ្ណសន្យារ៉ាប់រងនេះមានលក្ខណៈបែបចូលរួមដែលមានការផ្តល់ជូននូវភាគលាភប្រចាំឆ្នាំ។

បញ្ញត្តិ និងលក្ខខណ្ឌដែលមាននៅលើទំព័របន្ទាប់នេះគឺជាផ្នែកមួយនៃប័ណ្ណសន្យារ៉ាប់រងនេះ។

KINGDOM OF CAMBODIA
MANULIFE (CAMBODIA)

**Robert Elliott**

អគ្គនាយកប្រតិបត្តិ និងនាយកចាត់ការទូទៅ

ក្រុមហ៊ុនម៉េនូឡាយហ្វ៍ (ខេមបូឌា) ភីអិលស៊ី

ក្រុមហ៊ុនម៉េនូឡាយហ្វ៍ (ខេមបូឌា) ភីអិលស៊ី
ជាន់ទី៨ អគារលេខ ១០៨ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទូរស័ព្ទផ្នែកសេវាបម្រើអតិថិជន: (855) 23 965 999, ទូរសារលេខ (855) 23 965 966



MANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFE
MANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFE

Manulife

# សេចក្តីសង្ខេបនៃបណ្ណសន្យារ៉ាប់រង

| | | | |
|---|---|---|---|
| លេខបណ្ណសន្យារ៉ាប់រង | 9000275305 | កាលបរិច្ឆេទបណ្ណសន្យារ៉ាប់រងចាប់ផ្តើមមានសុពលភាព | 04-APR-2017 |
| កាលបរិច្ឆេទផ្តល់ជូនបណ្ណសន្យារ៉ាប់រង | -04-APR-2017 | កាលបរិច្ឆេទដល់កាលកំណត់នៃបណ្ណសន្យារ៉ាប់រង | 04-APR-2036 |

| | | | |
|---|---|---|---|
| <u>ម្ចាស់បណ្ណសន្យារ៉ាប់រង:</u> | | <u>អ្នកត្រូវបានធានាអាយុជីវិត:</u> | |
| ឈ្មោះ: | IM SOKCHENDA | ឈ្មោះ: | IM CHANMONY |
| លេខអត្តសញ្ញាណប័ណ្ណ | 010895845 | លេខអត្តសញ្ញាណប័ណ្ណ | 36/01/2013 |
| ថ្ងៃខែឆ្នាំកំណើត | 20-MAR-1976 | ថ្ងៃខែឆ្នាំកំណើត | 06-APR-2013 |
| អាយុនៅពេលបណ្ណសន្យារ៉ាប់រងត្រូវបានផ្តល់ជូន | 41 | អាយុនៅពេលបណ្ណសន្យារ៉ាប់រងត្រូវបានផ្តល់ជូន | 3 |
| ភេទ | M | ភេទ | M |
| ចំនួនទឹកប្រាក់ត្រូវបានធានា | 6,000 | ចំនួនទឹកប្រាក់ត្រូវបានធានា | 6,000 |

| | |
|---|---|
| ប្រភេទនៃការធានារ៉ាប់រងជាមូលដ្ឋាន | អនាគតការសិក្សារបស់កូនខ្ញុំជាមួយម៉េនូឡាយហ្វ៍ 22 (USD), Manulife Education Protector 22 (USD) មានលក្ខណៈបែបចូលរួមចំណែក ដែលមានរយៈពេលបង់បុព្វលាភរ៉ាប់រងចំនួន 16 ឆ្នាំ និងទទួលបានភាគលាភទុកជាប្រាក់តម្កល់ជាមួយក្រុមហ៊ុនដោយទទួលបានការប្រាក់។ |
| ផលប្រយោជន៍បន្ថែម | ផលប្រយោជន៍អ្នកបង់ប្រាក់– លើកលែងបុព្វលាភរ៉ាប់រង<br>ផលប្រយោជន៍អ្នកបង់ប្រាក់– ពិការភាពទាំងស្រុង / អាយុជីវិត |
| រូបិយប័ណ្ណ | រាល់ចំនួនទឹកប្រាក់ដែលបានកំណត់នៅលើទំព័រនេះ និងនៅក្នុងបណ្ណសន្យារ៉ាប់រងទាំងមូលគឺត្រូវគិតជា USD។ |
| អ្នកទទួលផលប្រយោជន៍ | PRIMARY - ថៅ ស៊ីណា, ម្តាយ (100%) |

កាលវិភាគបុព្វលាភរ៉ាប់រង — បុព្វលាភរ៉ាប់រងប្រចាំឆ្នាំត្រូវបានបង្កើតឡើងដូចខាងក្រោម:

| | <u>បុព្វលាភរ៉ាប់រងត្រូវបង់រហូតដល់</u> | <u>បុព្វលាភរ៉ាប់រង</u> |
|---|---|---|
| គម្រោងធានារ៉ាប់រងជាមូលដ្ឋាន | 04-APR-2033 | 366 |
| ផលប្រយោជន៍អ្នកបង់ប្រាក់– លើកលែងបុព្វលាភរ៉ាប់រង | 04-APR-2033 | 26 |
| ផលប្រយោជន៍អ្នកបង់ប្រាក់– ពិការភាពទាំងស្រុង / អាយុជីវិត | 04-APR-2036 | 58 |
| សរុប | | 450 |

បណ្ណសន្យារ៉ាប់រងនេះត្រូវបានផ្តល់ជូននៅក្នុងព្រះរាជាណាចក្រកម្ពុជា។



MANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFE
MANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFEMANULIFE

RECEIVED
2 5 FEB 2016

KHIN MONYRATH

25/2

PRUDENTIAL

# ពាក្យស្នើសុំ / APPLICATION FORM

Application No: 151 101440

$298.58

| | Day | Month | Year |
|---|---|---|---|
| Application Date: | 25 | 02 | 2016 |
| Receipt Date: | 25 | 02 | 2016 |

Receipt No.: 80098282

Policy Number: 80037066

| Name of Life Insurance Specialist / Life Insurance Consultant | Branch Name | Code of Life Insurance Specialist / Life Insurance Consultant | Telephone No. |
|---|---|---|---|
| Tam Vicheth | PNP | 69001158 | 095307222 |

PLEASE READ THESE INFORMATION CAREFULLY BEFORE FILLING THIS APPLICATION FORM

a) PLEASE FILL IN CLEARLY WITH BLUE / BLACK INK ONLY

b) PLEASE MAKE SURE ALL INFORMATION PROVIDED BY YOU IS ACCURATE AND PLEASE DISCLOSE ALL INFORMATION. NON DISCLOSURE OF INFORMATION / MISREPRESENTATION MAY RESULT IN INVALIDATING YOUR POLICY

c) PLEASE ASK LIFE INSURANCE SPECIALIST / LIFE INSURANCE CONSULTANT FOR HELP, IN CASE YOU NEED ANY CLARIFICATION ON THIS APPLICATION.

## DETAILS OF POLICY OWNER

50085697

| | |
|---|---|
| Full name as on ID Card / Passport (Capital Letter) | Say Theary |
| Relationship to Life Assured | PO=LA |
| Gender and Marital Status | ☐ Male ☑ Female ☐ Single ☑ Married ☐ Widowed ☐ Divorced |
| ID Card / Passport number | 010048189 |
| Date of birth / Age at last birthday | 13-10-1981 / 34 |
| Country of birth / Nationality | Cambodia / Khmer |
| Height / Weight | 1.60 / 59 |
| Occupation | |
| Exact duty | |
| Average monthly individual income in last 12 months | 1200 / |
| Do you currently file a tax return in the US? | ☑ NO ☐ YES |

| | | | | |
|---|---|---|---|---|
| Children | 0 - 10 years old | NA | Above 10 years | 02 |
| Assets: (1) Car | NO | NA | YES | 01 |
| (2) House | NO | NA | YES | 01 |

Correspondence Address: N°08 St 271

Province / Country: PhnomPenh Cambodia

Cell phone - mandatory: 0979996400

Country of phone no.: (+855) Cambodia

Cell phone (secondary): 011816426

E-mail: NA

I would like to receive company updates through SMS / E-mail ☐ NO ☑ YES

Is Policy Owner a main Life Assured? ☐ NO ☑ YES

If Yes, please skip Section III " DETAILS OF LIFE ASSURED "

## DETAILS OF LIFE INSURANCE PROPOSED

| | |
|---|---|
| Product Code | |
| Product Name | edusave |
| Sum Assured of Basic Plan | 2000 |
| Policy Term of Basic Plan | 15 |
| Premium Payment Term | 15 |

XTRA

Payment method: ☐ Monthly ☐ Half-yearly ☑ Yearly

Payment method: ☑ Non-cash ☐ Cash

Non-cash method, give you discount

លេខពាក្យស្នើសុំ
Application No: 151101440

| ប្រយោជន៍នៃលក្ខខណ្ឌបន្ថែម<br>...rs Benefits | បុគ្គលដែលជាកម្មវត្ថុនៃការធានា ទី១<br>Life Assured 1<br>ទឹកប្រាក់ធានារ៉ាប់រង (ដុល្លារអាមេរិក)<br>Sum Assured (USD) | រយៈពេល (ឆ្នាំ)<br>Term (year) | បុគ្គលដែលជាកម្មវត្ថុនៃការធានា ទី២<br>Life Assured 2<br>ទឹកប្រាក់ធានារ៉ាប់រង (ដុល្លារអាមេរិក)<br>Sum Assured (USD) | រយៈពេល (ឆ្នាំ)<br>Term (year) |
|---|---|---|---|---|
| ...ប្រយោជន៍ធានារ៉ាប់រងមានតម្លៃ...<br>...ent Coverage Benefit | 3000 | 15 | | |
| ...ប្រយោជន៍ចំណូលគ្រួសារ<br>...nily Income Benefit | 200 | 15 | | |

បុព្វលាភធានារ៉ាប់រងសរុបត្រូវទូទាត់ជាដំណាក់កាល
Total Installment Premium: 288.58

---

## ព័ត៌មានលម្អិតអំពីបុគ្គលដែលជាកម្មវត្ថុនៃការធានា / DETAILS OF LIFE ASSURED

| | បុគ្គលដែលជាកម្មវត្ថុនៃការធានា ទី១<br>Life Assured 1 | បុគ្គលដែលជាកម្មវត្ថុនៃការធានា ទី២<br>Life Assured 2 |
|---|---|---|
| ...ឈ្មោះពេញតាមអត្តសញ្ញាណប័ណ្ណ / លិខិតឆ្លងដែន / Full name as on ...Card / Passport (Capital Letter) | | |
| ...ទំនាក់ទំនងជាមួយម្ចាស់បណ្ណសន្យារ៉ាប់រង / ...ationship to Policy Owner | | |
| ...ភេទ និង ស្ថានភាពគ្រួសារ / ...and Marital Status | ☐ ប្រុស Male ☐ នៅលីវ Single ☐ មេម៉ាយ-ពោះម៉ាយ Widowed<br>☐ ស្រី Female ☐ រៀបការ Married ☐ លែងលះ Divorced | ☐ ប្រុស Male ☐ នៅលីវ Single ☐ មេម៉ាយ-ពោះម៉ាយ Widowed<br>☐ ស្រី Female ☐ រៀបការ Married ☐ លែងលះ Divorced |
| ...លេខអត្តសញ្ញាណប័ណ្ណ / លិខិតឆ្លងដែន / ...ard / Passport number | | |
| ...ថ្ងៃខែឆ្នាំកំណើត / អាយុនៅថ្ងៃខួបកំណើតចុងក្រោយ / Date of birth / Age at last birthday | | |
| ...ទីកន្លែងកំណើត / Country of birth<br>...សញ្ជាតិ / Nationality | | |
| ...កម្ពស់ / ទម្ងន់ / Height / Weight | | |
| ...មុខរបរ / Occupation | | |
| ...តួនាទីពិតប្រាកដ / Exact duty | | |
| ...ប្រាក់ចំណូលប្រចាំខែជាមធ្យមក្នុងរយៈពេល ១២ ខែ ចុងក្រោយ<br>...rage monthly individual income in last 12 months | | |
| ...អាសយដ្ឋាន / Address | | |
| ...ខេត្ត និងប្រទេស / Province / Country | | |
| ...លេខទូរស័ព្ទ (Cell phone - mandatory) | | |
| ...លេខទូរស័ព្ទទំនាក់ទំនងទីពីរ (secondary) | | |
| ...អ៊ីមែល / E-mail | | |

---

...សូមបំពេញក្នុងផ្នែកនេះដោយផ្តល់ព័ត៌មានឲ្យបានពេញលេញ និងឲ្យបានច្បាស់លាស់បំផុតតាមដែលលោកអ្នកដឹង
...EASE FILL IN THIS SECTION WITH FULL DISCLOSURE AND TO THE BEST OF YOUR KNOWLEDGE

### សេចក្តីប្រកាសអំពីសុខភាពរបស់បុគ្គលដែលជាកម្មវត្ថុនៃការធានា / HEALTH DECLARATION FOR LIFE ASSURED

...សូមគូស √ ក្នុងប្រអប់សមស្រប ប្រសិនបើ បាទ/ចាស សូមផ្តល់ព័ត៌មានលម្អិត
...se tick √ in the appropriate box. If "YES", please give details

| | បុគ្គលដែលជាកម្មវត្ថុនៃការធានាទី១<br>Life Assured 1<br>គ្មាន NO | មាន YES | បើមាន សូមរៀបរាប់លម្អិត<br>If "YES", please give details | បុគ្គលដែលជាកម្មវត្ថុនៃការធានាទី២<br>Life Assured 2<br>គ្មាន NO | មាន YES | បើមាន សូមរៀបរាប់លម្អិត<br>If "YES", please give details |
|---|---|---|---|---|---|---|
| ...តើលោកអ្នកមានចូលរួមលេង ឬមានបំណងចូលរួមលេង ...កីឡាប្រកបដោយគ្រោះថ្នាក់ណាមួយ (ដូចជាលោតទឹក ...ឡើងភ្នំ លោតឆ័ត្រយោង ប្រណាំង បរបាញ់។ល។) ...ដែរឬទេ? ប្រសិនបើមានសូមបញ្ជាក់ឲ្យបានលម្អិត។<br>...Do you engage in or intent to engage in any ...dangerous sport (diving, mountaineering, ...parachuting, racing, hunting, etc.)? If YES, ...please give details | ☑ | ☐ | | ☐ | ☐ | |

លេខពាក្យស្នើសុំ
Application No: **151 101440**

## សេចក្តីប្រកាសអំពីសុខភាពរបស់បុគ្គលដែលជាកម្មវត្ថុនៃការធានា (បន្ត) / HEALTH DECLARATION FOR LIFE ASSURED (Continued)

| | គ្មាន NO | មាន YES | បុគ្គលដែលជាកម្មវត្ថុនៃការធានាទី១ Life Assured 1 — បើមាន សូមរៀបរាប់លម្អិត If "YES", please give details | គ្មាន NO | មាន YES | បុគ្គលដែលជាកម្មវត្ថុនៃការធានាទី២ Life Assured 2 — បើមាន សូមរៀបរាប់លម្អិត If "YES", please give details |
|---|---|---|---|---|---|---|
| តើមានសមាជិកគ្រួសារណាម្នាក់របស់លោកអ្នក (ឪពុកម្តាយ បងប្អូន) មាន ឬស្លាប់ដោយសារជំងឺទឹកនោមផ្អែម ជំងឺសរសៃឈាមបេះដូង ជំងឺតម្រងនោម ជំងឺផ្លូវចិត្ត ជំងឺមហារីក ។ល។ ដែរឬទេ ប្រសិនបើមាន សូមបញ្ជាក់ឲ្យបានលម្អិត<br>Has any member of your family (parents, siblings) suffered from or died of diabetes, cardiovascular diseases, renal diseases, mental disorders, cancer, etc.?<br>If YES, please give details<br>2.1 ទំនាក់ទំនង / Relationship<br>2.2 ជំងឺ(នានា) / Disease(s)<br>2.3 នៅរស់ ឬស្លាប់ / Living or dead?<br>2.4 ចាប់ផ្តើមនៅអាយុ / Onset age | ☑ | ☐ | – | ☐ | ☐ | |

ប្រសិនបើឆ្លើយ "ធ្លាប់" នៅសំណួរទី៣ ឬទី៤ សូមបញ្ជាក់ចំនួន និងផ្តល់សេចក្តីលម្អិត ពាក់ព័ន្ធនឹងសភាពជំងឺ វះកាត់ ឬការព្យាបាល កាលបរិច្ឆេទ និងរយៈពេល ភាពធ្ងន់ធ្ងរ និងលទ្ធផល ឈ្មោះ និងអាសយដ្ឋានរបស់គ្រូពេទ្យព្យាបាល គ្លីនិក ឬមន្ទីរពេទ្យ
YES of question 3 or 4 below, please indicate
e number and give details as to the nature
illness, operation or treatment, date and duration,
verity and results, name and address of attending
ysician, clinics or hospitals.

| តើលោកអ្នកធ្លាប់: Have you ever: | មិនធ្លាប់ NO | ធ្លាប់ YES | បុគ្គលដែលជាកម្មវត្ថុនៃការធានាទី១ Life Assured 1 — បើធ្លាប់ សូមរៀបរាប់លម្អិត If "YES", please give details | មិនធ្លាប់ NO | ធ្លាប់ YES | បុគ្គលដែលជាកម្មវត្ថុនៃការធានាទី២ Life Assured 2 — បើធ្លាប់ សូមរៀបរាប់លម្អិត If "YES", please give details |
|---|---|---|---|---|---|---|
| 1 ថតកាំរស្មីអ៊ិច មានការកត់ត្រាចលនាបេះដូងដោយប្រើឧបករណ៍អេឡិចត្រូនិច ការពិនិត្យឈាម ឬការធ្វើតេស្តរោគវិនិច្ឆ័យផ្សេងទៀតដែរឬទេ / Had X-ray, electrocardiogram, blood studies or other diagnostic test? | ☑ | ☐ | | ☐ | ☐ | |
| 2 បាន ឬត្រូវបានប្រាប់ថា លោកអ្នកមានជំងឺអេដស៍ ភាពស្មុគស្មាញទាក់ទងនឹងជំងឺអេដស៍ ឬ ស្ថានភាពទាក់ទងនឹងជំងឺអេដស៍ដែរឬទេ តើមានបញ្ហាណាមួយអំពីរបៀបរស់នៅរបស់លោកអ្នកដែលអាចឲ្យអ្នកប្រឈមនឹងហានិភ័យកើតជំងឺអេដស៍ដែរឬទេ / Had or been told you had AIDS, AIDS-related complex or AIDS-related conditions? Is there anything about your lifestyle which could expose you to risk of AIDS? | ☑ | ☐ | | ☐ | ☐ | |
| 3 បានធ្វើតេស្តរកមើលភ្នាក់ងារប្រឆាំងនឹងមេរោគអេដស៍ឃើញថាវិជ្ជមានដែរឬទេ / Been tested positive for antibodies to the AIDS virus? | ☑ | ☐ | | ☐ | ☐ | |
| 4 មានទម្រង់ណាមួយនៃជំងឺកាមរោគ ដូចជា រោគស្វាយ និងរោគប្រមេះដែរឬទេ / Had any form of sexually transmitted disease such as syphilis and gonorrhea? | ☑ | ☐ | | ☐ | ☐ | |
| 5 ពិសាហួសកម្រិតនូវភេសជ្ជៈមានជាតិអាល់កុល ប្រើប្រាស់ថ្នាំញៀន ឬស្វែងរកដំបូន្មាន ឬការព្យាបាលចំពោះការញៀនគ្រឿងស្រវឹង ទម្លាប់ប្រើប្រាស់ថ្នាំ ឬការញៀនផ្សេងទៀតដែរឬទេ / Used alcoholic beverages to excess, taken habit-forming drugs or sought advice or treatment for alcoholism, drug habit or other addiction? | ☑ | ☐ | | ☐ | ☐ | |
| 5 ជក់បារីក្នុងឆ្នាំកន្លងទៅដែរឬទេ ប្រសិនបើធ្លាប់<br>Smoked cigarettes within the past years? If YES<br>តើលោកអ្នកបានជក់បារីអស់រយៈពេលប៉ុន្មានឆ្នាំហើយ<br>How many years have you smoked cigarettes?<br>ចំនួនបារីជាមធ្យមដែលលោកអ្នកជក់ជារៀងរាល់ថ្ងៃ<br>Average number of cigarettes daily. | ☑ | ☐ | | ☐ | ☐ | |

លេខពាក្យស្នើសុំ
Application No: 151101440

## សេចក្តីប្រកាសអំពីសុខភាពរបស់បុគ្គលដែលជាកម្មវត្ថុនៃការធានា (បន្ត) / HEALTH DECLARATION FOR LIFE ASSURED (Continued)

| | បុគ្គលដែលជាកម្មវត្ថុនៃការធានាទី១ Life Assured 1 | | | បុគ្គលដែលជាកម្មវត្ថុនៃការធានាទី២ Life Assured 2 | | |
|---|---|---|---|---|---|---|
| | មិនធ្លាប់ NO | ធ្លាប់ YES | បើធ្លាប់ សូមរៀបរាប់លម្អិត - If "YES", please give details | មិនធ្លាប់ NO | ធ្លាប់ YES | បើធ្លាប់ សូមរៀបរាប់លម្អិត If "YES", please give details |
| 4. តើលោកអ្នកធ្លាប់បាន ឬត្រូវបានប្រាប់ថា លោកអ្នកមាន ឬបានស្វែងរកដំបូន្មានចំពោះ៖ / Have you ever had or been told that you had, or sought advice for: | | | – | | | |
| 4.1 អាការៈវិលមុខ សន្លប់ ជំងឺឆ្កួតជ្រូក វិកលចរិត ឈឺក្បាលធ្ងន់ធ្ងរ ឬ ជំងឺ ណាមួយ ឬ កំជំងឺពាក់ព័ន្ធនឹងប្រព័ន្ធសរសៃប្រសាទដែរឬទេ? / Dizziness, fainting spells, epilepsy, nervous breakdown, severe headaches, or any disease or disorder of the brain or nervous system? | ✓ | ☐ | | ☐ | ☐ | |
| 4.2 ជំងឺហឺត គ្រុនក្តៅ ក្អករ៉ាំរ៉ៃ ក្អកឈាម របេង ឬជំងឺណាមួយ ឬកំជំងឺសួតនៃប្រព័ន្ធដំណកដង្ហើម ដែរឬទេ? / Asthma, hay fever, chronic cough, spitting of blood, tuberculosis or any disease or disorder of the lungs or respiratory system? | ✓ | ☐ | | ☐ | ☐ | |
| 4.3 ជំងឺលើសឈាម ដាច់សរសៃឈាមខួរក្បាល ឈឺទ្រូង ដកដង្ហើមមិនរួច ស្រាលបេះដូង ឬជំងឺណាមួយ ឬ ជំងឺបេះដូង ឬប្រព័ន្ធចរន្តឈាមដែរឬទេ? / High blood pressure, stroke, chest pain, shortness of breath, heart murmur, or any disease or disorder of the heart or circulatory system? | ✓ | ☐ | | ☐ | ☐ | |
| 4.4 ជំងឺណាមួយ ឬជំងឺបំពង់អាហារ ក្រពះ ពោះវៀនតូច ពោះវៀនធំ ចុងពោះវៀន ខ្នែងពោះវៀន ថ្លើម ឬ ប្រមាត់ លំពែង ដែរឬទេ? / Any disease or disorder of the oesophagus, stomach, intestines, bowel, rectum, appendix, liver, gall bladder or spleen? | ✓ | ☐ | | ☐ | ☐ | |
| 4.5 ជំងឺរលាកតម្រងនោម គ្រួសក្នុងតម្រងនោម ឬជំងឺណាមួយ ឬ កំជំងឺតម្រងនោម ប្លោកនោម ឬក្រពេញប្រូស្តាត ដែរឬទេ Nephritis, kidney stones, or any disease or disorder of the kidney, bladder or prostate? | ✓ | ☐ | | ☐ | ☐ | |
| 4.6 ជំងឺទឹកនោមផ្អែម ក្រពេញទីរ៉ូអ៊ីត ឬជំងឺក្រពេញអង់ដូគ្រីន ដែរឬទេ? / Diabetes, thyroid or other endocrine disorders? | ✓ | ☐ | | ☐ | ☐ | |
| 4.7 ជំងឺរលាកសន្លាក់ឆ្អឹង ជំងឺឈឺសន្លាក់ឆ្អឹង ឬជំងឺណាមួយ ឬ កំការមិនប្រក្រតី ផ្នែកខ្នង ឆ្អឹងខ្នង ឆ្អឹង សន្លាក់ ឬសាច់ដុំ ដែរឬទេ? / Arthritis, rheumatism, or any disease or disorder of the back, spine, bones, joints or muscles? | ✓ | ☐ | | ☐ | ☐ | |
| 4.8 មហារីក ឬដុំសាច់ ដំបៅក្រពះប្រភេទណាមួយដែរឬទេ Cancer or a tumor or ulcer of any kind? | ✓ | ☐ | | ☐ | ☐ | |
| 4.9 ជំងឺហើមសរសៃវ៉ែន ដំបៅសរសៃវ៉ែន ឬរលាកសរសៃវ៉ែន ឬ ជំងឺក្លូនប្រភេទណាមួយ ដែរឬទេ? / Varicose veins, varicose ulcers or phlebitis or hernia of any kind? | ✓ | ☐ | | ☐ | ☐ | |
| 4.10 ជំងឺស៊ីអ៊ី (ជំងឺលើស្បែកម្យ៉ាង) ឬជំងឺស៊ុយប្រព័ន្ធ ភាពស៊ាំដទៃទៀត និង ជំងឺខ្វះឈាមក្រហម ឬជំងឺឈាមដទៃទៀត ដែរឬទេ? / SLE or other autoimmune diseases? Anaemia or other blood diseases? | ✓ | ☐ | | ☐ | ☐ | |
| 4.11 ជំងឺណាមួយ ឬជំងឺភ្នែក ត្រចៀក ច្រមុះ ឬបំពង់ក ដែរឬទេ? / Any disease or disorder of the eyes, ears, nose or throat? | ✓ | ☐ | | ☐ | ☐ | |

លេខពាក្យស្នើសុំ
Application No: 151101440

## សេចក្តីប្រកាសអំពីសុខភាពរបស់បុគ្គលដែលជាកម្មវត្ថុនៃការធានា (បន្ត) / HEALTH DECLARATION FOR LIFE ASSURED (Continued)

| | មិនធ្លាប់ NO | ធ្លាប់ YES | បុគ្គលដែលជាកម្មវត្ថុនៃការធានាទី១ Life Assured 1 — បើធ្លាប់ សូមរៀបរាប់លម្អិត If "YES", please give details | មិនធ្លាប់ NO | ធ្លាប់ YES | បុគ្គលដែលជាកម្មវត្ថុនៃការធានាទី២ Life Assured 2 — បើធ្លាប់ សូមរៀបរាប់លម្អិត If "YES", please give details |
|---|---|---|---|---|---|---|
